مدرسة اهل البيت

صلوات الله عليهم

# សាលា

# អាស់ួលុល-បៃត៍

## សៀវភៅសិក្សា ប្រវត្តិសាស្ត្រ (تَارِيْخ)

## ថ្នាក់ទី ៦ (អាយុ ១០-១១ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថាៈ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ វិវរណីយៈដំបូង ........ ៤
មេរៀនទី ២ បុគ្គលដំបូងបង្អស់ដែលទៅជាមុស្លីម ........ ៧
មេរៀនទី ៣ ដ្ហាក្វ៉ាស់ ស៊្មុល អាស្ហ៊ីរ៉ោះត៍ (دعوة ذي العشيرة) ........ ១០
មេរៀនទី ៤ ការធ្វើបាបពួកមុស្លីម ........ ១៤
មេរៀនទី ៥ ហ៊្ជីរ៉ោះត៍ទៅកាន់អាប៊ីស៊ីនី ........ ១៩
មេរៀនទី ៦ ពហិការលើ បានី ហ្ហាស៊្មីម ........ ២៤
មេរៀនទី ៧ អាប៊ូ ត៍លិបនិងព្រះនាងខ៉ូឌីយ៉ាស់ទទួលអនិច្ចកម្ម ........ ២៨
មេរៀនទី ៨ ព្រះអារោហ (មិអ៍រ៉ាច់) របស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ ........ ៣២
មេរៀនទី ៩ ដំណើរទៅត៍អ៊ីហ្វ ........ ៣៧
មេរៀនទី ១០ កិច្ចសន្យានៅអាក៏បាស់ ........ ៤១
មេរៀនទី ១១ ហ៊្ជីរ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ១ ........ ៤៥
មេរៀនទី ១២ ហ៊្ជីរ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ២ ........ ៤៨
មេរៀនទី ១៣ ហ៊្ជីរ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ៣ ........ ៥៣
មេរៀនទី ១៤ ហ៊្ជីរ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ៤ ........ ៥៦
មេរៀនទី ១៥ ព្រះសាស្ដា អ៊ីបរ៉ហ៊ីមعليه السلام - ភាគ ១ ........ ៦០
មេរៀនទី ១៦ ព្រះសាស្ដា អ៊ីបរ៉ហ៊ីមعليه السلام - ភាគ ២ ........ ៦៦
មេរៀនទី ១៧ ព្រះសាស្ដា អ៊ីបរ៉ហ៊ីមعليه السلام - ភាគ ៣ ........ ៧០
មេរៀនទី ១៨ ព្រះសាស្ដា អ៊ីសម៉ាអ៊ីលعليه السلام ........ ៧៥
មេរៀនទី ១៩ ព្រះសាស្ដា អៃយូបعليه السلام ........ ៨១
មេរៀនទី ២០ ព្រះសាស្ដា យូនុសعليه السلام ........ ៨៦
បទនិពន្ធ ........ ៩១

## មេរៀនទី ១

# វិវរណីយៈដំបូង

ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺធ្លាប់តែចំណាយពេលមួយប៉ែកធំ នៅក្នុងគុហាភ្នំហ៊ីរ៉អ៍ ភ្នំមួយដែលអាចមើលពីលើឃើញកាក់បាស់ នៅឯប៉ែកខាងជើងម៉ាក់កាស់ ប្រមាណបីគីឡូម៉ែត្រ ។

ជួនកាលព្រះអង្គﷺតាំងសមាធិពីរបីថ្ងៃជាប់នៅក្នុងគុហា ព្រះមហេសីព្រះអង្គﷺ ព្រះនាងខ៍ឌីយ៉ាស់ (عليها السلام) បានយកបាយទឹកមកឲ្យព្រះអង្គﷺ ។

យប់មួយកាលព្រះអង្គﷺនៅក្នុងគុហាភ្នំហ៊ីរ៉អ៍ ព្រះអង្គﷺបានឮសម្លេងហៅព្រះនាមព្រះអង្គﷺ ហើយក៏មានពន្លឺចែងចាំងនៅក្នុងគុហា ។ ព្រះសាស្តាﷺដាក់ខ្លួនអង្គុយដោយស្ងៀមស្ងាត់មួយកន្លែង ហើយបានឃើញបុរសម្នាក់ដើរចូលមកជិតព្រះអង្គﷺ ។ បុរសនោះពុំមែនអ្នកណាក្រៅពីយ៉ីបរ៉អ៊ីល (عليه السلام) ទេដែលក្លែងខ្លួនជាមនុស្ស ។ យ៉ីបរ៉អ៊ីល (عليه السلام) ប្រាប់ព្រះសាស្តាﷺឲ្យអានអ្វីដែលមានចារនៅលើរមូរសំពត់ធ្វើអំពីសូត្រនៅក្នុងដៃព្រះអង្គ (عليه السلام) ។ ព្រះសាស្តាﷺបានអានពាក្យពេជន៍ដែលជាព្រះវិវរណីយៈដំបូងរបស់អល់ឡោះហ្វ៏ (عزّ وجلّ) (គឺវ៉ាហ៊ីរបស់អល់ឡោះហ្វ៏ (عزّ وجلّ)) ដែលក្រោយមកបានក្លាយទៅជាប្រាំអាយ៉ាស់ដំបូងរបស់ស៊ូរ៉ោះត៍ អាល់-អាឡាក់ គឺ៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

ٱقۡرَأۡ بِٱسۡمِ رَبِّكَ ٱلَّذِي خَلَقَ ١ خَلَقَ ٱلۡإِنسَٰنَ مِنۡ عَلَقٍ ٢ ٱقۡرَأۡ وَرَبُّكَ ٱلۡأَكۡرَمُ ٣ ٱلَّذِي عَلَّمَ بِٱلۡقَلَمِ ٤ عَلَّمَ ٱلۡإِنسَٰنَ مَا لَمۡ يَعۡلَمۡ ٥

*ដោយនូវព្រះនាមអល់ឡោះហ្វ៏ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*1. ចូរអ្នកសូត្រទៅ ក្នុងព្រះនាមព្រះម្ចាស់អ្នកដែលបានបង្កើត 2. ព្រះអង្គបានបង្កើតមនុស្សពីដុំឈាមខន់ ។ 3. ចូរអ្នកសូត្រទៅ ព្រះម្ចាស់អ្នកមានព្រះហឫទ័យទូលំទូលាយបំផុត 4. ព្រះដែលបានបង្ហាត់បង្រៀនដោយប៉ាកកា ។ 5. ព្រះអង្គបានបង្ហាត់បង្រៀនមនុស្សនូវអ្វីដែលគេមិនបានចេះដឹង ។* (96:1-5)

ពេលព្រះសាស្តាមូហ៊ាំម៉ាដ់ﷺអានចប់ ទេវតាយ៊ីបរ៉អ៊ីល﵇មានវចនៈថា៖ "មូហ៊ាំម៉ាដ់ﷺអើយ មិនមានអ្វីគួរឲ្យសង្ស័យទេ ព្រះអង្គﷺជាព្រះសាស្តារបស់អល់ឡោះហ៊្វ عز وجل ពិតមែន ឯទូលបង្គំ﵇ជាទេវតារបស់ព្រះអង្គ عز وجل ។" បន្ទាប់ពីបានថាពាក្យពេជន៍មួយឃ្លានេះ យ៊ីបរ៉អ៊ីល﵇ក៏បានបាត់ខ្លួន ។ ព្រឹត្តិការណ៍នេះបញ្ជាក់ប្រាប់ព្រះសាស្តាﷺថាដល់ពេលព្រះអង្គﷺចាប់ផ្តើមបំពេញបេសកកម្ម ។ កាលនោះព្រះអង្គﷺមានព្រះជន្ម ៤០ ឆ្នាំ ។ ថ្ងៃទីរបស់ព្រឹត្តិការណ៍នោះគឺថ្ងៃទី ២៧ រ៉យ៉ាប់ ត្រូវនឹងឆ្នាំ 610 នៃគ្រិស្តសករាជ ។ ដូច្នេះ កាលនោះអល់ឡោះហ៊្វ عز وجل បានប្រទានអំណោយឲ្យព្រះសាស្តាﷺនូវការចងចាំអស្ចារ្យមហិមា អ្វីដែលព្រះអង្គﷺបានឮតែមួយដងពីយ៊ីបរ៉អ៊ីល﵇ ព្រះអង្គﷺចងចាំជាប់ក្នុងចិត្តរហូតអនន្ត ។

ព្រះសាស្តាﷺបានចាកចេញពីគុហា ត្រឡប់ទៅលំនៅដ្ឋានវិញ ទីកន្លែងដែលព្រះអង្គﷺចង់ចាប់ផ្តើមបំពេញបេសកកម្មព្រះអង្គﷺដំបូងបង្អស់ គឺផ្សាយឯកលក្ខណៈរបស់អល់ឡោះហ៊្វ عز وجل ហៅមនុស្សជាតិមកកាន់មាគ៌ាសក្ការៈព្រះតែមួយគត់ ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺះ

១. ហេតុអ្វីព្រះសាស្តាﷺចំណាយពេលច្រើននៅក្នុងគូហាភ្នំហ៊ីរ៉អ៍ ?

២. ហេតុអ្វីព្រះអង្គﷺមិនខ្លាច ពេលព្រះអង្គﷺឃើញយ៉ីបរ៉អ៊ីលﷷ ?

៣. ហេតុអ្វីអល់ឡោះហ្វ៍ﷻប្រទានឲ្យព្រះអង្គﷺនូវការចងចាំឯក ?

៤. តើមានសារៈសំខាន់អ្វីដែលព្រះសាស្តាចាប់ផ្តើមបំពេញបេសកកម្ម ពេលព្រះអង្គﷺមានព្រះជន្ម ៤០ ឆ្នាំ ?

៥. ខ្លឹមសាររបស់បេសកកម្មព្រះអង្គﷺគឺអ្វី ?

## មេរៀនទី ២

# បុគ្គលដំបូងបង្អស់ដែលទៅជាមុស្លីម

កាលព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានត្រឡប់មកពីគុហាភ្នំហ៊ីរ៉អ៍វិញ ក្រោយពីវិវរណីយៈដំបូង ព្រះអង្គ ﷺ ឆ្ពោះទៅកាន់ផ្ទះព្រះអង្គ ﷺ មុនគេ ។

ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ រស់នៅជាមួយព្រះមហេសីព្រះអង្គ ﷺ ព្រះនាងខ៌ឌីយ៉ាស្ហ់ سلام الله عليها និងអ៊ីម៉ាំអាលី صلوات الله عليه والسلام ប្អូនប្រុសជីតាមួយរបស់ព្រះអង្គ ﷺ ដែលនៅកុមារភាព ។ អាប៊ូ ត៉លិប មិនអាចចិញ្ចឹមកូនប្រុសទាំងបួនរបស់លោកបានទេ ព្រោះលោកក្រ ។ ហេតុដូច្នេះ កូនប្រុសលោកឈ្មោះ យ៉ាក់ហ្វារ ត្រូវប្អូនប្រុសលោកឈ្មោះ អាប់បាស់ យកទៅចិញ្ចឹម ចំណែកឯអាលី صلوات الله عليه والسلام កូនប្រុសលោក ត្រូវព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ យកទៅចិញ្ចឹម ។ កាលអ៊ីម៉ាំអាលី صلوات الله عليه والسلام ប្រសូតមក ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ទើបនឹងបានបាត់បង់ព្រះរាជបុត្របង្កើត ។ សៃយីដ្ឋាស្ហ់ ហ្វាទីម៉ាស្ហ់ ប៊ិនទី អាសាដ្ឋ់ មហេសីរបស់ អាប៊ូ ត៉លិប បានសន្យាព្រះអង្គ ﷺ ថាពេលកូនប្រុសព្រះនាងធំបន្តិច ព្រះនាងនឹងឲ្យកូនប្រុសនោះទៅព្រះអង្គ ﷺ ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام មានព្រះជន្ម ៩ ឆ្នាំកាលព្រះអង្គ صلوات الله عليه والسلام ទៅរស់នៅជាមួយព្រះនាងខ៌ឌីយ៉ាស្ហ់ سلام الله عليها និងព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ។

ពេលបានទៅដល់ផ្ទះ ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ បានប្រាប់ព្រះមហេសីព្រះអង្គ ﷺ ឲ្យជ្រាបអំពីព្រឹត្តិការណ៍ដែលបានកើតឡើង ព្រះនាង سلام الله عليها ក៏បានជឿព្រះអង្គ ﷺ ជាព្រះសាសនៈទូតរបស់អល់ឡោះហ្ស៍ عز وجل ភ្លាម ហើយក៏បានទៅជាស្ត្រីមុស្លីម ។ បុគ្គលបន្ទាប់ដែលព្រះសាស្តា ﷺ បានប្រាប់ឲ្យជ្រាបរឿងនេះ គឺអ៊ីម៉ាំអាលី صلوات الله عليه والسلام កាលព្រះអង្គ صلوات الله عليه والسلام មានព្រះជន្ម ១២ ឆ្នាំ ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام ក៏ព្រមទទួលសាសនាអ៊ីស្លាមដែរពេលបានដឹងរឿងព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ។ ដូច្នេះ សៃយីដ្ឋាស្ហ់ ខ៌ឌីយ៉ាស្ហ់ سلام الله عليها ជាស្ត្រីដំបូងបង្អស់ដែលបានទៅជានារីមុស្លីម អ៊ីម៉ាំអាលី صلوات الله عليه والسلام ជាបុរសដំបូងបង្អស់ដែលបានទៅជាបុរសមុស្លីម ។ បុគ្គលទីបីដែលបានទៅជាមុស្លីម គឺ ស៊ៃដ្ឋ៍ ប៊ិន ហារីស្ហ៍ ដែលជាបម្រើរបស់ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ដែលត្រូវដោះលែងឲ្យមានសេរីភាព និងជាកូនចិញ្ចឹមរបស់ព្រះអង្គ ﷺ ។

ព្រះសាស្ដាមូហ្ហាំម៉ាដ់صلى الله عليه وآله وسلمបានទទួលព្រះវិវរណៈថ្មីៗពីអល់ឡោះហ្ទ៍عزوجل ព្រះអង្គصلى الله عليه وآله وسلمបានចាប់ផ្ដើមផ្សាយសាសនាអ៊ីស្លាមបន្តិចម្ដងៗ ។ បីឆ្នាំដំបូង ព្រះអង្គصلى الله عليه وآله وسلم មិនបានប្រកាសឲ្យមហាជនទាំងអស់ដឹងតែម្ដងទេ តែព្រះអង្គصلى الله عليه وآله وسلمបានជ្រើសរើសមនុស្សខ្លះ ដែលព្រះអង្គصلى الله عليه وآله وسلمគិតថានឹងព្រមជឿសាសនារបស់អល់ឡោះហ្ទ៍عزوجل ។ ហេតុដូច្នេះឯងបានជាមានតែ ៣០ នាក់ទេដែលទៅជាមុស្លីមក្នុងអំឡុងពេលបីឆ្នាំដំបូងនេះ ។

ពួកគូរ៉យ់ស្ហ៍និងមេដឹកនាំឈ្មោះ អាប៊ូ ស៊ុហ្វយ៉ាន ដឹងថាអ្វីកំពុងតែកើតឡើង តែមិនបារម្ភអំពីសកម្មភាពរបស់ព្រះសាស្ដាមូហ្ហាំម៉ាដ់صلى الله عليه وآله وسلمទេកាលនោះ ។ ពួកគេគិតថាសាសនាថ្មីនេះនឹងរលត់បាត់ដូចកាល វ៉ារ៉ាកោះត៍ និង អ៊ូម៉ៃយ៉ាស់ បានធ្វើសក្ការៈរូបព្រះបន្ទាប់ពីបានកាន់សាសនាគ្រិស្ដមួយរយៈពេលខ្លី ក្រោយពីបានអានគម្ពីរអ៊ិនយ៊ីលនោះដែរ ។

ក្នុងអំឡុងពេលបីឆ្នាំ ពួកគូរ៉យ់ស្ហ៍មិនធ្វើទុក្ខព្រះសាស្ដាصلى الله عليه وآله وسلمទេ ពួកគេនៅតែគោរពព្រះអង្គصلى الله عليه وآله وسلم ។ ចំណែកព្រះសាស្ដាصلى الله عليه وآله وسلمវិញមិនរិះគន់រូបព្រះពួកគេចំៗទេ ព្រះអង្គصلى الله عليه وآله وسلمរវល់តែរក្សាទំនាក់ទំនងជាមួយក្រុមមុស្លីមដ៏តូចរបស់ព្រះអង្គصلى الله عليه وآله وسلم ។ ពួកគូរ៉យ់ស្ហ៍ស្ងប់ស្ងៀម រហូតដល់ថ្ងៃដែលព្រះសាស្ដាصلى الله عليه وآله وسلمមូហ្ហាំម៉ាដ់صلى الله عليه وآله وسلمចាប់ផ្ដើមផ្សាយសាសនាអ៊ីស្លាមដោយលែងលាក់បាំង តាមព្រះបញ្ជាអល់ឡោះហ្ទ៍عزوجل ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីពួកគូរ៉យស្ជ៍មិនអើពើ សកម្មភាពព្រះសាស្ដាមូហាំម៉ាដ្ជ៍ﷺកាលពីដើម ?

២. ហេតុអ្វីអ៊ីមុាំអាលីعليه السلامរស់នៅជាមួយព្រះសាស្ដាមូហាំម៉ាដ្ជ៍ﷺ ?

៣. តើអ៊ីមុាំអាលីعليه السلامជាប់សាច់សាលោហិតអ្វី ជាមួយព្រះសាស្ដាមូហាំម៉ាដ្ជ៍ﷺ ?

៤. អ្នកណាជានារីដំបូងបង្អស់ដែលទៅជាស្ត្រីមុស្លីម ? អ្នកណាជាបុរសដំបូងបង្អស់ដែលទៅជាបុរសមុស្លីម ?

៥. ហេតុអ្វីព្រះសាស្ដាមូហាំម៉ាដ្ជ៍ﷺបានប្រកាសសាសនាអ៊ីស្លាម ឲ្យមនុស្សតែពីរបីនាក់ដឹងប៉ុណ្ណោះ ?

## មេរៀនទី ៣

# ដាក់វ៉ាស់ ស៊ុល អ៊ុស្ហ៊ីរ៉ោះត៍

دعوة ذي العشيرة

បន្ទាប់ពីបានបំពេញបេសកកម្មសាស្ដាបីឆ្នាំ ព្រះសាស្ដាមូហាំម៉ាដ់ﷺបាន ទទួលព្រះវិវរណ៍ាយៈពីអល់ឡោះហ៊្ជَلَّ وَعَزَّ ថា៖

وَأَنذِرْ عَشِيرَتَكَ ٱلْأَقْرَبِينَ ﴿٢١٤﴾

*214. ចូរអ្នកដាស់តឿន (គឺហៅមករកអល់ឡោះហ៊្) ញាតិសន្តានជិតស្និទ្ធបំផុតរបស់អ្នក ។* ស៊ូរ៉ោះត៍ អាស្ហ៊-ស្ហ៊ុអារ៉ អ៊ុ អាយ៉ាស់ 214 (26:214)

ពេលបានទទួលព្រះរាជបញ្ជានេះ ព្រះសាស្ដាមូហាំម៉ាដ់ﷺហៅអ៊ីម៉ាំអាលី صلوات الله عليه والسلام មកប្រាប់ឲ្យរៀបចំពិធីលៀងអាហារ ដោយហៅបណ្ដាកូនៗរបស់អ៊ុប់ឌុល-មុត្ដត៍លិបមកចូលរួម ដើម្បីព្រះអង្គﷺនឹងប្រាប់ព្រះរាជបន្ទូលរបស់អល់ឡោះហ៊្ជَلَّ وَعَزَّ ឲ្យពួកគាត់ជ្រាប ។ បណ្ដាកូនៗរបស់អ៊ុប់ឌុល-មុត្ដត៍លិបប្រមាណសែសិបនាក់ បានឆ្លើយតបការអញ្ជើញ មកប្រជុំគ្នានៅក្បែរភ្នំស្ហ៍ហ្វា ដោយមានឪពុកធំរបស់ព្រះសាស្ដាﷺគឺ៖ អាប៊ូ ត៍លិប, អ៊ុប់បាស់, ហាំស្ហាស់ និង អាប៊ូ ឡាហាប់ ។

គេហៅការអញ្ជើញសាច់ញាតិជិតស្និទ្ធរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ មកចូលសាសនាអ៊ីស្លាមនេះថា ដាក់វ៉ាស់ ស៊ុល អ៊ុស្ហ៊ីរ៉ោះត៍ ។



ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានសូមឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلام លើកម្ហូបមកដាក់ឲ្យភ្ញៀវ ។ អ៊ីម៉ាំអាលីصلوات الله عليه والسلامក៏បានលើកម្ហូបមកឲ្យភ្ញៀវ តែម្ហូបនោះតិចណាស់មិនគ្រប់សម្រាប់ភ្ញៀវតែម្នាក់ផង ។ ព្រះសាស្តាصلى الله عليه وآله وسلمបានប្រសិទ្ធពរម្ហូបដោយព្រះនាមអល់ឡោះហ្វ៍عز وجل ហើយបានអញ្ជើញភ្ញៀវបរិភោគ ។ ភ្ញៀវរាល់គ្នាទាំងសែសិបនាក់បានបរិភោគឆ្អែត តែម្ហូបមិនរលស់ទេ នៅសល់ដដែល ។

បរិភោគលៀងរួច ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمចង់និយាយប្រាប់អង្គប្រជុំតែ អាប៊ូឡាហ្វាប់បានប្រាប់គេថាព្រះសាស្តាصلى الله عليه وآله وسلمបានប្រើមន្តអាគម ។ មនុស្សក៏បានចាកចេញទៅវិញអស់ ។

ថ្ងៃស្អែក ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានសូមឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامរៀបចំពិធីដដែលដូចកាលពីម្សិលមិញ តែបានលទ្ធផលដដែល ។ ថ្ងៃទីបី ព្រះសាស្តាصلى الله عليه وآله وسلمបានអញ្ជើញក្រុមមនុស្សដដែលម្តងទៀតមកបរិភោគលៀង ។ លើកនេះព្រះអង្គصلى الله عليه وآله وسلمងើបឡើងភ្លាមពេលបរិភោគរួច ហើយប្រកាសប្រាប់អង្គប្រជុំថា៖ "បណ្តាកូនៗរបស់អាប់ឌុល-មុត្តត៌លិបអើយ ខ្ញុំصلى الله عليه وآله وسلمសូមស្បថចំពោះអល់ឡោះហ្វ៍عز وجلថាពុំមានព្រះទេក្រៅពីព្រះអង្គعز وجل ថាខ្ញុំصلى الله عليه وآله وسلمត្រូវព្រះអង្គعز وجلចាត់បញ្ជូនមកជាព្រះសាសនៈទូតរបស់ព្រះអង្គعز وجل ។ បងប្អូនខ្ញុំصلى الله عليه وآله وسلمអើយ ថ្ងៃណាមួយបងប្អូននឹងស្លាប់ដូចដេកលក់ បន្ទាប់មកបងប្អូននឹងរស់ឡើងវិញ ដើម្បីគេនឹងជម្រះក្តីអស់លោកតាមទង្វើរបស់អស់លោក ។ អ្នកល្អនឹងបានទៅឋានសួគ៌ អ្នកបាបនឹងចូលនរករហូត ។ ពុំដែលមានអ្នកណាបាននាំមកឲ្យប្រជារាស្ត្រខ្លួននូវដំណឹងល្អ ជាងដំណឹងល្អដែលខ្ញុំصلى الله عليه وآله وسلمនាំមកឲ្យអស់លោកនេះទេ ។ ព្រះម្ចាស់عز وجلខ្ញុំصلى الله عليه وآله وسلمឲ្យខ្ញុំصلى الله عليه وآله وسلمហៅអស់លោកទៅរកព្រះអង្គعز وجل ។ តើអស់លោកណាម្នាក់នឹងគាំទ្រខ្ញុំصلى الله عليه وآله وسلم ដើម្បីនឹងទៅជាបងប្អូនខ្ញុំصلى الله عليه وآله وسلمនិងជាអ្នកស្នងខ្ញុំصلى الله عليه وآله وسلمអត់ពីខ្ញុំصلى الله عليه وآله وسلمទៅ ?" ពេលព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈដល់ត្រឹមនេះ អង្គប្រជុំស្ងាត់មាត់ ។ ស្រាប់តែអ៊ីម៉ាំអាលីصلوات الله عليه والسلام ដែលមានព្រះជន្មត្រឹមតែ ១៥ ឆ្នាំនោះ ងើបឡើងថា៖ "ព្រះសាសនៈទូតصلى الله عليه وآله وسلمអល់ឡោះហ្វ៍عز وجلអើយ ទូលបង្គំصلوات الله عليه والسلامសូមគាំទ្រព្រះអង្គصلى الله عليه وآله وسلم ។" ព្រះសាស្តាصلى الله عليه وآله وسلمបានឲ្យព្រះអង្គصلوات الله عليه والسلامអង្គុយវិញ ហើយបានសួរដដែលបីដង ។ រាល់ដងពុំមានអ្នកណាងើបឡើងទេក្រៅពីអ៊ីម៉ាំអាលីصلوات الله عليه والسلام ដើម្បីគាំទ្រព្រះអង្គصلى الله عليه وآله وسلم ។ ក្រោយលើកទីបី ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានឱបអ៊ីម៉ាំអាលីصلوات الله عليه والسلام ហើយបានចាប់ដៃព្រះអង្គصلوات الله عليه والسلامលើកឡើង មានព្រះវចនៈថា៖ "ប្រជារាស្ត្រអើយ យុវជន



នេះជាបងប្អូនខ្ញុំﷺនិងជាអ្នកស្នងខ្ញុំﷺ ក្នុងចំណោមអស់លោក ។ ចូរស្តាប់គេصلوات الله عليه والسلام ចូរតាមគេصلوات الله عليه والسلام ។" ពេលនោះអង្គប្រជុំបានចប់ អ្នកខ្លះបានបែរទៅរក អាប៊ូ ត៉ូលិប ចំអកឲ្យលោកថា៖ "មូហាំម៉ាដ់ﷺបញ្ជាឲ្យលោកតាមកូនប្រុសលោក ឲ្យគោរពបញ្ជាកូនប្រុសលោក បានតែងតាំងកូនប្រុសលោកជារៀមច្បងលោក ។"

តែព្រះវចនៈរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺជាពាក្យពិត ។ ច្រើនលើក ច្រើនគ្រាក្នុងជីវិតព្រះអង្គﷺ ព្រះអង្គﷺបានថាដូចនេះដដែលៗអំពីឋានៈពិសេសរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلام ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានហៅតែបណ្តាកូនៗរបស់ អាប់ឌុលមុត្តលិប ប៉ុណ្ណោះមកបរិភោគលៀង ?

២. ហេតុអ្វី អាប៊ូ ឡាហាប់ ចង់បំបែកអង្គប្រជុំ ?

៣. តើព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានសន្យាអ្វី ចំពោះបុរសដែលគាំទ្រព្រះអង្គ صلى الله عليه وآله وسلم ?

៤. មានតែអ្នកណាម្នាក់គត់ដែលគាំទ្រព្រះអង្គ صلى الله عليه وآله وسلم ដោយចេញមុខ ?

៥. តើអ្នកអាចរៀបរាប់អំពីព្រឹត្តិការណ៍មួយទៀតបានទេ ដែលព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានថាដូចនេះដែរអំពីឋានៈរបស់អ៊ីមុាំអាលី صلوات الله عليه والسلام ?

## មេរៀនទី ៤

# ការធ្វើបាបពួកមុស្លីម

បន្ទាប់ពីបានប្រាប់សាច់ញាតិជិតរបស់ព្រះអង្គ صلى الله عليه وآله وسلم ឲ្យស្គាល់សាសនាអ៊ីស្លាម ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានបើកឲ្យពួកអ្នកស្រុកម៉ាក់កាស់ដឹង នូវព្រះបេសកកម្មសាស្ដារបស់ព្រះអង្គ صلى الله عليه وآله وسلم ។ ព្រះអង្គ صلى الله عليه وآله وسلم បានហៅប្រជាជាតិទាំងអស់មកប្រជុំគ្នានៅឯភ្នំស្វ៏ហ្វា ប្រាប់ពួកគេថា៖ "បើខ្ញុំ صلى الله عليه وآله وسلم ប្រាប់អស់លោកថាមានសត្រូវនៅពីក្រោយភ្នំនេះ ត្រៀមខ្លួនវាយប្រហារអស់លោក តើអស់លោកជឿខ្ញុំ صلى الله عليه وآله وسلم ទេ ?" ទាំងអស់គ្នាតបថា៖ "ជឿ ព្រោះយើងមិនដែលឃើញលោក صلى الله عليه وآله وسلم និយាយកុហកសោះ ។" ព្រះសាស្ដា صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ចូរអស់លោកការពារខ្លួនពីភ្លើងនរក ។ ចូរអស់លោកជឿថាពុំមានព្រះទេក្រៅពីអល់ឡោះហ៍ عز وجل អស់លោកនឹងមានជីវិតរុងរឿង ។" ពេលបានឮសម្ដីនេះមនុស្សជ្រួលច្របល់ ។ អាប៊ូ ឡាហ្ហាប់បាននិយាយខ្លាំងៗថា៖ "ឯង صلى الله عليه وآله وسلم ធ្វើឲ្យយើងខាតពេលដោយនិយាយផ្ដេសផ្ដាសបែបនេះ ។"



ពួកអ្នកស្រុកម៉ាក់កាស្ហ៍ក៏បានភ្លេចថា ខ្លួនធ្លាប់តែហៅព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ថា "អាស្ហ៍-ស្ហ៍ឌិក្ហ" មានន័យ "សច្ចការី" ។ ផ្ទុយពីនេះ ពួកគេចាប់ផ្ដើមហៅព្រះអង្គ ﷺ ថាមនុស្សកុហក មនុស្សឆ្កួត ។ ពួកគេចាប់ផ្ដើមធ្វើទុក្ខព្រះអង្គ ﷺ ដោយដាក់បន្លាតាមផ្លូវដែលព្រះអង្គ ﷺ ធ្លាប់ដើរ ញុះញង់មនុស្សឲ្យចោលព្រះអង្គ ﷺ ដោយដុំថ្ម ។ ជួនកាល ពួកគេចោលសម្រាមមកលើព្រះអង្គ ﷺ ពេលព្រះអង្គ ﷺ ដើរកាត់ក្រោមបង្អួចផ្ទះពួកគេ ។ ព្រះសាស្ដា ﷺ មិនអើពើទង្វើទាំងនេះទេ ព្រះអង្គ ﷺ មិនឈប់ផ្សាយជំនឿព្រះតែមួយទេ ជួសជំនឿលើរូបព្រះរយពាន់ដែលពួកអ្នកស្រុកម៉ាក់កាស្ហ៍ធ្វើសក្ការៈនោះ ។

ពេលពួកមុស្លីមមានចំនួនកាន់តែច្រើនឡើងៗ ពួកមេដឹកនាំប្រជាជាតិខ្លះបារម្ភ មកជួប អាប៊ូ ត៍្វលិប ឪពុកធំរបស់ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ដើម្បីសូមឲ្យលោកបញ្ឈប់ក្មួយ ﷺ លោក កុំឲ្យផ្សាយសាសនាព្រះអង្គ ﷺ តទៅទៀត ។ ពួកគេព្រមឲ្យទៅព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ប្រាក់ អំណាចឬអ្វីៗស្រេចតែព្រះអង្គ ﷺ ចង់បាន ឲ្យតែព្រះអង្គ ﷺ ឈប់និយាយជំទាស់រូបព្រះរយពាន់របស់ពួកគេ ។

ពេល អាប៊ូ ត៍្វលិប នាំសម្ដីពួកគេមកប្រាប់ព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ព្រះអង្គ ﷺ មានព្រះវចនៈថា៖ "សូមស្បថចំពោះអល់ឡោះហ៍ ﷻ ទោះបីពួកគេយកថ្ងៃមកថ្វាយខ្ញុំ ﷺ ក្នុងដៃខ្ញុំ ﷺ ម្ខាង យកខែមកថ្វាយខ្ញុំ ﷺ ក្នុងដៃខ្ញុំ ﷺ ម្ខាងទៀតក៏ដោយ ក៏ខ្ញុំ ﷺ មិនឈប់ធ្វើអ្វីដែលអល់ឡោះហ៍ ﷻ បានដាក់ព្រះរាជបញ្ជា ឲ្យខ្ញុំ ﷺ ធ្វើនោះឡើយ ។"

ពួក បានី អ៊ូម៉ៃយ៉ាស្ហ៍ ដែលជាសត្រូវរបស់ ពួកបានី ហ្ហាស្ហ៊ីម ចាប់ផ្ដើមបៀតបៀនព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ ឥតស្រាក ។ បុគ្គលដែលដល់ជាងគេគឺ អាប៊ូ ស៊ុហ្វយ៉ាន (أَبُو سُفيَان), អាប៊ូ យ៉ាហ្ហាល់ (أبو جهل) និង អ៊ុតបាស្ហ៍ ប៊ិន រ៉ាប៊ីអ៊ាស្ហ៍ (عُتْبَةَ بْنِ رَبِيعَةَ) ។ ទោះបីបុគ្គលទាំងនេះមិនអាចវាយប្រហារព្រះសាស្ដា ﷺ ដោយចេញមុខបានព្រោះតែ អាប៊ូ ត៍្វលិប មានអំណាចនិងឥទ្ធិពលក៏ដោយ ពួកគាត់ឆ្លៀតយកគ្រប់ឱកាសដើម្បីបង្កបញ្ហាដាក់ព្រះអង្គ ﷺ ។

ថ្ងៃមួយ កាលព្រះសាស្ដាមូហាំម៉ាដ្ឋ ﷺ កំពុងស្ហ៍ឡាត្ហ៍ក្បែរកាក់ហ្ហ៍បាស្ហ៍ អាប៊ូ យ៉ាហ្ហាល់ និងពួកគ្ហ៍រ៉យស្ហ៍ពីរបីនាក់បានចោលពោះវៀនពពែលើស្មាព្រះអង្គ ﷺ ពេលព្រះអង្គ ﷺ កំពុងស៊ូយ៉ូដ្ហ ។ ព្រះអង្គ ﷺ បានបួងសួងអល់ឡោះហ៍ ﷻ ឲ្យដាក់

បណ្ដាសាបុគ្គលទាំងនេះ ។ ប្រវត្តិសាស្ត្របានបញ្ជាក់ប្រាប់យើងថាបុគ្គលគ្រប់រូបដែលបានចូលរួមក្នុងទង្វើនេះ រាប់ទាំង អាប៊ូ យ៉ាហ្ញាល់ និង អ៊ុតបាស់ ប៊ិន រ៉ាប៊ីអាស់ដែរ បានស្លាប់ក្នុងសមរភូមិបាដារ៍ ដែលជាសមរភូមិដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ។

ពួកអ្នកស្រុកម៉ាក់កាស់បានបែរអារម្មណ៍ទៅរកពួកមុស្លីមថ្មី ។ មុស្លីមខ្លះមានដើមកំណើតជាប្រជាជាតិដែលមានអំណាច ដូច្នេះពួកគេទាំងនេះចៀសផុតពីការលំបាក ។ ក៏ប៉ុន្តែមុស្លីមភាគច្រើនក្រីក្រឬជាបម្រើគេ ជនទាំងនេះឯងដែលរងអំពើសាហាវយង់ឃ្នងខ្លាំងជាងគេពីសំណាក់អ្នកស្រុកម៉ាក់កាស់ ។

អាប៊ូ ស្ារ៍ អាល់-គ៊ីហ្វារី (أَبُو ذَرٍّ الْغِفَارِيُّ) ជាមុស្លីមដំបូងម្នាក់ ។ កាលលោកបានប្ដេជ្ញាកាន់សាសនាអ៊ីស្លាម ពួកគូរ៉ាយ៉ស្ហ៍បានវាយលោកធ្ងន់ណាស់ស្ទើរស្លាប់ ។ ពេល អាប់បាស់ ឪពុកធំរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ បានដើរកាត់តាមនោះ ឃើញពួកគេប្រព្រឹត្តអំពើនេះ លោកបានរំលឹកពួកគូរ៉ាយ៉ស្ហ៍ថា អាប៊ូ ស្ារ៍ ជាប្រជាជាតិ បានី គ៊ីហ្វារ៍ ម្នាក់ ពួកគេរស់នៅក្បែរផ្លូវទៅមករបស់ក្បួនទូរចរជំនួញ ។ បើពួកគេដឹងថាសមាជិកណាម្នាក់របស់ពួកគេត្រូវពួកគូរ៉ាយ៉ស្ហ៍ធ្វើបាប ពួកគេច្បាស់ជានឹងមិនបណ្ដោយឲ្យក្បួនទូរចរជំនួញឆ្លងកាត់ដោយសុវត្ថិភាពជាដាច់ខាត ។ បានឮដូច្នេះ ពួកគូរ៉ាយ៉ស្ហ៍លោភលែងប៉ះពាល់ អាប៊ូ ស្ារ៍ ។

ប៊ីឡាល់ ប៊ិន រ៉ាបាស់ (بلال بن رباح) ហៅ ប៊ីឡាល់ អាល់-ហាបាស្ហ៊ី (بلال الحبشي) ជាមូអាស់ស៊ីន (مُؤَذِّنٌ អ្នកប្រកាសហៅស្ហ៍ឡាត់) របស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ ។ លោកជាបម្រើរបស់ អ៊ូម៉ៃយ៉ាស់ ប៊ិន ខ៉ុឡាហ្វ (أُمَيَّةُ بْنُ خَلَفٍ) ។ កាល ប៊ីឡាល់ ប្ដេជ្ញាកាន់សាសនាអ៊ីស្លាម ម្ចាស់ឃោរឃៅរបស់លោកក្រោធខ្លាំងណាស់ បានធ្វើបាបលោកឥតអាណិត ។ គាត់បានសម្រាតខោអាវប៊ីឡាល់ឲ្យដេកលើដីខ្សាច់ក្ដៅក្នុងវាលខ្សាច់ដោយដាក់ដុំថ្មពីទ្រូង ដើម្បីកុំឲ្យលោករត់រួចពីខ្សាច់ក្ដៅដូចភ្លើងនោះ ។ ច្រើនលើកទៀត គាត់យកខ្សែចងកប៊ីឡាល់បណ្ដើរជុំវិញទួលនៅឯម៉ាក់កាស់ ។ ទោះបីរងអំពើកាចសាហាវយ៉ាងណាក៏ដោយក៏ ប៊ីឡាល់នៅតែថា៖ "អាហាដ់ អាហាដ់" មានន័យ "អល់ឡោះហ្ ﷻ ជាព្រះមួយគត់" ។ ទីបំផុត អាប់បាស់ ឪពុកធំរបស់ព្រះសាស្ដាﷺបានទិញលោកហើយបានដោះលែងលោកឲ្យមានសេរីភាព ។

លូប៊ីណាស់ ខ៉ុទូន ជាស្រីបម្រើរបស់ អ៊ូម៉ារ ប៊ិន ខ៉ុត្តាប់ ដែលបានទៅជា

ខ្ញុំលិហ្វទីពីរក្រោយមក ។ កាលលូបីណាសុំបានទៅជាស្ត្រីមុស្លីម អ៊ុម៉ារបានវាយគាត់ទាល់តែហត់ខ្លួនឯង ។

អាំម៉ារ ប៊ិន យ៉ាសៀរ (عَمَّارَ اِبْنَ يَاسِرٍ) និងឪពុកម្តាយលោកឈ្មោះ យ៉ាសៀរ និង ស៊ូម៉ៃយ៉ាស់ (سُمَيَّة) នៅក្នុងចំណោមបុគ្គលដែលបានចូលសាសនាអ៊ីស្លាមមុនគេបង្អស់ ។ ពួកកាហ្វៀរបានបង្ខំឲ្យលោកទាំងបីនាក់ប្តូរសាសនាតែលោកបដិសេធ ។ ពួកវាបាននាំខ្លួនលោកទាំងបីទៅវាយនិងធ្វើបាបនៅឯវាលខ្សាច់ ។ លោកយ៉ាសៀរបានទទួលអនិច្ចកម្មក្រោយពីបានរងទារុណកម្មច្រើនលើក ។ ស៊ូម៉ៃយ៉ាស់ ភរិយាលោកដែលមានផ្ទៃពោះ បានទៅប្តឹង អាប៊ូ យ៉ាហ្ហាល់ អំពីអំពើអមុស្សធម៌នេះ អាប៊ូ យ៉ាហ្ហាល់ បានយកលំពែងចាក់ប្រហារលោកស្រីស៊ូម៉ៃយ៉ាស់ចំកណ្តាលបេះដូង ។ បន្ទាប់ពីនោះ អាប៊ូ យ៉ាហ្ហាល់ បានវាយអាំម៉ាររិះនឹងស្លាប់ ។ ដើម្បីចាកផុតពីសេចក្តីស្លាប់ អាំម៉ារ ចាំបាច់ត្រូវបង្ខំចិត្តព្រមធ្វើតាមពួកកាហ្វៀរ ។ ក្រោយមក ព្រះសាស្តាមូហាំម៉ាដ់ﷺបានយល់ស្របនឹងទង្វើរបស់លោកអាំម៉ារ ដោយមានព្រះវចនៈថា ដរាបណាអាំម៉ារមានជំនឿស្មោះនៅក្នុងចិត្ត ដរាបនោះលោកមិនមានកំហុសទេ ដែលត្រូវគេបង្ខំឲ្យថានោះ ។ ទោះបីរងទុក្ខវេទនាធ្ងន់យ៉ាងណាក៏ដោយ ក៏ពុំមានមុស្លីមណាមួយបានដូរជំនឿរបស់ខ្លួនឡើយ កាន់តែមានចំនួនច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. អ្នកណាជាស្ត្រីរងទុក្ករៈកម្មមុនគេបង្អស់ ?

២. ហេតុអ្វីពួកគូរ៉យស្ធ្វើបាបពួកមុស្លីមទន់ខ្សោយ ?

៣. ប៊ីឡាល់សូត្រថាអ្វីកាលត្រូវគេធ្វើទារុណកម្ម ?

៤. ពួកគូរ៉យស្ឲ្យអ្វីព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلم ដើម្បីនឹងឲ្យព្រះអង្គصلى الله عليه وآله وسلمឈប់ផ្សាយសាសនា ?

៥. ព្រះវចនៈដ៏ល្បីល្បាញរបស់ព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمគឺអ្វី ?

## មេរៀនទី ៥

# ហ៊ិចរ៉ោះត៍ទៅកាន់អាប៊ីស៊ីនី

ពួកទមិឡឥតសាសនាស្រុកម៉ាក់កាស់ ធ្វើឲ្យពួកមុស្លីមពិបាករស់នៅខ្លាំងណាស់ ។ ព្រះសាស្ដាមូហាំម៉ាដ់ﷺបារម្ភនិងខ្វល់ខ្វាយអំពីស្ថានភាពពួកមុស្លីមណាស់ ដូច្នេះព្រះអង្គﷺបានណែនាំឲ្យបក្សពួកព្រះអង្គﷺមួយក្រុមភៀសខ្លួនទៅកាន់ដែនដីអាប៊ីស៊ីនី (គឺប្រទេសអេត្យូពី) ដែលមានស្ដេចគ្រិស្តសាសនិកស្លូតត្រង់មួយអង្គសោយរាជ្យ មាននាមថា ណាយ៉ាស្ស៊ី (نَجَاشِيّ ឬ Negus នេគុស) ។

នេះគឺហ៊ិចរ៉ោះត៍ (ការភៀសខ្លួន) ដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម មានមនុស្ស ១០ នាក់ចូលរួមក្នុងការភៀសខ្លួននេះ ។ ព្រឹត្តិការណ៍នេះបានកើតឡើងក្នុងឆ្នាំទី ៥ នៃសាស្ដាភាព ។

ក្រុមមុស្លីមទីពីរដែលមានចំនួនច្រើនជាងមុនបានភៀសខ្លួនដែរ ក្រោយមកបន្តិច ក្រោមការដឹកនាំរបស់ យ៉ាក់ហ្វារ ប៊ិន អាប៊ូ ត៏លិប បងប្រុសរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ។ គេបានទទួលពួកមុស្លីមនៅឯដែនដីអាប៊ីស៊ីនីដោយមនុស្សធម៌ ជីវភាពរស់នៅទីនេះប្រកបដោយសេចក្ដីសុខសាន្ត ។ ពេលពួកមេដឹកនាំម៉ាក់កាស់បានដំណឹងថាពួកមុស្លីមបានភៀសខ្លួនទៅរស់នៅឯដែនដីអាប៊ីស៊ីនីដោយសន្តិសុខ ពួកគេខ្លាចពួកមុស្លីមទាក់ទាញស្ដេចណាយ៉ាស្ស៊ីឲ្យចូលសាសនាអ៊ីស្លាម ។ ពួកគេបាននាំយកអំណោយទៅថ្វាយស្ដេចនិងមន្ត្រីស្ដេច ខិតខំនិយាយញុះញង់ឲ្យបញ្ជូនពួកមុស្លីមត្រឡប់ទៅម៉ាក់កាស់វិញ ។ ពួកមេដឹកនាំបានចាត់បញ្ជូនបុរសពីរនាក់ទៅរកពួកមុស្លីម ។ លុះបុរសទាំងពីរបានទៅដល់ដែនដីអាប៊ីស៊ីនី ពួកគេបានជួបពួកមន្ត្រីមុនគេ បានជូនអំណោយដ៏មានតម្លៃ ។ ពួកគេបាននិយាយញុះញង់ពួកមន្ត្រីលោភលន់ឲ្យគាំទ្របេសកកម្មខ្លួនដោយជួយជ្រោមជ្រែងខ្លួននៅឯរាជវាំង ។

ស្អែកឡើង ពួកគេបានចូលគាល់ស្ដេចណាយ៉ាស្ស៊ី បន្ទាប់ពីបានថ្វាយសួយសារអាករពួកគេបានទូលថា៖ "យុវជនប្រជាជាតិអស់ទូលបង្គំមួយក្រុមបានប្រព្រឹត្តខុសគន្លងជំនឿរបស់ដូនតាអស់ទូលបង្គំ ដោយបានប្រឌិតឡើងនូវសាសនាថ្មីមួយ ។ បុគ្គលទាំងនេះគេចខ្លួនមកស្នាក់នៅឯនគរព្រះអង្គ ។ ទូលបង្គំសូមព្រះអង្គ

ប្រគល់ខ្លួនពួកគេឲ្យមកអស់ទូលបង្គំវិញ ដើម្បីនាំពួកគេទៅដែនដីអារ៉ាប៊ីវិញ ។" និយាយចប់ ពួកមន្ត្រីលោភលន់បានទូលស្តេចថាពួកគេយល់ស្របនឹងសំណូមនេះ ។ ប៉ុន្តែស្តេចណាយ៉ាស្ទីមិនយកចិត្តទុកដាក់ទេ ដោយសួរថាតើពួកជនភៀសខ្លួនមុស្លីមទាំងនោះបានសម្លាប់គេទេ បានលួចប្លន់ទ្រព្យគេទេ ឬបានប្រព្រឹត្តបទខុសច្បាប់ណាមួយទេនៅឯម៉ាក់កាស៊ូ ។ ពួកគេបានតបវិញថាបទខុសច្បាប់តែមួយ



របស់ពួកគេនោះ គឺប្រឌិតឡើង នូវសាសនាថ្មីមួយ ។ ស្តេចបានប្រកាសថា៖ "ខ្ញុំមិនអាចប្រគល់ខ្លួន បណ្តាអ្នកដែលនៅក្រោម អាណាព្យាបាលខ្ញុំ ដោយគ្មានការស៊ើបអង្កេត បានទេ ។" ស្តេចបានហៅ អ្នកដឹកនាំពួកមុស្លីមមកជួប នៅឯរាជវាំង ។ យ៉ាក់ហ្វារ ប៊ិន អាប៊ូ ត៍លិប បានឆ្លើយតបការអញ្ជើញដើម្បីអធិប្បាយបំភ្លឺរឿងពួកមុស្លីម ។ ស្តេចបានបែរទៅរកយ៉ាក់ហ្វារ សួរថា៖ "ហេតុអ្វីអស់លោកបានបោះបង់ចោលជំនឿរបស់ដូនតាអស់លោក ទៅជឿសាសនាថ្មី ?" យ៉ាក់ហ្វារបានតបថា៖ "កាលពីមុនអស់ទូលបង្គំជាមនុស្សអវិជ្ជាដែលធ្វើសក្ការៈរូបព្រះ បរិភោគសាកសពនិងប្រព្រឹត្តទង្វើអាក្រក់ ។ អស់ទូលបង្គំមិនគោរពអ្នកជិតខាងទេ វាយប្រតប់គ្នាឯង ។ អ្នកទន់ខ្សោយ អ្នកឥតអំណាចត្រូវអ្នកមានអំណាចជិះជាន់ ធ្វើបាប ។ អស់ទូលបង្គំបានរស់នៅបែបនេះដ៏យូរហូតដល់មានបុគ្គលម្នាក់នៅក្នុងចំណោមអស់ទូលបង្គំ ដែលមានចរិយាមារយាទសុក្រឹតឥតខ្ចោះ បានហៅអស់ទូលបង្គំមកធ្វើសក្ការៈព្រះតែមួយគត់ ។ បុគ្គលសុក្រឹតឥតខ្ចោះនោះបានបង្គាប់អស់ទូលបង្គំឲ្យចេះគោរពអ្នកដទៃ ឲ្យចេះប្រព្រឹត្តខ្លួនត្រឹមត្រូវជាមួយញាតិ ឲ្យចេះគោរពអ្នកជិតខាងនិងបណ្តាស្ត្រីនិងឲ្យចៀសវាងនិយាយកុហក ។ បុគ្គលសុក្រឹតឥតខ្ចោះនោះដាក់បញ្ញាឲ្យអស់ទូលបង្គំធ្វើសក្ការៈថ្វាយបង្គំព្រះតែមួយគត់ ឲ្យកាន់សីលត្រណម ឲ្យបង់ពន្ធសាសនាលើទ្រព្យសម្បត្តិរបស់អស់ទូលបង្គំ ។ អស់ទូលបង្គំជឿ

បុគ្គលសុក្រឹតឥតខ្ចោះនោះនិងគោរពបូជាអល់ឡោះហ៍ عَزَّ وَجَلَّ ។ តែពួកគូរ៉យ៉ស្ស៍ប្រព្រឹត្តអំពើកាចសាហាវចំពោះអស់ទូលបង្គំ ។ អស់ទូលបង្គំបានស៊ូទ្រាំមួយរយៈពេល តែពេលនេះអស់ទូលបង្គំមកកាន់ទីនេះដើម្បីការពារជំនឿរបស់អស់ទូលបង្គំ ។ អស់ទូលបង្គំបានឮថាព្រះអង្គមានមេត្តាសន្ដោស ដូច្នេះអស់ទូលបង្គំបានមកកាន់នគរព្រះអង្គ និងជឿជាក់ទាំងស្រុងថាព្រះអង្គមិនខ្វះយុត្តិធម៌ជាដាច់ខាត ។" ស្ដេចស្ញើចវោហារយ៉ាក់ហ្វារណាស់ បានសូមឲ្យសូត្រពាក្យពេជន៍ឧត្ដុង្គឧត្ដមនៅក្នុងព្រះគម្ពីររបស់ពួកមុស្លីម ។ យ៉ាក់ហ្វារបានសូត្រនិងបានធ្វើអធិប្បាយអាយ៉ាស់ខ្លះក្នុងស៊ូរ៉េះត៍ម៉ារយ៉ាំនៃព្រះគម្ពីរគួរអាន ។ ពេលបានឮព្រះបន្ទូលអល់ឡោះហ៍ عَزَّ وَجَلَّ ថ្លែងអំពីព្រះគុណសម្បត្តិរបស់ព្រះនាងម៉ារយ៉ាំ عليها السلام និងព្រះសាស្ដាអ៊ីសា عليه السلام ស្ដេចនិងពួកមេសាសនាគ្រិស្តស្រក់ទឹកភ្នែក ទទួលស្គាល់ការពិត ។ ស្ដេចណាយ៉ាស្ស៊ីបានប្រកាសថានឹងមិនប្រគល់ខ្លួនពួកមុស្លីមឲ្យទៅពួកគូរ៉យ៉ស្ស៍ជាដាច់ខាត ហើយបានឲ្យពួកគេគូរ៉យ៉ស្ស៍ចាកចេញពីរាជវាំង ។

បុរសស្រុកម៉ាក់កាស់ម្នាក់ ដែលជាបុរសមានក្រឡេចច្រើនយ៉ាង សាកប្រើល្បិចផ្សេង ។ គាត់ដឹងថាពួកគ្រិស្តសាសនិកជឿថាព្រះសាស្ដាអ៊ីសា عليه السلام ជាកូនរបស់ព្រះ ។ ថ្ងៃបន្ទាប់គាត់ទៅជួបស្ដេច ទូលថាពួកមុស្លីមមានជំនឿផ្សេងពីបណ្ដាអ្នកកាន់សាសនាគ្រិស្តអំពីព្រះសាស្ដាអ៊ីសា عليه السلام អាស្រ័យហេតុនេះពួកមុស្លីមជាគ្រោះថ្នាក់សម្រាប់សាសនាផ្លូវការរបស់ដែនដីអាប៊ីស៊ីនី ។ ស្ដេចណាយ៉ាស្ស៊ីហៅយ៉ាក់ហ្វារមកជួបវិញ សួរលោកថាតើពួកមុស្លីមយល់ឃើញយ៉ាងណាអំពីព្រះសាស្ដាអ៊ីសា عليه السلام ។ យ៉ាក់ហ្វារបានតបវិញថា៖ "ជំនឿរបស់អស់ទូលបង្គំអំពីអ៊ីសា عليه السلام ជាជំនឿតែមួយ ដែលព្រះសាស្ដាមូហាំម៉ាដ់ ﷺ របស់អស់ទូលបង្គំបានប្រាប់អស់ទូលបង្គំ ។ អ៊ីសា عليه السلام ជាបាវបម្រើនិងជាព្រះសាស្ដារបស់អល់ឡោះហ៍ عَزَّ وَجَلَّ ព្រះអង្គ عليه السلام ជាព្រះវិញ្ញាណរបស់អល់ឡោះហ៍ عَزَّ وَجَلَّ ដែលអល់ឡោះហ៍ عَزَّ وَجَلَّ បានព្រះរាជទានឲ្យមកព្រះនាងម៉ារយ៉ាំ عليها السلام ។" ចម្លើយនេះបានធ្វើឲ្យស្ដេចពេញចិត្ត ព្រះអង្គបានសរសើរជំនឿរបស់ពួកមុស្លីម បានអនុញ្ញាតឲ្យពួកមុស្លីមអាចប្រតិបត្តិសាសនាខ្លួនបាននៅក្នុងដែនដីព្រះអង្គ ។ ស្ដេចបានប្រគល់សួយសារអាករឲ្យទៅពួកគូរ៉យ៉ស្ស៍វិញ ថា៖ "ព្រះបានប្រគល់ឲ្យខ្ញុំនូវអំណាចគ្រប់គ្រងលើប្រជារាស្ត្រខ្ញុំដោយមិនសូមអ្វីវិញឡើយ ។ ទទួលសំណូកដើម្បីបង្កើនទ្រព្យសម្បត្តិនោះមិនត្រឹមត្រូវទេ ។ បុរស

ទាំងពីរនាក់ពុំមានជម្រើសផ្សេងពីត្រឡប់ទៅម៉ាក់កាស៊ូវិញទេ ដោយទទួលបរាជ័យក្នុងការសាកល្បងនាំខ្លួនពួកមុស្លីមទៅស្រុកវិញ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺះ

១. មានមនុស្សប៉ុន្មាននាក់ភៀសខ្លួនទៅកាន់ដែនដីអាប៊ីស៊ីនី ?

២. ហេតុអ្វីពួកគូរ៉យស្ស៍បានចាត់បញ្ជូនបេសកជនពីរនាក់ ទៅកាន់ដែនដីអាប៊ីស៊ីនី ?

៣. អ្នកណាជាមេដឹកនាំពួកមុស្លីម ?

៤. មធ្យោបាយពីរដែលពួកម៉ាក់កាស្វ៍បានប្រើ ដើម្បីធ្វើឲ្យស្តេចណាយ៉ាស្ស៊ីបដិសេធពួកមុស្លីមនោះជាមធ្យោបាយអ្វី ?

## មេរៀនទី ៦

# ពហិការលើ បានី ហាស៊្ហឹម

ពួកមេដឹកនាំពួកគូរ៉យ់ស្ហ៍មានសេចក្តីទោមនស្សអនេក ដែលឃើញសាសនាអ៊ីស្លាមរីកសាយសុស ទោះបីខ្លួនព្យាយាមបង្ក្រាបឥតសំចៃកម្លាំងក៏ដោយ ។ ពេលនេះបុគ្គលប្រកបដោយប្រិយភាពដែលមនុស្សគោរពដូចជា ហ៊ាំស្ហាស្ហ៍ ឪពុកធំរបស់ព្រះសាស្តាមូហ៊ាំម៉ាដ្ហ៍ﷺ និងបុគ្គលមានអំណាចមួយចំនួនទៀតក្នុងចំណោមពួកគូរ៉យ់ស្ហ៍ជាដើមបានទៅជាមុស្លីម ។ ពួកមេដឹកនាំមិនអាចទ្រាំមើលសាសនាអ៊ីស្លាមបោះជំហានទៅមុខបែបនេះបានទេ ។ ដូច្នេះពួកគេបានរៀបចំការប្រជុំដើម្បីរកមធ្យោបាយទប់ស្កាត់សាសនាអ៊ីស្លាម ។ ពួកគេបានសម្រេចចិត្តធ្វើពហិការ (គឺដាក់បម្រាម) លើពួកមុស្លីមទាំងអស់ ធ្វើបែបនេះពួកគេនឹងអាចបង្អាក់ចលនាពួកមុស្លីមបាន ។

ពួកមេដឹកនាំបានមូលមតិគ្នាធ្វើកិច្ចព្រមព្រៀងមួយ បានបិទប្រកាសកិច្ចព្រមព្រៀងនេះលើជញ្ជាំងកាក់បាស្ហ៍ សហាគមន៍គូរ៉យ់ស្ហ៍ត្រូវតែអនុវត្តិតាមកិច្ចព្រមព្រៀងនេះ ។ ខនៃកិច្ចព្រមព្រៀងនេះមានដូចតទៅគឺៈ

១. ការធ្វើជំនួញនិងធុរកិច្ចជាមួយបណ្តាអ្នកគាំទ្រមូហ៊ាំម៉ាដ្ហ៍ﷺត្រូវហាម ។

២. ធ្វើសហាការឬចូលរួម ដោយរបៀបណាមួយក៏ដោយ ជាមួយបណ្តាអ្នកគាំទ្រមូហ៊ាំម៉ាដ្ហ៍ﷺ ត្រូវហាមផ្តាច់ ។

៣. មិនអនុញ្ញាតឲ្យអ្នកណាមួយរៀបការកូនស្រីឬកូនប្រុស ជាមួយកូនប្រុសឬកូនស្រីរបស់ពួកមុស្លីមទេ ។

៤. អ្នកណាដែលប្រឆាំងមូហ៊ាំម៉ាដ្ហ៍ﷺ នឹងបានទទួលការគាំទ្រគ្រប់ប្រការ ។

ពួកមេដឹកនាំគូរ៉យ់ស្ហ៍ទាំងអស់ បានចុះហត្ថលេខាយល់ព្រមកិច្ចព្រមព្រៀងនេះហើយដាក់ឲ្យអនុវត្តិភ្លាម ។ អាប៊ូ ត៉ុលិបបានសន្យាក្នុយﷺលោកថា ប្រជាជាតិបានី ហាស្ហ៊ឹម ទាំងអស់នឹងគាំទ្រព្រះអង្គﷺ ។ អាប៊ូ ត៉ុលិបបានណែនាំពួកមុស្លីមដែរឲ្យចាកចេញពីម៉ាក់កាស្ហ៍ ទៅកាន់ជ្រលងភ្នំ ។ ដូច្នេះ ពួកមុស្លីមក៏បានចាក

ចោលលំនៅដ្ឋាន ទៅកាន់កន្លែងមួយដែលគេហៅថា "ជ្រលងអាប៊ូ ត៉ូលិប" បានសាងសង់ផ្ទះនិងជំរំតូចៗនៅទីនោះ ។

ដើម្បីការពារខ្លួនពីការវាយឆ្មក់របស់ពួកគូរ៉យស៊្ហ អ្នកខ្លះបានឃាមល្បាត ។ ពួកមុស្លីមត្រូវបង្ខំឲ្យរស់នៅឯជ្រលងភ្នំនេះបីឆ្នាំ ។ ពួកគេរងទុក្ខវេទនាខ្លាំងក្នុងអំឡុងពេលនេះ ។ ក្រស្បៀង ភាគច្រើនរស់នៅយ៉ាងលំបាកដោយមានតែផ្លែលម៉ើមួយគ្រាប់ឬតិចជាងនេះជាអាហារប្រចាំថ្ងៃ ។ ប្រជាជាតិ បានី ហ្វាស្ហ៊ីម ត្រូវអនុញ្ញាតឲ្យចេញពីជ្រលងភ្នំបានតែក្នុងខែរ៉យ៉ាប់និងខែស៊ុល ហ៊ីជ្ជយ៉ាស្ហ៊ុទេ ព្រោះការប្រយុទ្ធត្រូវហាមផ្តាច់ក្នុងខែទាំងពីរនេះ ។ ក្នុងអំឡុងខែទាំងពីរនេះ ពួកគេមកម៉ាក់កាស្ហ៊ុដើម្បីទិញស្បៀងនិងគ្រឿងប្រើប្រាស់ចាំបាច់ ។ តែពួកអ្នកស្រុកម៉ាក់កាស្ហ៊ុខ្លះ ដូចជា អាប៊ូ ឡាហ្វាប់ ជាដើមបានធ្វើឲ្យពួកមុស្លីមរងការលំបាករឹតតែខ្លាំងឡើងដោយញុះញង់ឈ្មួញឲ្យដំឡើងថ្លៃស្បៀង កុំឲ្យពួកមុស្លីមមានលទ្ធភាពទិញបានច្រើន ។ ក្នុងកាលៈទេសៈលំបាកនេះ ពួកមុស្លីមមិនបាត់បង់ជំនឿទេ តោងសាសនាអ៊ីស្លាមនិងព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ យ៉ាងខ្ជាប់ខ្ជួន ។ ទីបំផុត អ្នកស្រុកម៉ាក់កាស្ហ៊ុខ្លះនឹកស្តាយក្រោយ ដែលបានប្រព្រឹត្តចំពោះពួកមុស្លីមនូវអំពើគួរឲ្យអៀនខ្មាស ពីព្រោះទោះជាយ៉ាងណាក៏ដោយ ពួកគេជាប់សាច់ញាតិជាមួយខ្លួនដែរ ។ ពួកគេខ្មាសខ្លួនឯងដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះ ហើយបានស្វែងរកដំណោះស្រាយបញ្ហានេះ ។ ពួកគេបានចាត់ចែងឲ្យមានការប្រជុំពួកគូរ៉យស្ហ៊ ស្នើសូមឲ្យបញ្ចប់ពហិការ ដើម្បីអនុញ្ញាតឲ្យពួកមុស្លីមត្រឡប់មកកាន់ស្រុកវិញបាន ។

ទោះបី អាប៊ូ យ៉ាហ្វាល់ មិនយល់ព្រមឲ្យពួកគេត្រឡប់មកវិញក៏ដោយ តែគាត់ត្រូវសមាជិកឯទៀតនៃប្រជាជាតិបង្ខំឲ្យស្ងាត់មាត់ ឥតជម្រើស ។ ពួកមេដឹកនាំបានសម្រេចចិត្តបកលិខិតប្រកាសកិច្ចព្រមព្រៀង នៅលើជញ្ជាំងកាក់ប៉ាស្ហ៊ុចោល ។ ពេលបកចោលលិខិតប្រកាសនោះ ពួកគេបានឃើញថាសន្លឹកក្រដាសត្រូវកណ្តៀរស៊ីអស់នៅសល់តែពាក្យថា "ក្នុងព្រះនាមព្រះជាម្ចាស់យើង" ។

ក្រោយពី អាប៊ូ ត៉ូលិប ឪពុកធំរបស់ព្រះអង្គ ﷺ បានប្រាប់ឲ្យដឹងការប្រែប្រួលព្រះសាស្តាមូហ៊ាំម៉ាដ្ឋ ﷺ បានសម្រេចចិត្តចាកចេញពីជ្រលងភ្នំ ពួកមុស្លីមក៏បានវិលត្រឡប់មកកាន់ម៉ាក់កាស្ហ៊ុ មាតុភូមខ្លួនវិញ សាថ្មីម្តងទៀត ។

អំណាត់និងទំនុកចិត្តលើអល់ឡោះហ្ ﷻ របស់បណ្ដាមុស្លីមដំបូងនេះ ដែលបានរងទុក្ខវេទនានោះ ជាមេរៀនសំខាន់សម្រាប់យើងរាល់គ្នា ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ហេតុអ្វីពួកមុស្លីមនៅឯម៉ាក់កាស្ទូត្រូវនិរទេស ?

២. ពួកគេបានរស់នៅឯណាអស់រយៈពេល ៣ ឆ្នាំ ?

៣. អាប៊ូ ឡាហ្វាប់ខំធ្វើឲ្យពួកមុស្លីមរឹតតែលំបាកខ្លាំងឡើងដោយវិធីណា ?

៤. ពួកមុស្លីមអាចត្រឡប់មកកាន់មាតុភូមិវិញបានដូចម្ដេច ?

៥. តើគេអាចដកស្រង់បាននូវមេរៀនអ្វីពីព្រឹត្តិការណ៍នេះ ?

## មេរៀនទី ៧

# អាប៊ូ ត៏លិបនិងព្រះនាងខ៏ឌីយ៉ាស់ទទួលអនិច្ចកម្ម

បន្ទាប់ពីពហិរការលើពួកមុស្លីមត្រូវលើកចោល ពួកមុស្លីមបានវិលត្រឡប់មកកាន់ជីវិតដើមវិញឯម៉ាក់កាស់។ ក្រោយបីឆ្នាំដ៏លំបាក ពួកគេគិតថាស្ថានភាពជីវិតនឹងប្រសើរឡើង។ ប៉ុន្តែព្រឹត្តិការណ៍ខ្លះបានកើតឡើងក្នុងឆ្នាំនោះ បណ្តាលឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺសោយទុក្ខជាទីបំផុត ពួកមុស្លីមរំលែកទុក្ខព្រះអង្គﷺដែរ។

ក្នុងឆ្នាំនេះ ដំបូងព្រះសាស្តាមូហាំម៉ាដ់ﷺបានបាត់បង់ អាប៊ូ ត៏លិប ឪពុកធំព្រះអង្គﷺ បន្ទាប់មកព្រះអង្គﷺបានបាត់បង់ព្រះនាងខ៏ឌីយ៉ាស់ មហេសីព្រះអង្គﷺ មួយខែក្រោយមក។ ទុក្ខសោកព្រះអង្គﷺពុំមានព្រំដែនឡើយ ព្រះអង្គﷺហៅឆ្នាំនេះថា "អ៊ាមុល-ហ៊ុស្និ" ឆ្នាំសោកសង្រេង។

អាប៊ូ ត៏លិប ធ្លាប់ជាបង្អែកនិងជាអ្នកការពារព្រះសាស្តាﷺចាប់តាំងពីពេលអាប់ឌុល-មុត្តត៏លិប ជីតាព្រះអង្គﷺ ស្លាប់មក។ លោកបានមើលថែរក្សាព្រះអង្គﷺប្រសើរជាងកូនបង្កើតទៅទៀត។ ដើម្បីការពារព្រះសាស្តាﷺពីការលួចធ្វើឃាតពីសំណាក់សត្រូវព្រះអង្គﷺ អាប៊ូ ត៏លិប តែងតែឲ្យកូនប្រុសលោកម្នាក់ ជាធម្មតាអ៊ីម៉ាំអាលីصلوات الله عليه والسلام ដេកលើគ្រែព្រះសាស្តាﷺ។

អាប៊ូ ត៏លិប ជឿជាក់លើសុក្រឹតភាពរបស់ក្មួយﷺលោក ព្រោះលោកតែងតែបួងសួងសូមព្រះពរពីអល់ឡោះហ៍عزّوجلّដោយប្រើព្រះនាមរបស់ព្រះភាតុបុត្តﷺ (ក្មួយប្រុសខាងបងប្រុសឬប្អូនប្រុស) របស់លោក។

ថ្ងៃមួយ កាលពួកគួរ៉ាយស្ហ៍ជួបប្រទះការរាំងស្ងួតគួរឲ្យខ្លាច ពួកគេបានមករកអាប៊ូ ត៏លិប អង្វរលោកឲ្យបួងសួងសូមភ្លៀង។ អាប៊ូ ត៏លិបបានលើកដៃព្រះសាស្តាមូហាំម៉ាដ់ﷺ កាលនោះព្រះអង្គﷺនៅកុមារភាពនៅឡើយ ហើយលោកបានងើយមុខទៅឯមេឃដោយពោលថាៈ "ព្រះជាម្ចាស់عزّوجلّអើយ សូមព្រះអង្គعزّوجلّប្រទានទឹកភ្លៀងក្នុងនាមនៃសេចក្តីស្រឡាញ់ក្មេងប្រុសនេះ សូមព្រះអង្គعزّوجلّប្រទានព្រះពរឲ្យអស់ទូលព្រះបង្គំជាខ្ញុំផង។" បួងសួងស្ទើរតែមិនទាន់ចប់ផងស្រាប់តែភ្លៀងធ្លាក់ដូចបាក់មេឃ។

ពេលព្រះសាស្តាមូហាំម៉ាដ់ﷺធំ អាប៊ូ ត៏លិប ឲ្យព្រះអង្គﷺចូលរួមក្នុងមុខរបរជំនួញតាមក្បួនទូរចរ ដូច្នេះព្រះអង្គﷺទទួលបាននូវបទពិសោធន៍ក្នុងការដោះដូរទៅវិញទៅមកជាមួយមនុស្សទូទៅ ។ ពេលព្រះអង្គﷺមានព្រះជន្ម ២៥ ឆ្នាំ អាប៊ូ ត៏លិប បានរៀបចំការស្តីដណ្តឹងព្រះនាងខ៏ឌីយ៉ាស់ﷺឲ្យព្រះអង្គﷺ ។ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ លោកប្រកាសឧត្តមភាពរបស់ព្រះភាតុបុត្តﷺរបស់លោកលើសអស់យុវជនឯទៀត លោកបានសូត្រឃុត្តបាស់នីកាស់ដោយខ្លួនឯងផ្ទាល់តែម្តង ។

កាលព្រះសាស្តាមូហាំម៉ាដ់ﷺបានបើកឲ្យដឹង ថាព្រះអង្គﷺជាព្រះសាស្តារបស់អល់ឡោះហ្ ﷻ អាប៊ូ ត៏លិប ជឿព្រះអង្គﷺ នៅខាងព្រះអង្គﷺដោយស្មោះមិនគេចវេះការពារព្រះភាតុបុត្តﷺលោកឡើយ ។ ទោះបី អាប៊ូ ត៏លិប អន់ថយអំណាចក្នុងចំណោមពួកគូរ៉យ៉ស្ក៏ដោយ ព្រោះតែលោកគាំទ្រព្រះភាតុបុត្តﷺលោក លោកមិនដែលគិតសូមឲ្យព្រះអង្គﷺបំបិទព្រះរាជសារអ៊ីស្លាមឡើយ ។

ទង្វើទាំងឡាយរបស់ អាប៊ូ ត៏លិប អស់មួយជីវិតលោក បញ្ជាក់ឲ្យដឹងថាលោកជាមុស្លីមដែលជឿព្រះសាសនាអល់ឡោះហ្ ﷻ ។ បុគ្គលខ្លះបានចោទលោកថាជាទមិឡផតសាសនា (កាហ្វៀរ) តែភ័ស្តុតាងដូចតទៅនេះសឲ្យឃើញថាសម្តីនេះខុសស្រឡះពីការពិត ។

ស្ត្រីមុស្លីមមិនអាចរស់នៅជាប់ ដោយរៀបការជាមួយបុរសផតសាសនាបានទេ ។ ការពិតក្នុងប្រវត្តិសាស្ត្រអ៊ីស្លាមបានបង្ហាញថាសៃយីដាស់ ហ្វាទី៏ម៉ាស់ ប៊ិនទីអាសាដ់ នៅក្នុងចំណោមស្ត្រីដែលបានចូលសាសនាអ៊ីស្លាមមុនគេ ថាព្រះនាងជាឧត្តមភរិយារបស់ អាប៊ូ ត៏លិប ហើយបាននៅជាប់ជាភរិយាលោករហូតលុះស្លាប់ ។ ប្រសិនបើ អាប៊ូ ត៏លិប មិនមែនមុស្លីមទេ ច្បាប់អ៊ីស្លាមមិនអនុញ្ញាតឲ្យព្រះនាងរស់នៅជាភរិយាលោកទេ ។

មិនប្លែកទេ ដែលព្រះសាស្តាមូហាំម៉ាដ់ﷺនឹកស្រណោះអាល័យឪពុកធំព្រះអង្គﷺជាទីបំផុតនោះ ។ អាប៊ូ ត៏លិប ជាអាណាព្យាបាលព្រះអង្គﷺអស់រយៈពេលជិត ៥០ ឆ្នាំ ។

ក្នុងឆ្នាំតែមួយព្រះសាស្តាមូហាំម៉ាដ់ﷺបានបាត់បង់ ព្រះមហេសីជាទីស្រឡាញ់ ព្រះនាងខ៏ឌីយ៉ាស់ﷺ ព្រះមាតារបស់ព្រះរាជបុត្រីជាទីស្រឡាញ់របស់

ព្រះអង្គ صلى الله عليه وآله وسلم ព្រះនាង ហ្វាទីម៉ាស់ សុាស់រ៉អ៊ុ سلام الله عليها ។ ព្រះនាងខ៉ឌីយ៉ាស់ سلام الله عليها ជាស្ត្រីមានទ្រព្យសម្បត្តិជាងគេនៃដែនដីអារ៉ាប៊ី  កាលព្រះនាង سلام الله عليها រៀបអាពាហ៍ពិពាហ៍ជាមួយព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ព្រះនាងអាយុ ៤០ ឆ្នាំ ។ កាលព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានបើកឲ្យដឹងថាព្រះអង្គ صلى الله عليه وآله وسلم ជាព្រះសាស្តារបស់អល់ឡោះហ៍ عز وجل ១៥ ឆ្នាំក្រោយពីនោះ  ព្រះនាង سلام الله عليها ជាស្ត្រីដំបូងបង្អស់ដែលជឿព្រះអង្គ صلى الله عليه وآله وسلم និងទទួលយកសាសនាអ៊ីស្លាមជាសាសនាខ្លួន ។ ចាប់តាំងពីពេលនេះតទៅ ព្រះនាង سلام الله عليها បានបរិច្ចាគទ្រព្យទាំងអស់ដើម្បីបម្រើផលប្រយោជន៍អ៊ីស្លាម ។  ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានប្រើទ្រព្យព្រះនាង سلام الله عليها សម្រាប់ផ្សាយសាសនា  និងសម្រាប់ទិញសិរីភាពរបស់ជនបម្រើគេច្រើននាក់ដែលបានទៅជាមុស្លីម ។

ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم នឹកឃើញសម្តីព្រះនាង سلام الله عليها ជានិច្ច ដែលជាសាក្សីថាព្រះនាង سلام الله عليها ជឿព្រះរាជសាររបស់ព្រះអង្គ صلى الله عليه وآله وسلم  ចំណែកឯមនុស្សនៅជុំវិញខ្លួនព្រះអង្គ صلى الله عليه وآله وسلم ចោទព្រះអង្គ صلى الله عليه وآله وسلم ថានិយាយកុហក ។

សោកនាដកម្មទាំងពីរនេះជាការទង្គិចទង្គើខ្លាំងបំផុត  សម្រាប់ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم  នៅក្នុងកាលៈទេសៈមួយដែលព្រះអង្គ صلى الله عليه وآله وسلم ត្រូវការការលើកទឹកចិត្តនិងការគាំទ្រពីសំណាក់បុគ្គលជាទីស្រឡាញ់របស់ព្រះអង្គ صلى الله عليه وآله وسلم ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺហៅឆ្នាំនេះថា "អ៊ាមុល-ហ៊ុស្សនី" ?

២. ពេលសោយទិវង្គត តើព្រះនាងខ៏ឌីយ៉ាស់ﷺមានព្រះជន្មប៉ុន្មានឆ្នាំ ?

៣. តើព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រើប្រាស់ទ្រព្យរបស់ព្រះនាងﷺ ដូចម្តេង ?

៤. ហេតុអ្វីព្រះអង្គﷺនឹករលឹកព្រះនាងﷺជានិច្ច ?

៥. អាប៊ូ ត៉ូលិប បានការពារព្រះសាស្តាមូហាំម៉ាដ់ﷺដូចម្តេចកាលព្រះអង្គﷺនៅកុមារភាព ?

## មេរៀនទី ៨

# ព្រះអារោហ (មិអ៏រ៉ច់) របស់ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ

មិអ៏រ៉ច់ (الْمِعْرَاج) មានន័យជាភាសាបាលីថា "អារោហ (អា-រ៉ោ-ហ:)" មានន័យជាភាសាខ្មែរថា "ការឡើង" ។

មិអ៏រ៉ច់ (الْمِعْرَاج) ជាព្រឹត្តិការណ៍សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ។ ជាឱកាសដែលអល់ឡោះហ្វ៍عزّوجلّលើកព្រះសាស្ដាﷺ ជាទីស្រឡាញ់របស់ព្រះអង្គعزّوجلّ ឡើងទៅឋានសួគ៌ បង្ហាញព្រះអង្គﷺនូវព្រះមាបនកម្មអស្ចារ្យទាំងឡាយ ។ មិនដែលមានព្រះសាស្ដាអល់ឡោះហ្វ៍عزّوجلّអង្គណាមួយ ធ្លាប់មានព្រះកិត្តិយសក៏ធំធេងនេះឡើយ ។

ព្រះគម្ពីរគួរអានចែងថា៖

سُبۡحَٰنَ ٱلَّذِيٓ أَسۡرَىٰ بِعَبۡدِهِۦ لَيۡلٗا مِّنَ ٱلۡمَسۡجِدِ ٱلۡحَرَامِ إِلَى ٱلۡمَسۡجِدِ ٱلۡأَقۡصَا ٱلَّذِي بَٰرَكۡنَا حَوۡلَهُۥ لِنُرِيَهُۥ مِنۡ ءَايَٰتِنَآۚ إِنَّهُۥ هُوَ ٱلسَّمِيعُ ٱلۡبَصِيرُ ١

*1. សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះដែលបានលើកបាវបម្រើព្រះអង្គ (ព្រះសាស្ដាមូហ៊ាំម៉ាដ់) ឡើងក្នុងយប់មួយពីបូជនីយវិហារឆ្ពោះទៅកាន់ព្រះវិហារអាល់-អាក់ស្វ៏ ដែលយើងបានប្រសិទ្ធពរជ័យសិរីសួស្ដីជុំវិញ ដើម្បីនឹងបង្ហាញគេនូវបណ្ដាសញ្ញា[ដ៏មហាស្ចារ្យ]របស់យើង ។ ពិតណាស់ ព្រះអង្គទ្រង់សវនាការ ទ្រង់ទស្សនាការ ។*(ស៊ូរ៉ោះត៍ បានី អ៊ីសរ៉អ៊ីល ឬ អាល់-អ៊ីសរ៉អ៍ អាយ៉ាស់ 1 (17:1))

ព្រះយាត្រាបានចាប់ផ្ដើមពីផ្ទះរបស់ អ៊ុម ហានី (أُمُّ هَانِئٍ) បងស្រីរបស់អ៊ីមុាំអាលីصلوات الله عليه والسلام ។ ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺបានសម្រាកនៅទីនេះកាលទេវតាយ៉ីបរ៉អ៊ីលعَلَيْهِ السَّلَامُបានដាស់ព្រះអង្គﷺ ។ គេបានឲ្យព្រះអង្គﷺឡើងជិះសត្វមួយដែលមានស្លាបហៅថា អាល់-ប៊ូរ៉ក់ (الْبُرَاقُ) ។ បន្ទាប់មកព្រះអង្គﷺបានចាកចេញពីម៉ាក់កាស់ទៅកាន់ម៉ាស់យ៉ិដ អាល់-អាក់ស្វ៏ (الْمَسْجِدَ الْأَقْصَى) នៅឯបៃទុល-ម៉ាក់ឌីស (بَيْتُ الْمَقْدِسِ) (ពោលគឺ យេរូសាឡេម) ។ តាមផ្លូវ ព្រះអង្គﷺបានឈប់នៅឯភ្នំស៊ីណាយ បានស្វ៏ឡាត់ពីរ៉ក់អាត់ ព្រោះនៅឯភ្នំនេះឯងដែលអល់ឡោះហ្វ៍عزّوجلّបាននិយាយរកព្រះ

សាស្តាមូសាعليه السلام ។

ក្នុងប៉ែកទីពីរនៃព្រះយាត្រា ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានឡើងពីម៉ាស់យ៊ិដ្ អាល់-អាក់ស្វ៏ ជ្រែកមេឃទាំងប្រាំពីរ ម្តងមួយៗ ជាមួយយ៊ីបរ៉អ៊ីលعليه السلام ។ នៅលើមេឃទាំងនោះ ព្រះអង្គصلى الله عليه وآله وسلمបានជួបព្រះសាស្តាអ៊ីសាعليه السلام ព្រះសាស្តាមូសាعليه السلام ព្រះសាស្តានុះហ៊្វ៍عليه السلامនិងព្រះសាស្តាអាដាំعليه السلام ។ ព្រះអង្គصلى الله عليه وآله وسلمបានឃើញដែរ កន្លែងដែលប្រកបដោយព្រះពរនិងសេចក្តីរីករាយ (គឺឋានសួគ៌) និងកន្លែងធ្វើទារុណកម្មប្រកបដោយទុក្ខវេទនា (គឺឋាននរក) ។

បន្ទាប់ពីនោះ ព្រះអង្គصلى الله عليه وآله وسلمបានទៅដល់កន្លែងមួយដែលហៅថា ស៊ីដ្រ៉ោះត៍ អាល់-មុនតាហ្វា (سِدْرَةُ الْمُنْتَهَى) យ៊ីបរ៉អ៊ីលعليه السلامបានលាព្រះអង្គصلى الله عليه وآله وسلمនៅទីនេះ ។ ចាប់ពីពេលនេះទៅព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمនៅតែឯងជាមួយអល់ឡោះហ្វ៍عز وجل ។ ព្រះអង្គصلى الله عليه وآله وسلمបានទទួលពីអល់ឡោះហ្វ៍عز وجلនូវច្បាប់អ៊ីស្លាមទាំងអស់ រាប់បញ្ចូលព្រះបញ្ញាថ្មីៗមកលើមុស្លីមទាំងអស់ឲ្យអនុវត្តិស្វ៉ឡាត់ប្រចាំថ្ងៃទាំងប្រាំដែរ ។ បន្ទាប់ពីនោះ ព្រះអង្គصلى الله عليه وآله وسلمបានត្រឡប់មកវិញដូចកាលមកកាន់ទីនេះដែរ ដំបូងទៅកាន់បៃទុល-ម៉ាក់ឌីស បន្ទាប់មកទៅកាន់ម៉ាក់កាស់ ។ តាមផ្លូវទៅម៉ាក់កាស់ ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمជួបក្បួនទូរចរជំនួញពួកគូរ៉យ៉ស្ស៍ដែលកំពុងដើររកអូដ្ឋបែកហ្វូង ។ ព្រះអង្គصلى الله عليه وآله وسلمបានសោយទឹកពួកគេបន្តិច ហើយបានបន្តដំណើរទៅកាន់ម៉ាក់កាស់ ។ ព្រះអង្គصلى الله عليه وآله وسلمបានទៅដល់ផ្ទះ អ៊ូម ហ្វានី ពេលមុនថ្ងៃរះ ។

ស្អែកឡើង ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបាននិយាយរឿងនេះប្រាប់មនុស្សមួយក្រុមនៅឯម៉ាក់កាស់ ។ ភាគច្រើនសើចនិងជឿព្រះអង្គصلى الله عليه وآله وسلم តែអ្នកខ្លះមិនជឿព្រះអង្គصلى الله عليه وآله وسلمទេ ។ ពួកគេឲ្យព្រះអង្គصلى الله عليه وآله وسلمអធិប្បាយរៀបរាប់អំពីម៉ាស់យ៊ិដ្នៅឯបៃទុល-ម៉ាក់ឌីស ដើម្បីយកជាភ័ស្តុតាងថាព្រះអង្គصلى الله عليه وآله وسلمនិយាយពិតឬទេ ។ ពេលព្រះអង្គصلى الله عليه وآله وسلمថ្លែងរៀបរាប់លំអិតអំពីម៉ាស់យ៊ិដ្ បណ្តាអ្នកដែលធ្លាប់បានទៅកាន់ម៉ាស់យ៊ិដ្នោះបញ្ជាក់ថាព្រះអង្គصلى الله عليه وآله وسلمនិយាយពិត ។

ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានប្រាប់ពួកគូរ៉យ៉ស្ស៍មិនជឿ ថាព្រះអង្គصلى الله عليه وآله وسلمបានប្រទះក្បួនទូរចរជំនួញមួយរបស់ពួកគេនៅឯតានីម ថាពួកគេបានដើររកអូដ្ឋ ។ ព្រះអង្គصلى الله عليه وآله وسلمបានប្រាប់ដែរថាអូដ្ឋពណ៌ត្នោតនាំមុខក្បួនទូរចរ ថាក្រុមនេះជិតមកដល់ម៉ាក់កាស់ហើយ ។ មិនយូរ ក្បួនទូរចរជំនួញអធិប្បាយលំអិតដោយព្រះសាស្តាصلى الله عليه وآله وسلم

ក៏បានមកដល់ម៉ាក់កាស្ហ៍មែន ។ មេដឹកនាំក្បួនទូរចរឈ្មោះ អាប៊ូ ស៊ុហ្វយ៉ាន បញ្ជាក់ថាពិតអ្វីដែលព្រះសាស្តាﷺបានថានោះ ។

ពេលនេះគេមិនសង្ស័យទៀតទេ អំពីរឿងព្រះសាស្តាមូហាំម៉ាដ់ﷺបានចរយាត្រាយ៉ាងអស្ចារ្យ ព្រឹត្តិការណ៍មិអ៊្រ៉ច់បានលេចឮសុសសាយជុំវិញម៉ាក់កាស្ហ៍ ។ ពួកមេដឹកនាំគូរ៉យ៉ស្ហ៍មានសេចក្តីទោមនស្សអនេកអំពីលទ្ធផលបន្ទាប់ពីនេះ ពោលគឺ មានការផ្លាស់ប្តូរសាសនាមកកាន់សាសនាអ៊ីស្លាមជាច្រើន ។

សំខាន់ត្រូវយល់ថាព្រះយាត្រានេះជាចលនាដោយខ្លួនពិតៗតែម្តង មិនមែននៅក្នុងសុបិនអណ្តែតវិញ្ញាណដូច អៃស្ហាស្ហ៍ មហេសីម្នាក់របស់ព្រះសាស្តាមូហាំម៉ាដ់ﷺ ថានោះទេ ។ អៃស្ហាស្ហ៍បានថាព្រះសាស្តាមូហាំម៉ាដ់ﷺផ្ទំនៅឯផ្ទះខ្លួនក្នុងយប់ពាក់ព័ន្ធរឿងនេះ ។ សេចក្តីរាយការណ៍នេះមិនពិតទេ ព្រោះកាលមិអ៊្រ៉ច់នោះ អៃស្ហាស្ហ៍មិនទាន់រៀបការជាមួយព្រះសាស្តាមូហាំម៉ាដ់ﷺនៅឡើយទេ ហើយបានទៅជាមហេសីព្រះអង្គﷺ មួយឆ្នាំក្រោយពីបានភៀសខ្លួនទៅម៉ាឌីណាស្ហ៍ទេ ។

មូអាវីយ៉ាស្ហ៍ កូនរបស់ អាប៊ូ ស៊ុហ្វយ៉ាន បានអះអាងដែរថាមិអ៊្រ៉ច់ជា "សុបិនពិត" ។ មូអាវីយ៉ាស្ហ៍បានប្រឌិតរឿងនេះឡើងព្រោះតែគាត់ជាសត្រូវមួយរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺ ។ គាត់មិនបានកើតនៅសម័យនោះទេ មិនបានប្តូរសាសនាមកកាន់សាសនាអ៊ីស្លាមមុនអាយុ ៩ ឆ្នាំក្រោយសម័យភៀសខ្លួននោះទេ ដូច្នេះគាត់មិនអាចដឹងបាននូវហេតុការណ៍ទាំងអស់អំពីមិអ៊្រ៉ច់ទេ ។

មិអ៊្រ៉ច់បានប្រព្រឹត្តទៅអស់រយៈពេលមួយភាគបីនៃពេលយប់ ឬតិចជាងនេះបន្តិច ។ មូលហេតុដែលអល់ឡោះហ៊្ﷻបាននាំព្រះសាស្តាមូហាំម៉ាដ់ﷺទៅកាន់បៃទុល-ម៉ាក់ឌីស ដែលជាមជ្ឈដ្ឋានសម្រាប់ពួកអ្នកកាន់សាសនាយ៉ាហ៊ូឌីនិងពួកអ្នកកាន់សាសនាគ្រិស្តនោះ គឺដើម្បីបង្ហាញឲ្យឃើញថាអ៊ីស្លាមជាតំណាតពីព្រះរាជសារដែលព្រះសាស្តាអ៊ីបរ៉ហ៊ីមﷵ ព្រះសាស្តាមូសាﷵនិងព្រះសាស្តាអ៊ីសាﷵ បានទទួលរួចមកហើយកាលពីមុននោះ ។ ជាការបង្ហាញឲ្យឃើញដែរថាអ៊ីស្លាមជាសាសនាសាកល មិនត្រូវកម្រិតត្រឹមតែម៉ាក់កាស្ហ៍និងម៉ាឌីណាស្ហ៍ប៉ុណ្ណោះទេ ។

កាលព្រះសាស្តាមូហាំម៉ាដ់ﷺបានចរយាត្រាទៅលើមេឃ អល់ឡោះហ៊្ﷻ បានបើកឲ្យព្រះអង្គﷺដឹងព្រឹត្តិការណ៍ខ្លះ ក្នុងចំណោមព្រឹត្តិការណ៍ច្រើនទៀត នៅ

ទីនោះ គឺ៖

១. ការតែងតាំងអ៊ីម៉ាំអាលី عليه السلام ជាអ្នកស្នងព្រះអង្គ ﷺ អត់ពីព្រះអង្គ ﷺ ទៅ ។ សឲ្យឃើញនូវសារៈសំខាន់នៃការរៀបចំព្រឹត្តិការណ៍នានាទុកជាមុន ដើម្បីដឹកនាំអ៊ីស្លាមឲ្យបានល្អប្រសើរ ។

២. ស្វ៏ឡាត់ប្រចាំថ្ងៃប្រាំដង ។ ស្វ៏ឡាត់វ៉ាយិបដែលយើងស្គាល់សព្វថ្ងៃនេះបានទៅជាវ៉ាយិបសម្រាប់មុស្លីមទាំងអស់ក្រោយព្រឹត្តិការណ៍មិអ៍រ៉ាជ់ ។

៣. គេបានបង្ហាត់ព្រះសាស្តាមូហាំម៉ាដ់ ﷺ ឲ្យចេះដឹង ឌូអាអ៍និងស្វ៏ឡាត់ពិសេសខ្លះដែរ ។

ឱកាសល្អដែលគេបានប្រទានឲ្យព្រះសាស្តាមូហាំម៉ាដ់ ﷺ បានឃើញ និងបានឮអ្វីៗដែលដ៏អស្ចារ្យ (ដែលមិនធ្លាប់បានឃើញឬបានឮកាលពីមុនមក) នោះសឲ្យឃើញថាព្រះសាស្តាមូហាំម៉ាដ់ ﷺ ជាជំនិតរបស់អល់ឡោះហ្វ៍ عز وجل ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. តើមិអ៊្រ៉ជ្ញបានប្រព្រឹត្តទៅអស់រយៈពេលយូរប៉ុណ្ណា ?

២. យើងអាចដឹងបានដូចម្ដេងថាពុំមែនការយល់សប្ដិ ?

៣. គេបានបើកឲ្យព្រះសាស្ដាមូហាំម៉ាដ្ជ صلى الله عليه وآله وسلم ដឹងអ្វីខ្លះនៅក្នុងមិអ៊្រ៉ជ្ញ ?

៤. មុនព្រះសាស្ដាមូហាំម៉ាដ្ជ صلى الله عليه وآله وسلم បានទៅជួបអល់ឡោះហ្ទ៍ عز وجل ព្រះអង្គ صلى الله عليه وآله وسلم បានឆ្លងកាត់កន្លែងពីរ កន្លែងទាំងពីរនោះគឺកន្លែងអ្វី ?

៥. ហេតុអ្វីព្រះអង្គ صلى الله عليه وآله وسلم បានឈប់នៅឯភ្នំស៊ីណាយ ?

## មេរៀនទី ៩

# ដំណើរទៅត៏អ៊ីហ្វ

ក្រោយពី អាប៊ូ ត៏លិប ចូលទិវង្គត ព្រះសាស្តាមូហ្ហាំម៉ាដ្ឋ ﷺ ជួបប្រទះបញ្ហា និងការលំបាកច្រើននៅម៉ាក់កាស់ ។ គ្មានឪពុកធំការពារ ជីវិតព្រះអង្គ ﷺ នៅក្នុងគ្រោះថ្នាក់ឥតស្រាក ព្រះអង្គ ﷺ ពុំមានឱកាសច្រើនសម្រាប់ផ្សាយសាសនាអ៊ិស្លាមទេ ។

ព្រះអង្គ ﷺ បានសម្រេចព្រះទ័យផ្សាយសាសនាអ៊ិស្លាម ឯក្រៅម៉ាក់កាស់ ។ សម័យនោះស្រុកត៏អ៊ីហ្វ (طَائِف) ជាមជ្ឈដ្ឋានជំនួញសំខាន់និងធំមួយ ។ ព្រះសាស្តាមូហ្ហាំម៉ាដ្ឋ ﷺ ទៅកាន់ត៏អ៊ីហ្វតែឯង បានទាក់ទងប្រជាជាតិ បានី ស្សាគីហ្វ (بَنِي ثَقِيفٍ) ក្នុងបំណងហៅពួកគេមកចូលអ៊ីស្លាម ។ បន្ទាប់ពីបានទៅដល់ត៏អ៊ីហ្វ ព្រះអង្គ ﷺ បានជួបពួកមេដឹកនាំនិងពួកព្រឹទ្ធាចារ្យរបស់ប្រជាជាតិនេះ បានពន្យល់ពួកគេអំពីជំនឿលើព្រះតែមួយហើយបានសូមការគាំទ្រពីពួកគេ ។ តែព្រះវចនៈរបស់ព្រះអង្គ ﷺ ពុំមានឥទ្ធិពលលើពួកគេទេ ពួកគេបានបដិសេធព្រះរាជសារ ។ ព្រះសាស្តា ﷺ ដឹងថាពួកអ្នកស្រុកនេះអាចក្លាយទៅជាការគំរាមសម្រាប់ព្រះអង្គ ﷺ ព្រោះព្រះអង្គ ﷺ មានតែខ្លួនមួយ ឆ្ងាយពីស្រុក ។ ដូច្នេះព្រះអង្គ ﷺ បានសូមឲ្យពួក បានី ស្សាគីហ្វ សន្យាព្រះអង្គ ﷺ ថានឹងមិនឲ្យគេដឹងថាព្រះអង្គ ﷺ នៅទីនេះទេ ។ ពួកព្រឹទ្ធាចារ្យប្រជាជាតិ បានី ស្សាគីហ្វ មិនគោរពពាក្យសន្យាដែលបានឲ្យទៅព្រះសាស្តា ﷺ ទេ ផ្ទុយទៅវិញ ពួកគេបានឲ្យពួកចោរនិងពួកបំផ្លាញទ្រព្យសម្បត្តិគេរបស់ស្រុកនេះ បៀតបៀនព្រះអង្គ ﷺ ។ ដូច្នេះ ព្រះសាស្តាមូហ្ហាំម៉ាដ្ឋ ﷺ ត្រូវហ្វូងមនុស្សចោមរោមជេរប្រមាថ ។ ពេលត្រូវពួកគេចោលដុំថ្ម ព្រះអង្គ ﷺ ចាំបាច់ត្រូវដកខ្លួនថយទៅក្នុងសួនមួយ ។ សួននេះជាកម្មសិទ្ធិរបស់បុគ្គលប្រជាជាតិគូរ៉យស្ស៍សម្បូរទ្រព្យពីរនាក់ ។ ព្រះអង្គ ﷺ បែកញើសជោកមុខ ខ្លួនព្រះអង្គ ﷺ ត្រូវរបួសដោយសារពួកគេវាយ ។ ព្រះអង្គ ﷺ បានដាក់ខ្លួនសម្រាកក្រោមដើមឈើមួយ ហើយបានបួងសួងអល់ឡោះហ៍ ﷻ ថា៖ "ព្រះជាម្ចាស់ ﷻ អើយ ទូលព្រះបង្គំជាខ្ញុំ ﷺ ខ្សោយ ខ្វះខាតកម្លាំង ។ ព្រះអង្គ ﷺ ជាអ្នកផ្គត់ផ្គង់និងជាអ្នកជួយអ្នកទន់ខ្សោយ ។ តើពេលនេះព្រះ

អង្គﷻបោះបង់ចោលទូលព្រះបង្គំជាខ្ញុំﷺក្នុងកណ្តាប់ដៃអ្នកណា ?" ទោះបីម្ចាស់សួនធ្វើសក្ការៈរូបព្រះនិងជាសត្រូវរបស់អ៊ីស្លាមក៏ដោយ តែពួកគាត់អាណិតអាសូរព្រះសាស្តាម៉ូហាំម៉ាដ់ﷺ ។ ពួកគាត់បានឲ្យបម្រើកាន់សាសនាគ្រិស្តម្នាក់យកផ្លែទំពាំងបាយជូរមួយចានមកឲ្យព្រះអង្គﷺ ។ ពេលបម្រើយកទំពាំងបាយជូរមកឲ្យព្រះអង្គﷺ ព្រះអង្គﷺបេះមួយគ្រាប់មកសោយដោយមានព្រះវចនៈថា៖ "ដោយនូវព្រះនាមអល់ឡោះហ៊្ជﷻ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី (بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ)" ។ ពាក្យពេជន៍នេះធ្វើឲ្យបុរសគ្រិស្តសាសនិកភ្ញាក់ផ្អើលហើយបានកត់សម្គាល់ថា គាត់មិនដែលឮពួកអារ៉ាប់សូត្របួងសួងអ្វីផ្សេងទេក្រៅពីរូបព្រះធំៗឈ្មោះឡាត់ (اللات) និងអ៊ូស្សា (عزى) នោះ ។ ព្រះសាស្តាម៉ូហាំម៉ាដ់ﷺ បានសួរចង់ដឹងស្រុកកំណើតគាត់ ។ គាត់បានតបថាគាត់មកពីស្រុកណៃនីវ៉ា (نَيْنَوى) កាន់សាសនាគ្រិស្ត ។ ពេលបានឮចម្លើយ ព្រះសាស្តាម៉ូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "នេះគឺកន្លែងដែល យូនុសؑ កូនរបស់ ម៉ាតា (يونس بن مَتى) រៀមច្បងខ្ញុំﷺ បានរស់នៅ ។" ពេលបានឮឈ្មោះនេះបុរសគ្រិស្តសាសនិកភ្ញាក់ព្រើត សួរថា៖ "ម្តេចលោកﷺស្គាល់ឈ្មោះ យូនុសؑ កូនរបស់ម៉ាតា ? ពុំមានអ្នកណាធ្លាប់បានឮបុគ្គលទាំងនេះទេក្នុងតំបន់នេះ ។" ព្រះសាស្តាម៉ូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "យូនុសؑជាព្រះសាស្តាមួយអង្គរបស់អល់ឡោះហ៊្ជﷻដូចខ្ញុំﷺដែរ ។" ព្រះវចនៈរបស់ព្រះសាស្តាម៉ូហាំម៉ាដ់ﷺជះឥទ្ធិពលខ្លាំងទៅលើបុរសបម្រើគេ គាត់បានសម្តែងសេចក្តីគោរពភ្លាម បានថើបដៃព្រះសាស្តាﷺហើយបានប្តេជ្ញាជឿព្រះអង្គﷺ ។ ពេលគាត់ត្រឡប់ទៅជួបម្ចាស់គាត់វិញ ម្ចាស់គាត់សួរគាត់ថាបាននិយាយគ្នាអំពីអ្វី ។ គាត់បានឆ្លើយប្រាប់ថា៖ "បុគ្គលដែលកំពុងអង្គុយនៅក្នុងសួនរបស់លោកម្ចាស់នេះជាព្រះអគ្គមហាប្រមុខរបស់មនុស្សជាតិទាំងអស់ ។ ព្រះអង្គﷺបានប្រាប់ខ្ញុំអ្វីដែលមានតែព្រះសាស្តាទេដែលដឹង ។" ចម្លើយនេះធ្វើឲ្យម្ចាស់សួនរំខានចិត្តតែពួកគាត់គ្រាន់តែបានថាសាសនារបស់ពួកគាត់ប្រសើរជាងសាសនាអ៊ីស្លាម ។

ព្រះសាស្តាម៉ូហាំម៉ាដ់ﷺបានចាកចេញពីតំអ៊ីហ្វ ខកចិត្តដែលពុំបានសម្រេចក្នុងការដឹកនាំនៅលើផ្លូវត្រូវពួកចចេសខ្វះការចេះដឹង ។ ព្រះអង្គﷺបានសម្រេចព្រះទ័យវិលត្រឡប់ទៅម៉ាក់កាស់វិញ ។ តែព្រះអង្គﷺមិនអាចចូលទៅក្នុងស្រុកម៉ាក់កាស់បានដោយសុវត្ថិភាពទេ ព្រោះជីវិតព្រះអង្គﷺនៅក្នុងភ័យអន្តរាយ ។

ដូច្នេះព្រះអង្គﷺបានផ្ញើសំបុត្រទៅ មុត្ត្អ៊ីម ប៊ិន អាឌី (مُطْعِمُ بْنُ عَدِيٍّ) អ្នកស្រុកម៉ាក់កាស្ទ័មានអំណាចម្នាក់ដើម្បីសូមជំនួយ ។

មុត្ត្អ៊ីមធ្វើសក្ការៈរូបព្រះតែគាត់ព្រមជួយព្រះសាស្ដាមូហាំម៉ាដ់ﷺ ព្រោះគាត់គោរពវង្សត្រកូលព្រះសាស្ដាﷺ ។ គាត់បានផ្ញើសំបុត្រទៅព្រះសាស្ដាﷺ សូមឲ្យព្រះអង្គﷺយាងចូលក្នុងស្រុកម៉ាក់កាស្ទ័ មកកាន់លំនៅដ្ឋានគាត់តែម្ដង ។

ថ្ងៃបន្ទាប់ មុត្ត្អ៊ីមបានឲ្យកូនប្រុសៗរបស់គាត់ប្រដាប់អាវុធ ដើរការពារព្រះសាស្ដាមូហាំម៉ាដ់ﷺទៅកាន់កាក់បាស្ទ័ ។ ពេល អាប៊ូ ស៊ុហ្វយ៉ាន និងបុគ្គលឯទៀតដែលចង់បៀតបៀនព្រះសាស្ដាﷺបានឃើញមុត្ត្អ៊ីមការពារព្រះអង្គﷺ ពួកគេខកចិត្តតែមិនហ៊ានប៉ះពាល់ព្រះអង្គﷺទេ ។ ក្រោយពីបានធ្វើតាវ៉ាហ្វរួច ព្រះសាស្ដាមូហាំម៉ាដ់ﷺបានទៅកាន់លំនៅដ្ឋានព្រះអង្គﷺ ។

ក្រោយមកបន្តិច ព្រះសាស្ដាមូហាំម៉ាដ់ﷺបានភៀសខ្លួនទៅកាន់ម៉ាឌីណាស្ទ័ ។ ច្រើនឆ្នាំក្រោយមក ព្រះសាស្ដាមូហាំម៉ាដ់ﷺបានទៅកាន់តំ្អីហ្វវាយឈ្នះពួកប្រជាជាតិ បានី ស្ទាគីហ្វ ។ តែព្រះអង្គﷺមិនភ្លេចគុណមុត្ត្អ៊ីមឡើយដែលបានជួយព្រះអង្គﷺពេលដែលព្រះអង្គﷺត្រូវការបង្អែក ។ ពេលព្រះអង្គﷺបានទទួលដំណឹងថាមុត្ត្អ៊ីមទទួលអនិច្ចកម្ម ព្រះសាស្ដាﷺនឹកដល់លោកដែលធ្លាប់មានសប្បុរសធម៌ ។

ព្រះយាត្រារបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺទៅកាន់តំ្អីហ្វ ក្នុងកាលៈទេសៈដ៏លំបាកបញ្ជាក់ប្រាប់យើងថា ព្រះអង្គﷺបានប្ដូរផ្ដាច់បំពេញករណីយកិច្ចផ្សព្វផ្សាយសាសនាអ៊ីស្លាមរបស់ព្រះអង្គﷺឥតរួញរា ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺបានសម្រេចចិត្តទៅកាន់ស្រុកត៏អ៊ីហ្វ ?

២. ព្រះអង្គﷺបានទទួលចម្លើយអ្វីពីអ្នកស្រុកនោះ ?

៣. មូលហេតុអ្វីបានជាបុរសកាន់សាសនាគ្រិស្តព្រមចូលសាសនាអ៊ីស្លាម ?

៤. ហេតុអ្វីព្រះសាស្តាមូហាំម៉ាដ់ﷺបានទាក់ទងមុត្ទអ៊ីម មុនចូលទៅក្នុងស្រុកម៉ាក់កាស្ញ ?

៥. តើយើងស្រង់បាននូវមេរៀនអ្វីពីព្រឹត្តិការណ៍នេះ ?

**មេរៀនទី ១០**

# កិច្ចសន្យានៅអាកាបាស់

ក្នុងរដូវហាជ្ជ ប្រជាជាតិនានានៃដែនដីអារ៉ាប៊ីទាំងមូលមកបំពេញពិធីហាជ្ជនៅឯម៉ាក់កាស់ ។ ទោះបីការធ្វើសក្ការៈរបស់ពួកគេមិនជាប់ពាក់ព័ន្ធសោះនឹងពិធីហាជ្ជដែលអ៊ីស្លាមបានបង្ហាត់បង្រៀនយើងនោះក៏ដោយ តែពួកគេទុកព្រះមហាគ្រឹះកាក់បាស់ជាបូជណីយស្ថានសំខាន់មួយ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រើពេលច្រើនជាងពេលឯទៀតក្នុងឆ្នាំដើម្បីជួបបណ្តាអ្នកដំណើរ ដើម្បីបង្ហាត់បង្រៀនពួកគេឲ្យចេះដឹងសិក្ខាបទអ៊ីស្លាម ។

ពួកអ្នកស្រុកម៉ាឌីណាស់ ដែលគេហៅថាស្រុកយ៉ាស្ស៊ីរិបសម័យនោះ ធ្លាប់តែមកកាន់ម៉ាក់កាស់ដែររៀងរាល់ឆ្នាំ ។ កុលសម្ព័ន្ធឬប្រជាជាតិពីរធំជាងគេនៅម៉ាឌីណាស់គឺប្រជាជាតិអៅស៍ (الْأَوْس) និងប្រជាជាតិខូស្ស៊ូរ៉ច់ (الْخَزْرَج) ។ កុលសម្ព័ន្ធទាំងពីរនេះជាសត្រូវហុតឈាមនឹងគ្នា ច្បាំងគ្នាច្រើនលើកច្រើនសាហើយ ។

ក្នុងឆ្នាំទី ១១ ក្រោយពីចាប់ផ្តើមបំពេញព្រះបេសកកម្មសាស្តា ព្រះសាស្តាមូហាំម៉ាដ់ﷺបានជួបបុគ្គលប្រជាជាតិខូស្ស៊ូរ៉ច់ប្រាំមួយនាក់នៅម៉ាក់កាស់ ក្នុងរដូវហាជ្ជ ។ ពេលព្រះអង្គﷺនិយាយប្រាប់ពួកគេអំពីអ៊ីស្លាម ពួកគេចាប់អារម្មណ៍ណាស់ព្រោះធ្លាប់បានឮពួកយ៉ាហ៊ូឌីនៅម៉ាឌីណាស់និយាយថា ថ្ងៃមួយនឹងមានព្រះសាស្តាមួយអង្គលេចឡើងពីដែនដីអារ៉ាប៊ី ។ ពួកយ៉ាហ៊ូឌីដឹងរឿងនេះព្រោះរឿងនេះមានចារនៅក្នុងព្រះគម្ពីរពួកគេ គឺព្រះគម្ពីរតៅរ៉ត់ដែលអល់ឡោះហ៏ﷻបានឲ្យមកព្រះសាស្តាមូសាعليه السلام ។ ពួកខូស្ស៊ូរ៉ច់ជឿថាព្រះសាស្តានៅក្នុងព្រះគម្ពីរនេះជាព្រះសាស្តាអង្គនេះឯង ដូច្នេះពួកគេក៏បានទៅជាមុស្លីម ។ ពេលត្រឡប់មកម៉ាឌីណាស់វិញ ពួកគេខិតខំបង្ហាត់បង្រៀនសាសនាអ៊ីស្លាមឲ្យមនុស្សចេះដឹង មិនយូរប៉ុន្មានមានមនុស្សច្រើននាក់ចង់ដឹងចង់ស្គាល់ឲ្យបានក្រៃលអំពីសាសនាថ្មីនេះ ។

ឆ្នាំបន្ទាប់មក មានមនុស្សដប់ពីរនាក់មកម៉ាក់កាស់ដើម្បីជួបព្រះសាស្តាមូហាំម៉ាដ់ﷺ ។ កន្លែងប្រជុំគ្នានៅឯស្រុកមួយហៅថា អាកាបាស់ (الْعَقَبَة) ហើយបានទទួលលទ្ធផលកិច្ចព្រមព្រៀងអ៊ីស្លាមដំបូងមួយ ។ ក្រោយពីបានចូល

សាសនាអ៊ីស្លាមហើយ ពួកគេបានសន្យាថាមិនយកអ្នកណាផ្សេងមកហ៊ុនហាយជាមួយអល់ឡោះហ្ ﷻទេ ថាមិនលួចប្លន់គេទេ ថាមិនកប់កូនស្រីឯងទាំងរស់ទេ ។ ពួកគេបានសន្យាថានឹងមិននិយាយបង្កាច់គ្នាទេ និងធ្វើអំពើល្អ ។

ព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺបានសន្យាពួកគេថា បើពួកគេគោរពពាក្យសន្យាមែន អល់ឡោះហ្ ﷻនឹងឲ្យឋានសួគ៌ពួកគេជារង្វាន់ ។ គេហៅកិច្ចព្រមព្រៀងនេះថា "កិច្ចសន្យាអាក្វ៏បាស់ដំបូង" ។ បុគ្គលទាំង ១២ នាក់បានត្រឡប់ទៅម៉ាឌីណាស់វិញចិត្តពោរពេញដោយជំនឿ ។ ពួកគេបានផ្ញើសំបុត្រមកព្រះសាស្តា ﷺ សូមឲ្យព្រះអង្គ ﷺចាត់បញ្ជូនមនុស្សម្នាក់មកម៉ាឌីណាស់ ដើម្បីបង្ហាត់បង្រៀនឲ្យចេះដឹងសាសនាអ៊ីស្លាមក្រៃលជាងមុន ។

ព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺបានចាត់បញ្ជូន មុស្វអាប់ ប៊ីន អ៊ូម៉ៃរ៍ (مُصْعَبُ بْنُ عُمَيْرٍ) និង អ៊ីបនូ អ៊ុម ម៉ាក់ទុម (اِبْنُ أُمِّ مَكْتُومٍ) ទៅបង្ហាត់បង្រៀនពួកគេ ។ បេសកជនទាំងពីរធ្វើការបានល្អបំផុត បណ្តាលឲ្យមានការផ្លាស់ប្តូរគំនិតច្រើននៅម៉ាឌីណាស់ ។ មនុស្សទន្ទឹងចាំរដូវហាជ្ជ៍យ៉ាងអន្ទះអន្ទែង ព្រោះតែចង់ជួបព្រះសាស្តា ﷺមូហ៊ាំម៉ាដ្ ﷺនិងដើម្បីប្តេជ្ញាចិត្តជ្រោមជ្រែងអ៊ីស្លាម ។

ឆ្នាំក្រោយមក ក្បួនទូរចរបំពេញពិធីហាជ្ជ៍មានមនុស្ស ៥០០ នាក់ ភាគច្រើនជាប្រជាជាតិខ្ស៊្ររ៉ជ្ជ៍ បានចាកចេញពីម៉ាឌីណាស់មកកាន់ម៉ាក់កាស់ ។ ក្រុមនេះមានមុស្លីម ៧៣ នាក់ ២ នាក់ជាស្ត្រី ក្រៅពីនេះគឺបណ្តាអ្នកដែលចង់ដឹងឲ្យបានច្រើនអំពីសាសនាមុននឹងទៅជាមុស្លីម ។ ពួកគេបានជួបព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺ ថ្ងៃទី ១៣ ខែ ស៊្ហុល ហ៊ីជ្ជ៍យ៉ាស់ នៅឯអាក្វ៏បាស់ ។

នៅក្នុងអង្គប្រជុំនេះ ព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺបានចរចាជាមួយពួកគេ បានសូត្រអាយ៉ាស់គួរអានឲ្យពួកគេស្តាប់ ។ ព្រះវចនៈព្រះសាស្តា ﷺបានធ្វើឲ្យអ្នកស្តាប់ទាំងអស់ចាប់អារម្មណ៍ខ្លាំង ពួកគេទាំងអស់គ្នាត្រៀមខ្លួនប្តេជ្ញាជឿអ៊ីស្លាមនៅលើដៃព្រះអង្គ ﷺ ។ ទាំងអស់គ្នាបានស្បថស្មោះស្ម័គ្រ (اَلْبَيْعَةُ បៃអាស់) លើដៃព្រះសាស្តាមូហ៊ាំម៉ាដ្ ﷺ ។ គេហៅព្រឹត្តិការណ៍នេះថា "កិច្ចសន្យាអាក្វ៏បាស់ទីពីរ" ។ ព្រះសាស្តា ﷺបានសន្យាពួកគេទាំងអស់គ្នាថាមិនយូរទេ ព្រះអង្គ ﷺនឹងទៅម៉ាឌីណាស់ ។ ចប់ពីធី មនុស្សទាំងអស់បានវិលត្រឡប់ទៅលំនៅវិញ ។

ចំណុចមួយគួរឲ្យកត់សម្គាល់គឺ អ្នកស្រុកម៉ាឌីណាស់ច្រើនព្រមចូលសាសនា

អ៊ីស្លាមក្រោយពីបានដឹងអំពីសាសនាតែបីឆ្នាំទេ ចំណែកឯពួកអ្នកស្រុកម៉ាក់កាស្ហ៍វិញ ព្រះសាស្តាﷺបានផ្សាយសាសនា ១៣ ឆ្នាំទើបពួកគេបានទៅជាមុស្លីម ។ រឿងនេះអាចមានមូលហេតុពីរ គឺ៖

១. អ្នកស្រុកម៉ាឌីណាស្ហ៍ធ្លាប់បានឮប្រជាជាតិយ៉ាហ៊្វូឌីជិតខាង និយាយអំពីព្រះសាស្តាអារ៉ាប់ ។ ពួកយ៉ាហ៊្វូឌីបានថាកាលណាព្រះសាស្តាអង្គនេះកើតឡើង ព្រះអង្គនឹងផ្សាយសាសនាយ៉ាហ៊្វូឌី ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជាតិអៅស៍និងប្រជាជាតិខ្ហ៊ុស្ហ៊រ៉ច៍ បានត្រៀមខ្លួនជឿព្រះសាស្តាមូហាំម៉ាដ្ហ៍ﷺ ជាស្រេច កាលណាព្រះអង្គﷺប្រកាសថាត្រូវចាត់បញ្ជូនមកដោយអល់ឡោះហ្ហ៍ﷻ ចំណែកពួកអ្នកស្រុកម៉ាក់កាស្ហ៍មិនបានត្រៀមខ្លួនជាមុនទេ ។

២. ប្រជាជាតិអៅស៍និងប្រជាជាតិខ្ហ៊ុស្ហ៊រ៉ច៍ ធុញទ្រាន់ជម្លោះឥតស្រាករវាងប្រជាជាតិទាំងពីរដែលច្បាំងគ្នាតាំងពី ១២០ ឆ្នាំមកហើយនោះ ។ ពួកគេស្វែងរកអ្នកមានសមត្ថភាពដែលអាចនាំមកបាននូវសន្តិសុខក្នុងតំបន់ខ្លួន ។

ដល់ពេលព្រះសាស្តាមូហាំម៉ាដ្ហ៍ﷺចាកចេញពីលំនៅព្រះអង្គﷺ នៅឯម៉ាក់កាស្ហ៍ ។ ការរស់នៅក្នុងស្រុកនេះកាន់តែលំបាកឡើងៗសម្រាប់ពួកមុស្លីមដែលត្រូវពួកគូរ៉យ៉ស្ហ៍ធ្វើបាបឥតស្រាក ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺះ

១. ពួកអ្នកស្រុកម៉ាឌីណាស្ងបានសន្យាអ្វី កាលពួកគេមកឯអាក់ក៏បាស្ងលើកដំបូង ?

២. ប៉ុន្មាននាក់បានមកឯអាក់ក៏បាស្ងឆ្នាំចុងក្រោយ កាលព្រះសាស្តាﷺនៅម៉ាក់កាស្ង ?

៣. ហេតុអ្វីព្រះរាជសារអ៊ីស្លាមលេចឮនៅឯម៉ាឌីណាស្ង លឿនជាងនៅឯម៉ាក់កាស្ង ?

៤. ប្រជាជាតិណាទៀតដែលរស់នៅក្បែរប្រជាជាតិអៅស៍ និងប្រជាជាតិខុស្សរ៉ជ្ង ?

៥. ព្រះសាស្តាមូហាំម៉ាដ្ងﷺបានសន្យាពួកអ្នកស្រុកម៉ាឌីណាស្ងថាអ្វី ?

## មេរៀនទី ១១

# ហ៊ីច្រ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស៍ - ភាគ ១

ពួកគួរ៉យ៉ស្ហ៍ក្រោធណាស់ពេលបានដឹងថាពេលនេះ បណ្ដាអ៊ីស្លាមសាសនិកទទួលបាននូវការគាំទ្រពីអ្នកស្រុកម៉ាឌីណាស៍ ។ ដើម្បីកម្ទេចសេចក្ដីប្ដេជ្ញាចិត្តនិងសេចក្ដីក្លាហានរបស់ពួកមុស្លីម ពួកគេកាន់តែធ្វើបាបនិងធ្វើទុក្ខបុកម្នេញពួកមុស្លីមខ្លាំងឡើង ។ បណ្ដាបក្សពួករបស់ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺបានមកប្ដឹងព្រះអង្គﷺអំពីការធ្វើបាបជាទម្ងន់ ដែលពួកគេទទួលរងពីសំណាក់ពួកទមិឡឥតសាសនា ។ ព្រះអង្គﷺសូមឲ្យពួកគេទុកពេលឲ្យព្រះអង្គﷺបន្តិចដើម្បីគិតគូរ ។ ពីរបីថ្ងៃក្រោយមក ព្រះអង្គﷺបានណែនាំឲ្យមុស្លីមទាំងអស់ភៀសខ្លួនទៅម៉ាឌីណាស៍ដោយសម្ងាត់ ឲ្យរង់ចាំព្រះអង្គﷺនៅទីនោះ ។ លុះបានចេញបញ្ជាឲ្យភៀសខ្លួនហើយ បណ្ដាមុស្លីមបានចាកចេញពីម៉ាក់កាស៍ម្ដងម្នាក់ៗ ដោយមានលេស ។ ព្រោះតែខ្លាចប្រតិកម្មពួកគួរ៉យ៉ស្ហ៍ បានជាពួកមុស្លីមមិនឲ្យគេដឹងទិសដៅរបស់ខ្លួនទេ ។ ហេតុដូច្នេះឯងបានមុស្លីមភាគច្រើនចាំបាច់ត្រូវចាកចោលទ្រព្យសម្បត្តិខ្លួន ។ ពួកគួរ៉យ៉ស្ហ៍ក៏បានដឹងថាមុស្លីមទាំងអស់ចាកចេញពីម៉ាក់កាស៍ ។ ពួកគេព្យាយាមរារាំងបានខ្លះតែភាគច្រើនបានចេញផុតទៅហើយ កំពុងធ្វើដំណើរឆ្ពោះទៅកាន់ម៉ាឌីណាស៍ ។ នៅឯម៉ាក់កាស៍នៅសល់តែព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺនិងគ្រួសារព្រះអង្គﷺ អ៊ីមុាំអាលីصلوات الله عليه والسلامនិងមុស្លីមចំណាស់និងឈឺពីរបីនាក់ប៉ុណ្ណោះ ។ គេបានរៀបចំចំណាកចុងក្រោយសម្រាប់បុគ្គលចុងក្រោយទាំងនេះដែរ ។

ការលបរត់យ៉ាងសម្ងើមនេះធ្វើឲ្យពួកគួរ៉យ៉ស្ហ៍ក្ដៅក្រហាយចិត្តណាស់ ។ ពួកគេដឹងថាពេលនេះពួកមុស្លីមនឹងទៅជាគ្រោះថ្នាក់សម្រាប់ពួកគេ ។ នៅឯសភា ដារអាន់-ណាដ្វ៉ាស៍ (دار الندوة) កន្លែងប្រជុំពិភាក្សារឿងសំខាន់ៗ ពួកគួរ៉យ៉ស្ហ៍បានសម្រេចចិត្តថា មានតែមធ្យោបាយមួយគត់ដែលអាចទប់ស្កាត់កុំឲ្យសាសនាអ៊ីស្លាមរាលដាលបាន គឺសម្លាប់ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺចោលតែម្ដង ។ ទាំងអស់គ្នាយល់ស្របតាមមតិនេះ តែមានបញ្ហាមួយគឺពួក បានី ហ្ញាស្ហ៊ីម គ្រួសារព្រះសាស្ដាមូហ៊ាំម៉ាដ្ឋ៍ﷺនឹងសងសឹកឃាតករ ។ ទីបំផុត អាប៊ូ យ៉ាហ្ញាល់ ស្នើថាប្រសើរជាង

បញ្ជូនឃាតករតែម្នាក់ទៅសម្លាប់ព្រះសាស្តាមូហាំម៉ាដ់(صلى الله عليه وآله وسلم) គប្បីបញ្ជូនយុវជនម្នាក់របស់កុលសម្ព័ន្ធមួយ គ្រប់ៗកុលសម្ព័ន្ធ ។ ធ្វើដូច្នេះពួក បានី ហាស៊ីម មិនអាចទម្លាក់កំហុសទៅលើមនុស្សតែម្នាក់បានទេ ។ ពួកគេក៏បានមូលមតិគ្នាជ្រើសយកផែនការណ៍នេះ យុវជន ៤០ នាក់ត្រូវបានជ្រើសរើសសម្រាប់ប្រព្រឹត្តទង្វើកំសាក ។

ក្នុងយប់តែមួយ ដែលពួកគូរ៉យ៉ស៍បានរៀបផែនការណ៍ធ្វើគុតព្រះសាស្តាមូហាំម៉ាដ់(صلى الله عليه وآله وسلم)នោះ អល់ឡោះហ៍(عز وجل)បានដាក់ព្រះរាជបញ្ជាឲ្យព្រះអង្គ(صلى الله عليه وآله وسلم)ចាកចេញពីម៉ាក់កាស់ទៅកាន់ម៉ាឌីណាស់ ។ ទេវតាយីប៊ីរ៉អ៊ីល(عليه السلام)បានប្រាប់ព្រះសាស្តាមូហាំម៉ាដ់(صلى الله عليه وآله وسلم)ឲ្យជ្រាបអំពីគោលបំណងអាក្រក់របស់ពួកគូរ៉យ៉ស៍ ។ ព្រះសាស្តា(صلى الله عليه وآله وسلم)បានប្រាប់អ៊ីម៉ាំអាលី(صلوات الله عليه والسلام)ថា៖ "ចូរអ្នក(صلوات الله عليه والسلام)ដេកលើគ្រែខ្ញុំ(صلى الله عليه وآله وسلم)យប់នេះ ដណ្តប់ភួយពណ៌បៃតងដែលខ្ញុំ(صلى الله عليه وآله وسلم)ធ្លាប់តែប្រើពេលខ្ញុំ(صلى الله عليه وآله وسلم)ដេក ។" ព្រះអង្គ(صلى الله عليه وآله وسلم)បានផ្តាំឲ្យអ៊ីម៉ាំអាលី(صلوات الله عليه والسلام)ទៅតាមព្រះអង្គ(صلى الله عليه وآله وسلم) ក្រោយពីបានប្រគល់បញ្ញើរបស់អ្នកស្រុកម៉ាក់កាស់ដែលបានផ្ញើទុកនឹងព្រះអង្គ(صلى الله عليه وآله وسلم)នោះឲ្យទៅម្ចាស់នោះវិញ ។ អ៊ីម៉ាំអាលី(صلوات الله عليه والسلام)ធ្លាប់តែមានវចនៈ ច្រើនឆ្នាំក្រោយមក ថាទោះបីមានគ្រោះថ្នាក់ដល់ស្លាប់ក៏ដោយ ព្រះអង្គ(صلوات الله عليه والسلام)បានផ្ទំលក់ដោយសុខសាន្តយប់នោះ ។

ជិតដល់យប់ លំនៅព្រះសាស្តាមូហាំម៉ាដ់(صلى الله عليه وآله وسلم)ត្រូវឡោមព័ទ្ធដោយបុរសគូរ៉យ៉ស៍ ៤០ នាក់ ។ ពួកគេបានរង់ចាំដល់ពេលព្រឹកទើបចុះដៃ ។

ពាក់កណ្តាលយប់បានកន្លងផុត ព្រះសាស្តាមូហាំម៉ាដ់(صلى الله عليه وآله وسلم)បានចេញពីផ្ទះដើម្បីធ្វើដំណើរឆ្ពោះទៅឯនាយ ។ ពេលចេញពីផ្ទះ ព្រះអង្គ(صلى الله عليه وآله وسلم)បានបាយខ្សាច់បន្តិចទៅលើបនឃាតករដែលកំពុងរង់ចាំធ្វើឃាតព្រះអង្គ(صلى الله عليه وآله وسلم) ដោយសូត្រអាយ៉ាស់នេះ គឺ៖

وَجَعَلْنَا مِنۢ بَيْنِ أَيْدِيهِمْ سَدًّا وَمِنْ خَلْفِهِمْ سَدًّا فَأَغْشَيْنَٰهُمْ فَهُمْ لَا يُبْصِرُونَ ﴿٩﴾

*9. យើងនឹងដាក់របាំងមួយនៅពីមុខពួកគេ និងរបាំងមួយនៅពីក្រោយពួកគេហើយយើងនឹងគ្រប[ភ្នែក]ពួកគេ ។ ដូច្នេះពួកគេនឹងមើលមិនឃើញទេ ។* (ស៊ូរ៉ោះត៍យ៉ាស៊ីន អាយ៉ាស់ 9 (36:9))

ព្រះសាស្តាមូហាំម៉ាដ់(صلى الله عليه وآله وسلم)បានបន្តដំណើរទៅមុខ ដោយពុំធ្វើឲ្យពួកឃាតករដែលនៅចាំព្រះអង្គ(صلى الله عليه وآله وسلم)នោះដឹងខ្លួនទេ ។ ព្រឹកឡើង ពួកឃាតករសែសិបនាក់បានស្ទុះចូលទៅក្នុងផ្ទះព្រះអង្គ(صلى الله عليه وآله وسلم)លាន់សូរទ្រហឹង ម្នាក់ៗប៉ងកាប់សម្លាប់ព្រះសាស្តា

ﷺមុនគេ ។ ពេលឮសម្លេងជ្រួលច្របល់ អ៊ីមុាំអាុលីصلوات الله عليه والسلامងើបក្បាលពីខ្នើយ គ្រវាត់ផ្ទួយបែតងទៅម្ខាង ។ ពេលឃើញអ៊ីមុាំអាុលីصلوات الله عليه والسلام ពួកឃាតករសែសិបទច់ង៉ក់ ។ ពួកវាសួរថា៖ "ឯណាមូហ៊ាំម៉ាដ្ឋ៎ﷺ ?" អ៊ីមុាំអាុលីصلوات الله عليه والسلامតបថា៖ "អស់លោកផ្ញើព្រះអង្គﷺទុកនឹងខ្ញុំصلوات الله عليه والسلامឬ បានជាទារយកព្រះអង្គﷺពីខ្ញុំصلوات الله عليه والسلامវិញ ? ពេលនេះព្រះអង្គﷺមិននៅផ្ទះទេ ។"

ពួកគូរ៉យ៉ស្ហ៍ខកចិត្តជ្សិតបរាជ័យ មិនអើពើអ៊ីមុាំអាុលីصلوات الله عليه والسلامទេព្រោះព្រះអង្គصلوات الله عليه والسلامមិនមែនបដិបក្ខពួកគេទេ ។ ពួកគេបានចាកចេញពីផ្ទះដោយស្តាយក្រោយដែលបានរង់ចាំលុះដល់ព្រឹក ។

ក្នុងពេលតែមួយ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៎ﷺទទួលរងយថាការណ៍ច្រើនទៀតតាមផ្លូវទៅម៉ាឌីណាស្ហ៍ ព្រះអង្គﷺបានរួចផុតពីបច្ចាមិត្តព្រោះអល់ឡោះហ្ស៍عز وجلបានការពារព្រះអង្គﷺ ។

អល់ឡោះហ្ស៍عز وجلមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអានថា៖

وَإِذْ يَمْكُرُ بِكَ ٱلَّذِينَ كَفَرُوا۟ لِيُثْبِتُوكَ أَوْ يَقْتُلُوكَ أَوْ يُخْرِجُوكَ ۚ وَيَمْكُرُونَ وَيَمْكُرُ ٱللَّهُ ۖ وَٱللَّهُ خَيْرُ ٱلْمَٰكِرِينَ ﴿٣٠﴾

*30. [ចូរអ្នកនឹកឃើញ]កាលពួកបដិសេធសទ្ធា [ពួកលាក់ពុត ពួកបដិមានិយម ពួកទុច្ចរិត...] បានរៀបផែនការប្រឆាំងអ្នក ដើម្បីចាប់ខ្លួនអ្នក ធ្វើឃាតអ្នក ឬបណ្តេញអ្នក ។ ពួកគេបានប្រើឧបាយកល អល់ឡោះហ្ស៍[ក៏]បានរៀបផែនការ[ដែរប្រឆាំងល្បិចកលរបស់ពួកបដិសេធសទ្ធា ដើម្បីសង្គ្រោះអ្នកនិងបណ្តាអ្នកមានសទ្ធា] ។ អល់ឡោះហ្ស៍ជាអ្នករៀបផែនការប្រសើរដាច់គេ ។* (ស៊ូរ៉ោះត្ហ៍ អាល់-អាន់ហ្វាល អាយ៉ាស្ហ៍ 30 (8:30)) ។

## មេរៀនទី ១២

# ហ៊ីច្រ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ២

កាលអ៊ីមុាំអាលី(صلوات الله عليه والسلام)បានផ្ទំជួសព្រះសាស្តាមូហាំម៉ាដ់ﷺលើគ្រែ ព្រះអង្គﷺបានធ្វើដំណើរចាកចេញពីម៉ាក់កាស់ ។ ពេលចេញពីក្នុងស្រុកព្រះអង្គﷺបានជួបអាប៊ូ បាការ តាមផ្លូវ បាននាំគាត់ទៅជាមួយព្រះអង្គﷺ ។ ព្រះអង្គﷺដឹងថាពួកគូរ៉យ់ស្ហ៍នឹងមិនដេញតាមព្រះអង្គﷺឲ្យខាតពេលទេ ពេលដឹងថាព្រះអង្គﷺចាកចេញនោះ ដូច្នេះព្រះអង្គﷺបានទៅជ្រកក្នុងគុហាភ្នំមួយឈ្មោះ "ស្ទៅរ៍ (ثَوْر)" នៅខាងត្បូងម៉ាក់កាស់តាមផ្លូវទៅម៉ាឌីណាស់ ។

ពលីកម្មរបស់អ៊ីមុាំអាលី(صلوات الله عليه والسلام) កាលព្រះអង្គ(صلوات الله عليه والسلام)យកជីវិតប្តូរជីវិតព្រះសាស្តាមូហាំម៉ាដ់ﷺក្នុងយប់ភៀសខ្លួននោះ គាប់ព្រះហឫទ័យអល់ឡោះហ្ហ៍ﷻណាស់ បានជាអល់ឡោះហ្ហ៍ﷻដាក់មកនូវអាយ៉ាស់នេះគឺ៖

وَمِنَ ٱلنَّاسِ مَن يَشْرِى نَفْسَهُ ٱبْتِغَآءَ مَرْضَاتِ ٱللَّهِ ۗ وَٱللَّهُ رَءُوفٌۢ بِٱلْعِبَادِ ﴿٢٠٧﴾

*207. មនុស្សខ្លះប្តូរជីវិតដើម្បីផ្គាប់ព្រះហឫទ័យអល់ឡោះហ្ទ៍ ។ អល់ឡោះហ្ទ៍អាណិតស្រឡាញ់បាវទាំងឡាយ[បែបនេះ]របស់ព្រះអង្គ ។* (ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 207 (2:207)) ។

ពេលបានដឹងថាព្រះសាស្តាមូហាំម៉ាដ់ﷺបានចាកចេញពីម៉ាក់កាស់ ពួកគូរ៉យ់ស្ហ៍បានចាត់បញ្ជូនមនុស្សទៅស្កាត់ផ្លូវទៅម៉ាឌីណាស់ទាំងអស់ ។ ពួកគេបានជួលមនុស្សជំនាញខាងរកអ្នកដំណើរដោយពិនិត្យមើលដានជើង ។ ពួកគេបានប្រកាសដែរថាអ្នកណាអាចប្រាប់ឲ្យដឹងកន្លែងពួនរបស់ព្រះសាស្តាﷺ អ្នកនោះនឹងបានរង្វាន់អូដ្ឋ ១០០ ក្បាល ។ បុរសជាតិគូរ៉យ់ស្ហ៍ពូកែដើរតាមរកម្នាក់ឈ្មោះ អាប៊ូគូរស៍ (أَبُو كُرْز) បាននាំពួកអ្នកដេញតាមទៅដល់មាត់គុហាភ្នំស្ទៅរ៍ ។ តែពេលគេចូលទៅដល់មាត់រូងនោះគេឃើញមានសំបុកពីងពាងព័ទ្ធមាត់រូងនោះ មានសំបុកលលកព្រៃពងពេញ ។ ពួកអ្នកដេញតាមបានសម្រេចថាបើមានមនុស្សនៅខាងក្នុងរូងនោះមែន ពីងពាងនិងលលកព្រៃមិនធ្វើសំបុកលើមាត់រូងនោះទេ បើមានគេដើរកាត់តាមនេះមែនសំបុកពីងពាងប្រាកដជាដាច់ខូចអស់ ។ ពួកគេក៏បានចោលផ្លូវ



នេះ មិនចូលទៅមើលខាងក្នុងទេ ។ ដូច្នេះ អល់ឡោះហ្ ﷻ បានជួយសង្គ្រោះ ព្រះសាស្តាមូហាំម៉ាដ់ ﷺ ជាទីស្រឡាញ់របស់ព្រះអង្គ ﷻ ដោយអព្ភូតហេតុអស្ចារ្យ ។

ព្រះសាស្តាមូហាំម៉ាដ់ ﷺ បាននៅក្នុងរូងនេះបីថ្ងៃបីយប់ ។ យប់មួយ ក្នុងយប់ទាំងបីនេះ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានមកជួបព្រះអង្គ ﷺ ។ ព្រះសាស្តាមូហាំម៉ាដ់ ﷺ បានឲ្យព្រះអង្គ صلوات الله عليه والسلام រៀបចំអូដ្ឋសម្រាប់ព្រះអង្គ ﷺ និង អាប៊ូ បាការ ។ ព្រះសាស្តា ﷺ បានឲ្យព្រះអង្គ صلوات الله عليه والسلام ទៅប្រកាសឯម៉ាក់កាស្ថៃបន្ទាប់ថា បើអ្នកណាបានផ្ញើរបស់ទុកនឹងព្រះសាស្តា ﷺ ឬបានសូមខ្ចីរបស់ពីព្រះអង្គ ﷺ ចូរអ្នកនោះទូទាត់ជាមួយអ៊ីម៉ាំអាលី صلوات الله عليه والسلام ។ បន្ទាប់មកព្រះអង្គ ﷺ ផ្តាំអ៊ីម៉ាំអាលី صلوات الله عليه والسلام ឲ្យជួយមើលព្រះនាងហ្វាទីម៉ាស់ទាំងបី (ហ្វាទីម៉ាស់ ស្ហាស់រ៉អ៊ុ سلام الله عليها, ហ្វាទីម៉ាស់ ប៊ិនទី អាសាដ់, ហ្វាទីម៉ាស់ ប៊ិនទី ស្ស៊ូបៃរ៍) និងបណ្តាសមាជិក បានី ហ្វាស្ហ៊ីម ឯទៀតដែលចង់ចាកចេញពីម៉ាក់កាស់ ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام ត្រូវនាំដោយផ្ទាល់បុគ្គលទាំងអស់នេះទៅម៉ាឌីណាស់ ។

ថ្ងៃទីបួន អ៊ីម៉ាំអាលី صلوات الله عليه والسلام បានបញ្ជូនអូដ្ឋបីទៅឯរូងភ្នំជាមួយអ្នកនាំផ្លូវជាទីទុកចិត្តម្នាក់ឈ្មោះ អ៊ូរ៉យគ៏ត្ (اُرَيقِط) ។ ព្រះសាស្តាមូហាំម៉ាដ់ ﷺ និង អាប៊ូ បាការ បានធ្វើដំណើរទៅកាន់ម៉ាឌីណាស់ជាមួយបុរសអ្នកនាំផ្លូវ តាមផ្លូវឆ្នេរសមុទ្រដើម្បីចៀសវាងពលសេះគូរ៉យស៍ ។

ចាប់ពីយប់នេះតទៅ ពួកមុស្លីមចាប់ផ្តើមរាប់សករាជអ៊ីស្លាមឬប្រក្រតិទិនហ៊ិជ្ររ៉ោះត៍ ។ ការភៀសខ្លួននេះឯងដែលជាដើមទីនៃការប្រមូលផ្តុំពួកមុស្លីមនៅម៉ាឌីណាស់និងជាការបង្កើតរដ្ឋអ៊ីស្លាមដំបូងបង្អស់ ។

ដំណើរឆ្ពោះទៅម៉ាឌីណាស់មានចម្ងាយ ៤០០ គីឡូម៉ែត្រ ពួកគេច្រើនតែធ្វើដំណើរពេលយប់ សម្រាកពេលថ្ងៃ ។ ទោះបីពួកគេប្រយ័តប្រយែងក៏ដោយ បុរសម្នាក់បានឃើញពួកគេហើយទៅរាយការណ៍ប្រាប់ពួកគូរ៉យស៍នៅម៉ាឌីណាស់ ។

ព្រោះតែចង់បានរង្វាន់តែម្នាក់ឯង បុរសម្នាក់ឈ្មោះ សារ៉ាក្វោះត៍ (سراقة) បានធ្វើឲ្យពួកគូរ៉យស៍ជឿថាបុរសនោះបានឃើញអ្នកផ្សេងទៀត ថាដេញតាមពួកនោះ

ជាការខាតពេលទេ ។ គាត់បានមកផ្ទះ បានប្រដាប់អាវុធ ហើយបានជិះសេះលឿនទៅកាន់កន្លែងដែលគេបានឃើញព្រះសាស្ដាមូហាំម៉ាដ់ﷺ និងបក្សពួកព្រះអង្គﷺ ។ សារ៉ាកោះត៍ជាបុរសមាឌធំ អាប៊ូ បាការ បារម្ភណាស់ពេលគាត់ចូលមកជិតដល់ ។ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានប្រាប់ អាប៊ូ បាការ ដូចកាលមុនដែរ កាលគេជិតរកព្រះអង្គﷺនិងគាត់ឃើញនៅឯរូងភ្នំស្ងៅរ៍ ថា៖

إِلَّا تَنصُرُوهُ فَقَدْ نَصَرَهُ ٱللَّهُ إِذْ أَخْرَجَهُ ٱلَّذِينَ كَفَرُوا۟ ثَانِىَ ٱثْنَيْنِ إِذْ هُمَا فِى ٱلْغَارِ إِذْ يَقُولُ لِصَـٰحِبِهِۦ لَا تَحْزَنْ إِنَّ ٱللَّهَ مَعَنَا ۖ فَأَنزَلَ ٱللَّهُ سَكِينَتَهُۥ عَلَيْهِ وَأَيَّدَهُۥ بِجُنُودٍ لَّمْ تَرَوْهَا وَجَعَلَ كَلِمَةَ ٱلَّذِينَ كَفَرُوا۟ ٱلسُّفْلَىٰ ۗ وَكَلِمَةُ ٱللَّهِ هِىَ ٱلْعُلْيَا ۗ وَٱللَّهُ عَزِيزٌ حَكِيمٌ ﴿٤٠﴾

*40. បើពួកអ្នកមិនជួយគេទេ (គឺមូហាំម៉ាដ់) អល់ឡោះហ៊្វបានជួយគេរួចស្រេចហើយ កាលពួកបដិសេធសទ្ធា[ដែលជាសត្រូវ]បានបណ្ដេញគេចេញ គេជាជនទីពីរ (គឺមានគ្នាតែម្នាក់គត់) ក្នុងចំណោមអ្នកទាំងពីរ កាលគេទាំងពីរនៅក្នុងរូងភ្នំ គេ (មូហាំម៉ាដ់) បានប្រាប់មិត្តគេថា៖ "លោកកុំបារម្ភ អល់ឡោះហ៊្វនៅជាមួយយើង ។" ដូច្នេះអល់ឡោះហ៊្វបានប្រទានភាពស្ងប់នៃព្រះអង្គចុះមកលើគេ (គឺសាស្ដា) បានពង្រឹងកម្លាំងគេដោយទ័ព (គឺទេវតា) ដែលពួកអ្នកមើលមិនឃើញ ហើយព្រះអង្គបានបន្ថោកពាក្យសំដីរបស់ពួកបដិសេធសទ្ធា រីឯព្រះបន្ទូលអល់ឡោះហ៊្វឧត្ដម ខ្ពង់ខ្ពស់លើសលុប ។ អល់ឡោះហ៊្វទ្រង់មានព្រះមហិទ្ធិឫទ្ធិ ព្រះអង្គជាព្រះមុនិរាជ ។* (ស៊ូរ៉ោះត៍ អាត់-តៅបាស្ញ់ អាយ៉ាស្ញ់ 40 (9:40)) ។

ចន្លោះពេលនោះ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានបួងសួងអល់ឡោះហ៊្វعزّ وجلّ សូមឲ្យថែរក្សាការពារពីបំណងអាក្រក់របស់សារ៉ាកោះត៍ ។ រំពេចនោះ បុរសនេះធ្លាក់ពីលើខ្នងសេះយ៉ាងធ្ងន់ ។ គាត់ដឹងភ្លាមថានេះមិនមែនឧប្បត្តិហេតុធម្មតាទេ តែជាការព្រមានឲ្យគាត់ប្រយ័តខ្លួនដែលមានបំណងអាក្រក់នោះ ។ ដូច្នេះគាត់បានបែរទៅរកព្រះសាស្ដាមូហាំម៉ាដ់ﷺ សូមខមាទោសព្រះអង្គﷺ សូមជួយព្រះអង្គﷺស្រេចតែព្រះអង្គﷺបញ្ជា ។ ព្រះសាស្ដាﷺបានប្រាប់ឲ្យគាត់ត្រឡប់ទៅម៉ាក់កាស្ញ់វិញ ទៅហាមគេកុំឲ្យដេញតាមព្រះអង្គﷺ ។ សារ៉ាកោះត៍ក៏បានមកម៉ាក់កាស្ញ់វិញ ប្រាប់អ្នកដែលគាត់ជួបថាពុំបានឃើញស្លាកស្នាមឬដានព្រះសាស្ដាមូហាំម៉ាដ់ﷺទេ ។

ថ្ងៃទី ១២ ខែ រ៉ប៊ីអ៊ុល-អៅវ៉ាល់ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានទៅដល់ភូមិគូបាអ៊ុ (قباء) ជាយស្រុកម៉ាឌីណាស្ញ់ ។ ព្រះអង្គﷺរង់ចាំប្អូនជីតាមួយរបស់ព្រះអង្គ

صلى الله عليه وآله وسلم អ៊ីមុាំអាលី صلوات الله عليه والسلام នៅទីនេះ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានទៅជ្រកនៅកន្លែងណាពីពួកគូរ៉យស្ទ៍ ?

២. អល់ឡោះហ្ទ៍عز وجلបានការពារព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم ដោយអព្ភូតហេតុអ្វីកាលព្រះអង្គصلى الله عليه وآله وسلمគេចខ្លួនពីពួកគូរ៉យស្ទ៍ ?

៣. ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានផ្តាំអ៊ីម៉ាំអាលីصلوات الله عليه والسلامបីប្រការ កាលអ៊ីម៉ាំអាលីصلوات الله عليه والسلامមកជួបព្រះអង្គصلى الله عليه وآله وسلم មានប្រការអ្វីខ្លះ ?

៤. ព្រឹត្តិការណ៍ណាជាដើមទីនៃសករាជអ៊ីស្លាម និងជាប្រក្រតិទិនហ៊្ញីចូរ៉ោះត្ទ៍ហេតុអ្វី ?

៥. ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានជួយសម្រាលទុក្ខ អាប៊ូ បាការ ដូចម្តេច ?

## មេរៀនទី ១៣

# ហ៊ីចរ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ៣

ភូមិគូបាអ៊ុំជាមជ្ឈដ្ឋាននៃប្រជាជាតិ បានី អៅហ្វ៍ ។ ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم បានមកឈប់នៅទីនេះ បានស្នាក់នៅឯលំនៅរបស់មេដឹកនាំប្រជាជាតិនេះ ។ នៅឯភូមិគូបាអ៊ុំ មានមុស្លីមច្រើនរង់ចាំជូនដំណើរព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمទៅម៉ាឌីណាស់ មិនឆ្ងាយពីភូមិនេះទេ ។ ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمបានស្នាក់នៅភូមិនេះពីរបីថ្ងៃព្រោះព្រះអង្គصلى الله عليه وآله وسلمរង់ចាំអ៊ីម៉ាំអាលីصلوات الله عليه والسلام ។ ក្នុងអំឡុងពេលនេះ ព្រះអង្គصلى الله عليه وآله وسلمបានរៀបចំចាក់គ្រឹះសាងសង់ម៉ាស់យ៊ិដមួយឲ្យប្រជាជាតិ បានី អៅហ្វ៍ ។ ម៉ាស់យ៊ិដនេះជាម៉ាស់យ៊ិដដំបូងបង្អស់នៃប្រវត្តិសាស្ត្រអ៊ីស្លាម ។

ចន្លោះពេលនេះនៅឯម៉ាក់កាស់ អ៊ីម៉ាំអាលីصلوات الله عليه والسلامបានប្រាប់គេថាអ្នកណាបានផ្ញើរបស់ទុកនឹងព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم អ្នកនោះអាចមកយករបស់នោះវិញបាន ។ ព្រះអង្គصلوات الله عليه والسلامបាននៅម៉ាក់កាស់បីថ្ងៃទាល់តែបានប្រគល់របស់ទាំងអស់ឲ្យទៅម្ចាស់ពិតប្រាកដវិញ ។ បន្ទាប់មកព្រះអង្គصلوات الله عليه والسلامបានប្រមូលស្ត្រីទាំងអស់នៃគ្រួសារព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم និងមុស្លីមឯទៀតដែលមានសល់នៅឯម៉ាក់កាស់ ហើយត្រៀមខ្លួនចេញដំណើរ ។ ក្រុមនេះបានចាកចេញទៅម៉ាឌីណាស់ពេលយប់ ។

ពួកលបយកការណ៍គូរ៉យ៉ស្ស៍បានដឹងថា ក្រុមមុស្លីមចុងក្រោយនេះបានលបរត់ ហើយក៏បានដេញតាម ។ ពួកគេបានទៅទាន់អ៊ីម៉ាំអាលីصلوات الله عليه والسلامនៅឯកន្លែងមួយហៅថា "ដូជ្ញ៉ាណាន់ (ضَجْنَان)" ។ ពួកគូរ៉យ៉ស្ស៍ទាមទារឲ្យពួកមុស្លីមត្រឡប់ទៅម៉ាក់កាស់វិញ ក្រុមទាំងពីរបានឆ្លើយឆ្លងគ្នាដោយសម្តីធ្ងន់ៗ ។ ពួកគូរ៉យ៉ស្ស៍ធ្វើឲ្យបណ្តាស្ត្រីបារម្ភ អ៊ីម៉ាំអាលីصلوات الله عليه والسلامដឹងថាពុំមានមធ្យោបាយការពារពួកមុស្លីមផ្សេងពីដោយប្រើកម្លាំងទេ ។ ព្រះអង្គصلوات الله عليه والسلامបែរទៅរកពួកគូរ៉យ៉ស្ស៍ ថា៖ "អ្នកណាចង់ដាច់ខ្លួនជាកំណាត់ៗ ចង់ហូរឈាម ចូរអ្នកនោះចូលមក ។" ពេលឃើញទឹកមុខអ៊ីម៉ាំអាលីصلوات الله عليه والسلامប្រកបដោយសេចក្តីប្តេជ្ញាចិត្តមុតមាំ ពួកគូរ៉យ៉ស្ស៍ប្រែអាកប្បកិរិយា បើកផ្លូវឲ្យទៅ ។ អ៊ីម៉ាំអាលីصلوات الله عليه والسلامបានដឹកនាំក្រុមព្រះអង្គصلوات الله عليه والسلامឆ្ពោះទៅភូមិគូបាអ៊ុំ បីថ្ងៃ

ក្រោយព្រះសាស្តាﷺបានទៅដល់ ។ ជើងព្រះអង្គصلوات الله عليه والسلامហើមនិងចេញឈាម បណ្តាលឲ្យព្រះសាស្តាﷺទឹកភ្នែករលេងរលោង ។

មួយថ្ងៃក្រោយអ៊ីម៉ាំអ៊ាលីصلوات الله عليه والسلامបានមកដល់ ព្រះសាស្តាមូហាំម៉ាដ់ﷺបាន ចាកចេញទៅម៉ាឌីណាស់ ។ ពួកមូហាជៀរ (مُهَاجِرٌ គឺពួកមុស្លីមភៀសខ្លួនស្រុក ម៉ាក់កាស់) និងពួកអាន់សោរ៍ (أَنْصَار គឺពួកមុស្លីមស្រុកម៉ាឌីណាស់) តម្រៀបជួរគ្នា ហូរហែតាមផ្លូវម៉ាឌីណាស់ដោយរំជួលចិត្ត ចាំទទួលព្រះសាស្តាមូហាំម៉ាដ់ﷺ ។ ពេលអូដ្ឋព្រះអង្គﷺឈប់នៅឯកន្លែងមួយហៅថា "ស្ហានីយ៉ាទុល-វ៉ាដាអ៊ុ៍ (ثَنِيَّةَ الْوَدَاعِ)" ព្រះអង្គﷺបានចុះពីលើជំនិះ គេបានអបអរសាទរ ទទួលព្រះអង្គﷺដោយសូត្រ កំណាព្យនេះគឺ៖ "ខែរះដើម្បីយើងពី ស្ហានីយ៉ាទុល-វ៉ាដាអ៊ុ៍ យើងគប្បីដឹងព្រះគុណ ដែលបានទទួលព្រះពរនេះ រហូតដល់ថ្ងៃដែលទោះបីនៅលើផែនដីនៅសល់តែ មនុស្សម្នាក់បួងសួងអល់ឡោះហ្វ៍عزّ وجلّនិងធ្វើសក្ការៈព្រះអង្គعزّ وجلّក៏ដោយ ។"

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ម៉ាស់ឃ្ជិដជំបូងបង្អស់នៃប្រវត្តិសាស្ត្រអ៊ីស្លាមនៅឯណា អ្នកណាបានចាប់ផ្តើមសាងសង់ម៉ាស់ឃ្ជិដនេះ ?

២. ហេតុអ្វីអ៊ីម៉ាំអាលី صلوات الله عليه والسلام បានចាំបីថ្ងៃនៅម៉ាក់កាស់ មុននឹងចាកចេញទៅរកព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ?

៣. អ៊ីម៉ាំអាលី صلوات الله عليه والسلام បាននាំក្រុមព្រះអង្គ صلوات الله عليه والسلام ពុះពារពួកគូរ៉យស្ស៍ស្កាត់ផ្លូវដូចម្តេច ?

៤. ពួកមូហាជៀរនិងពួកអាន់ស្វារ៍ជាអ្នកណា ?

៥. "ខែ" មានន័យថាអ្វីពេលពួកអ្នកស្រុកម៉ាឌីណាស្វូត្រកំណាព្យថា "ខែរះដើម្បីយើង..." នោះ ?

**មេរៀនទី ១៤**

# ហ៊ីច្រ៉ោះត៍ឬការភៀសខ្លួនទៅម៉ាឌីណាស់ - ភាគ ៤

ពេលព្រះសាស្តាមូហាំម៉ាដ់ﷺបានមកដល់ម៉ាឌីណាស់ ពួកមុស្លីមបានធ្វើពិធីទទួលដោយអបអរសាទរដ៏គគ្រឹកគគ្រេង ។ ពេលអូដ្ឋបានចូលមកក្នុងនគរម៉ាឌីណាស់ ពួកមេដឹកនាំប្រជាជាតិនានាស្ទុះទៅចាប់ខ្សែបង្ហៀរអូដ្ឋ ម្នាក់ៗទទូចសូមទទួលព្រះសាស្តាមូហាំម៉ាដ់ﷺទៅស្នាក់នៅឯលំនៅដ្ឋានខ្លួន ជាភ្ញៀវរុងរឿង ។ ដើម្បីកុំឲ្យគេអាក់អន់ចិត្ត ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ទុកឲ្យអូដ្ឋដើរ ខ្ញុំﷺនឹងស្នាក់នៅកន្លែងណាដែលវាអង្គុយ ។" ទាំងអស់គ្នាសម្លឹងមើលដោយយកចិត្តទុកដាក់កន្លែងដែលអូដ្ឋចង់ទៅឈប់ ។ ទីបំផុតអូដ្ឋអង្គុយក្នុងលានធំមួយរបស់កូនប្រុសកំព្រាពីរនាក់ឈ្មោះ សាស្ល៍ (سَهْل) និង ស៊ូហៃល៍ (سُهَيْل) ។ ធ្លានេះប្រើសម្រាប់ហាលផ្លែលម៉ើនិងសម្រាប់កសិកម្ម ។ ផ្ទះដែលនៅជិតជាងគេគឺផ្ទះរបស់ អាប៊ូ អៃយូប អាន់ស៊ូរី (أَبُو أَيُّوبَ الْأَنْصَارِيُّ) ។ នេះជាឱកាសល្អសម្រាប់ម្ដាយលោក គាត់បានចាប់យកកម្មសិទ្ធិរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺយ៉ាងលឿនទៅឯផ្ទះគាត់ ។ ការប្រជែងគ្នាអញ្ជើញព្រះសាស្តាមូហាំម៉ាដ់ﷺទៅសោយបាយឯផ្ទះខ្លួនក៏បានចាប់ផ្ដើម តែព្រះសាស្តាﷺបានដឹងថាកម្មសិទ្ធិនានារបស់ព្រះអង្គﷺនៅឯផ្ទះ អាប៊ូ អៃយូប អាន់ស៊ូរី ដូច្នេះព្រះអង្គﷺបានសម្រេចព្រះទ័យជាភ្ញៀវរបស់លោកនិងម្ដាយលោក អស់រយៈពេលប្រមាណប្រាំពីរខែ ដើម្បីទុកពេលនេះសាងសង់ផ្ទះព្រះអង្គﷺនៅក្បែរម៉ាស់ឃ្ជិដ ។

ព្រះសាស្តាមូហាំម៉ាដ់ﷺចង់សង់ម៉ាស់ឃ្ជិដមួយ លើធ្លាដីដែលអូដ្ឋបានទៅឈប់ ។ កូនកំព្រាម្ចាស់ដីនេះចង់ឲ្យដីនេះមកព្រះសាស្តាﷺតែព្រះអង្គﷺបដិសេធហើយបានសូមទិញដីនេះថ្លៃ ១០ ឌីណារ៍មាស ។

បន្ទាប់ពីបានទិញដីហើយ គេបានសម្អាតធ្លានេះឲ្យអស់ដើមឈើ ហើយបានសង់ម៉ាស់ឃ្ជិដមួយធ្វើពីដីឥដ្ឋល្បាប់ មានទំហំ ៥០ ម៉ែត្រទទឹង ៥៥ ម៉ែត្របណ្ដោយ ។ ដំបូលធ្វើដោយឈើត្នោត ប្រក់ធាងនិងស្លឹកត្នោត ។ ខាងមួយនៃម៉ាស់ឃ្ជិដ គេបានសង់លំនៅសម្រាប់ព្រះសាស្តាមូហាំម៉ាដ់ﷺនិងគ្រួសារព្រះអង្គ

ﷺ ម្ខាងទៀតគេបានសង់ប្រមាណ ៧០ បន្ទប់សម្រាប់ជនក្រីក្រស្រុកម៉ាឌីណាស់គ្មានលំនៅ ។ គេហៅបន្ទប់ទាំងនេះថា "ស្វ៊ុហ្វហ្វាស់ (الصُّفَّة)" ។ ការសំណង់ត្រូវបែងចែកស្មើគ្នារវាងពួកមូហាជៀរ (គឺជនចំណាកស្រុកម៉ាក់កាស់) និងពួកអាន់ស្វ៉ារ៍ (គឺពួកអ្នកម៉ាឌីណាស់) ។ ព្រះសាស្តាមូហ្ហាំម៉ាដ់ﷺផ្ទាល់ក៏បានចូលរួមក្នុងការនេះដែរ ទោះបី អុំម៉ារ ប៊ិន យ៉ាសៀរ សាវកភ័ក្តីរបស់ព្រះអង្គﷺដែលបានចូលសាសនាអ៊ីស្លាមមុនគេនោះ ព្យាយាមឃាត់ព្រះអង្គﷺក៏ដោយ លោកធ្វើការព្រះសាស្តាﷺជួសព្រះអង្គﷺ ។

អុំម៉ារបានចាប់ផ្តើមការសាងគ្រឹះម៉ាស់យ៊ិដ់មុនគេ ។ ថ្ងៃមួយ ខណៈដែលព្រះសាស្តាមូហ្ហាំម៉ាដ់ﷺបោសធូលីពីលើខ្លួនលោក ព្រះអង្គﷺបានប្រាប់លោកថា៖ "អុំម៉ារអើយ លោកនឹងត្រូវក្រុមទមិឡសង្កត់សង្កិនគេសម្លាប់ខណៈដែលលោកហៅពួកគេនោះមកកាន់សច្ចធម៌ ។"

ព្រះទំនាយនេះល្បីណាស់ ៣៨ ឆ្នាំក្រោយមក អុំម៉ារ បានទទួលមរណៈភាពក្បែរអ៊ីម៉ាំអាលីصلوات الله عليه والسلامកាលប្រយុទ្ធទល់នឹងមូអាវីយ៉ាស់ឯសមរភូមិស្វ៊ិហ្វហ្វីន ។ កាលនោះរេហ៍ពលច្រើនរបស់មូអាវីយ៉ាស់ដឹងខ្លួនថានៅខាងខុស ហើយក៏បានរត់ចោលបុរសកំណាចរូបនេះ ។

ទោះបីទម្រង់ម៉ាស់យ៊ិដ់មានលក្ខណៈសាមញ្ញមែនក៏ដោយ តែវាជាម៉ាស់យ៊ិដ់ប្រសើរបំផុតក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ។ ម៉ាស់យ៊ិដ់នេះបានក្លាយទៅជាមជ្ឈមណ្ឌលកិច្ចការរបស់មុស្លីមនៃនគរម៉ាឌីណាស់ ។ ស្វ៉ឡាត់ប្រចាំថ្ងៃនិងស្វ៉ឡាត់ថ្ងៃសុក្របានប្រព្រឹត្តទៅនាទីនេះ ។ ព្រះសាស្តាមូហ្ហាំម៉ាដ់ﷺបានបង្ហាត់បង្រៀនមនុស្សឲ្យចេះដឹងព្រះសាសនាអល់ឡោះហ្វ៊عزّ وجلّពីម៉ាស់យ៊ិដ់នេះ មនុស្សរាប់ពាន់នាក់បានទៅជាមុស្លីម ។ គេបានដាក់ឈ្មោះម៉ាស់យ៊ិដ់នេះថា ម៉ាស់យ៊ិឌុន-ណាបាវី (المسجد النبوي) នៅតែគង់វង្សដដែលសព្វថ្ងៃនេះនៅឯម៉ាឌីណាស់ ទោះបីវាធំជាងមុនក៏ដោយ ។

មុនព្រះសាស្តាមូហ្ហាំម៉ាដ់ﷺបានភៀសខ្លួន ម៉ាឌីណាស់មានឈ្មោះថា យ៉ាស់រីប តែក្រោយពីព្រះអង្គﷺបានមកដល់ ស្រុកនេះមានឈ្មោះថា ម៉ាឌីណាទុន-ណាប៊ី (مَدِينَةُ النَّبِيِّ មានន័យថាស្រុករបស់ព្រះសាស្តាﷺ) ឬហៅខ្លីថា ម៉ាឌីណាស់ ។

ប្រក្រតិទិនសករាជហ៊ីជ្រ៉ោះត៍មុស្លីមបានចាប់ផ្តើមឡើងឆ្នាំនេះឯង ។ ដូច្នេះ

ព្រះសាស្តាមូហាំម៉ាដ្ទ ﷺ បានមកដល់នគរម៉ាឌីណាស្ទុំកាលពី ១៤៤២ ឆ្នាំមុន ។

សូមអល់ឡោះហ្វ៍ عزوجل ប្រទានកម្លាំងនិងសេចក្តីប្តេជ្ញាចិត្តឲ្យយើងរាល់គ្នា ដើម្បីនឹងអាចបាននៅលើមាគ៌ាព្រះសាសនាដែលព្រះសាស្តា មូហាំម៉ាដ្ទ អាល់-មុស្ទហ្វ៉ា صلوات الله عليه والسلام បានបង្ហាត់បង្រៀន ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. គេបានសម្រេច ជ្រើសយកកន្លែងធ្វើលំនៅរបស់ព្រះសាស្តាមូហាំម៉ាត់ﷺ ដូចម្តេច ? កន្លែងនេះនៅឯណា ?

២. ម៉ាស់ជិដរបស់ព្រះសាស្តាមូហាំម៉ាត់ﷺត្រូវសាងសង់នៅកន្លែងណា ?

៣. គេបានសាងសង់អ្វីទៀតនៅក្បែរម៉ាស់ជិដ ? សម្រាប់អ្នកណា ?

៤. តើព្រះសាស្តាមូហាំម៉ាត់ﷺមានព្រះទំនាយថាអ្វីអំពី អាំម៉ារ ? តើព្រះទំនាយនេះបានទៅជាពិតកាលណា ?

៥. យ៉ាស្រិបមានឈ្មោះថាអ្វីសព្វថ្ងៃនេះ ? ហេតុអ្វី ?

## មេរៀនទី ១៥

# ព្រះសាស្ដា អ៊ីបរ៉ហ៊ីម عليه السلام - ភាគ ១

ព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ជាព្រះសាស្ដាល្បីល្បាញមួយអង្គ ក្នុងចំណោមព្រះសាស្ដាល្បីល្បាញបំផុតឯទៀតរបស់អល់ឡោះហ៊្ O عز وجل ។ ព្រះមហាគម្ពីរគួរអានថែងថា៖

إِنَّ إِبْرَٰهِيمَ كَانَ أُمَّةً قَانِتًا لِّلَّهِ حَنِيفًا وَلَمْ يَكُ مِنَ ٱلْمُشْرِكِينَ ﴿١٢٠﴾ شَاكِرًا لِّأَنْعُمِهِ ٱجْتَبَىٰهُ وَهَدَىٰهُ إِلَىٰ صِرَٰطٍ مُّسْتَقِيمٍ ﴿١٢١﴾ وَءَاتَيْنَٰهُ فِى ٱلدُّنْيَا حَسَنَةً وَإِنَّهُۥ فِى ٱلْءَاخِرَةِ لَمِنَ ٱلصَّٰلِحِينَ ﴿١٢٢﴾

*120. អ៊ិបរ៉ហ៊ីមជាសហគមន៍មួយដែលស្ដាប់បង្គាប់អល់ឡោះហ៊្ ទៀងត្រង់ ហើយគេមិននៅក្នុងចំណោមពួកពហុទេពនិយមទេ ។ 121. គេមានកតញ្ញូតាចំពោះព្រះឧបការគុណព្រះអង្គ ។ ព្រះអង្គបានជ្រើសរើសគេ បានដឹកនាំគេនៅលើមាគ៌ាត្រង់ត្រូវ ។ 122. យើងបានប្រទានឲ្យគេក្នុងលោកនេះនូវមួយចំណែកដ៏បវរ នាលោកមុខគេនឹងបាននៅក្នុងចំណោមជនដែលប្រកបដោយព្រហ្មចរិយធម៌ ។* (ស៊ូរ៉ោះតុ័អាន់-ណាស្ល៍ អាយ៉ាស្ 120-122 (16:120-122))



ព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ប្រសូតនៅឯដែនដីស៊ីរីសម័យស្ដេចណាំរូដ (نمرود) لعنه الله សោយរាជ្យ ។ ណាំរូដ لعنه الله ជាបុគ្គលប្រកាន់ឫក បង្ខំមនុស្សឲ្យធ្វើសក្ការៈខ្លួនដូចព្រះ ។ មនុស្សក៏បានទៅជាអ្នកធ្វើសក្ការៈរូបបដិមា និងបុគ្គល ។ ពួកគេធ្វើសក្ការូបព្រះធ្វើអំពីឈើ និងថ្មស្រាប់ហើយដូច្នេះពួកគេព្រមធ្វើសក្ការៈណាំរូដ لعنه الله ជាព្រះដោយពេញចិត្ត ។ ក្រោយមក អល់ឡោះហ៊្ عز وجل បានចាត់បញ្ជូនព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ទៅដឹកនាំពួកគេនៅលើមាគ៌ាត្រូវ ។

មុនព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ប្រសូត ពួកហោរបានបានប្រាប់ណាំរូដ لعنه الله ថានឹងមានក្មេងពិសេសម្នាក់ចាប់កំណើត ក្មេងនេះនឹងប្រឆាំងខ្លួន នឹងប្រាប់មនុស្សឲ្យបោះបង់ចោលការធ្វើសក្ការៈរូបបដិមានិងបុគ្គលជាព្រះ ។ បន្ទាប់មក ណាំរូដ لعنه الله បានបញ្ជាឲ្យគេពិនិត្យមើលទារកដែលទើបនឹងកើតឲ្យហ្មត់ចត់

ដើម្បីនឹងស្គាល់ភិនភាគឬលក្ខណៈអស្ចារ្យ ។

មាតាព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامមិនមានសញ្ញាបញ្ជាក់ថា ព្រះនាងមានផ្ទៃពោះទេកាលព្រះនាងទម្ងន់ព្រះអង្គعليه السلام ដូច្នេះព្រះនាងដឹងថាកូនព្រះនាងមិនធម្មតាទេ ។ ដើម្បីការពារកូនពីបក្សពួករបស់ណាំរូដلعنه الله ព្រះនាងបានលាក់កូននៅក្នុងរូងមួយ ហើយត្រឡប់ទៅក្នុងស្រុកវិញ ។ អល់ឡោះហ៍عز وجلបានធ្វើឲ្យទឹកដោះហូរចេញមកពីម្រាមដៃព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامដើម្បីជាអាហាររបស់ព្រះអង្គعليه السلام ។

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានធាត់ធំនៅឆ្ងាយពីមនុស្សម្នាក្នុងស្រុកអស់ ១៣ ឆ្នាំទើបមាតាព្រះអង្គعليه السلامនាំព្រះអង្គعليه السلامទៅផ្ទះដោយសម្ងាត់ ។ តារ៉ក់ (ឬតារីក) ឪពុកព្រះអង្គعليه السلام បានស្លាប់ហើយ ឪពុកមា (ឬឪពុកធំ) របស់ព្រះអង្គعليه السلامឈ្មោះអាស្សារ៍ បានយកព្រះអង្គعليه السلامទៅចិញ្ចឹម ។ អាស្សារ៍ជាជាងចម្លាក់ល្បីម្នាក់ដែលឆ្លាក់រូបព្រះពីថ្ម ។ កូនប្រុសគាត់យករូបព្រះនោះទៅលក់ឲ្យគេ ។ អាស្សារ៍បានឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامធ្វើការនេះដែរ ។

តាំងពីព្រះអង្គعليه السلامនៅកុមារភាពម្ល៉េះ ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامជឿអល់ឡោះហ៍عز وجلស្រាប់ហើយ ស្អប់រូបព្រះ ។ ថ្ងៃធ្វើការដំបូង ព្រះអង្គعليه السلامបានយកខ្សែចងរូបព្រះពីរបី ដើរអូសលើដីលុះទៅដល់ផ្សារ ។ បន្ទាប់មកព្រះអង្គعليه السلامស្រែកអំពាវនាវថា៖ "មកទិញរូបព្រះគ្មានជីវិត ដែលមិនអាចផ្តល់ផលប្រយោជន៍ មិនអាចផ្តល់ផលអាក្រក់ឲ្យអ្នកណាបានឡើយ ។" ពេលឃើញរូបព្រះប្រឡាក់ដី មនុស្សម្នាក្រោធណាស់ដែលព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام មិនគោរពព្រះទាំងឡាយរបស់ខ្លួន ។ ពួកគេបានទៅប្តឹងអាស្សារ៍ គេក៏លែងឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ដើរលក់រូបព្រះនោះទៀត ។



អំណឹះតមក ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامព្យាយាមបង្ហាញមនុស្សឲ្យឃើញថាជំនឿពួកគេនោះមិនត្រឹមត្រូវទេ ។ ដំបូងព្រះអង្គعليه السلامទាក់ទងឪពុកធំ (ឬឪពុកមា) ព្រះអង្គعليه السلام ដែលប្រៀបបាននឹងឪពុកបង្កើតសម្រាប់ព្រះអង្គعليه السلام ប្រាប់លោកឲ្យធ្វើសក្ការៈអល់ឡោះហ៍عز وجل ចោលរូបព្រះ ។

ព្រះមហាគម្ពីរគួរអានថែងអំពីការសន្ទនារវាងព្រះអង្គعليه السلامនិងឪពុកមា (ឬ

ឪពុកធំ) ព្រះអង្គﷺថា៖

يَٰٓأَبَتِ لَا تَعۡبُدِ ٱلشَّيۡطَٰنَۖ إِنَّ ٱلشَّيۡطَٰنَ كَانَ لِلرَّحۡمَٰنِ عَصِيّٗا ﴿٤٤﴾ يَٰٓأَبَتِ إِنِّيٓ أَخَافُ أَن يَمَسَّكَ عَذَابٞ مِّنَ ٱلرَّحۡمَٰنِ فَتَكُونَ لِلشَّيۡطَٰنِ وَلِيّٗا ﴿٤٥﴾ قَالَ أَرَاغِبٌ أَنتَ عَنۡ ءَالِهَتِي يَٰٓإِبۡرَٰهِيمُۖ لَئِن لَّمۡ تَنتَهِ لَأَرۡجُمَنَّكَۖ وَٱهۡجُرۡنِي مَلِيّٗا ﴿٤٦﴾ قَالَ سَلَٰمٌ عَلَيۡكَۖ سَأَسۡتَغۡفِرُ لَكَ رَبِّيٓۖ إِنَّهُۥ كَانَ بِي حَفِيّٗا ﴿٤٧﴾

*44. លោកឪពុកអើយ (មា ឬ អ៊ំ) សូមលោកឪពុកកុំគោរពបូជាមារស្ហៃតន ។ ពិតណាស់ មារស្ហៃតនបានប្រឆាំងព្រះដ៏មានព្រះមេត្តាធម៌ ។ 45. លោកឪពុកអើយ (មា ឬ អ៊ំ) [បើមា ឬ អ៊ំធ្វើគោរពមារស្ហៃតន] ខ្ញុំខ្លាចតែការផ្តន្ទាទោសរបស់ព្រះដ៏មានព្រះមេត្តាធម៌ នឹងពើបពះលើលោកឪពុកទេ ដូច្នេះលោកឪពុកនឹងទៅជាកនរបស់មារស្ហៃតន ។" 46. គេ (ឪពុកមា ឬ អ៊ំ) បានថា៖ "តើឯងស្អប់ព្រះអញឬអ៊ីបរ៉ហ៊ីម ? បើឯងមិនឈប់ទេ អញនឹងប្រហារឯងដោយដុំថ្ម ។ ចូរឯងចេញឲ្យផុតពីមុខអញឲ្យយូរទៅ ។" 47. គេ (អ៊ិបរ៉ហ៊ីម) បានថា៖ "សូមលោកឪពុក (លោកមា ឬ លោកអ៊ំ) ប្រកបដោយសេចក្តីសុខ សេចក្តីសប្បាយ ។ ខ្ញុំនឹងសូមអភ័យទោសពីព្រះម្ចាស់ខ្ញុំឲ្យលោកឪពុក ព្រះអង្គប្រោសប្រណីខ្ញុំជានិច្ច ។* (ស៊ូរ៉ោះត៍ ម៉ារយ៉ាំ អាយ៉ាស់ 44-47 (19:44-47)) ។

ទោះបីអាស្ស៊ារ៍មិនស្តាប់ព្រះអង្គعليه السلامក៏ដោយ ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامមិនអស់សង្ឃឹមទេ ព្រះអង្គعليه السلامប្រកាសហៅប្រជារាស្ត្រថា៖ "រូបព្រះរបស់អស់លោកឮអស់លោកទេ វាអាចជួយអស់លោកបានទេ វាអាចធ្វើអាក្រក់ដល់អស់លោកបានទេ ?" ពួកគេតបថា៖ "យើងធ្វើសក្ការៈរូបព្រះព្រោះដូនតាយើងធ្វើសក្ការៈរូបព្រះដែរ ។" ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានប្រាប់ពួកគេថាមានតែអល់ឡោះហ៊្ជَلَّ عَزَّ وَ ព្រះអ្នកបង្កើតមេឃនិងដីទេដែលស័ក្តិសមជាទីសក្ការៈបូជា ។ ទោះបីមនុស្សមិនអាចឆ្លើយតបសម្តីព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامជំទាស់រូបព្រះពួកគេនោះបានក៏ដោយ តែពួកគេនៅតែចចេស មានតែពីរបីអ្នកប៉ុណ្ណោះដែលស្តាប់ព្រះអង្គعليه السلام ធ្វើសក្ការៈអល់ឡោះហ៊្عَزَّ وَجَلَّ ។ បន្ទាប់មក ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានសម្រេចចិត្តបង្ហាញមនុស្សឲ្យឃើញថារូបព្រះពួកគេនោះឥតប្រយោជន៍ ដោយវាយកម្ទេចវាចោល ។ ព្រះអង្គعليه السلامយកឱកាសបុណ្យខួបប្រចាំឆ្នាំ ដែលគេរៀបចំឡើងនៅក្រៅស្រុក ។ ដល់ថ្ងៃបុណ្យ ពេលទាំងអស់គ្នា ក្មេង ចាស់ បានចាកចេញពីក្នុងស្រុកអស់ ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامនៅតែឯង ។ ព្រះអង្គعليه السلامទៅដល់វិហារធំមួយដែលមានរូប



ព្រះធំៗ ។ ព្រះអង្គعليه السلام បានយកពូថៅ វាយបំបាក់ រូបព្រះទាំងអស់ ទុករូបព្រះធំជាងគេ តែមួយ ។ រូបព្រះដែលគេបានរៀបទុក និងថែរក្សាដោយផ្ចិតផ្ចង់នោះ ត្រូវបែកបាក់ខ្ទេចខ្ទី ពាសពេញដី ។ មុនចេញពីក្នុងវិហារ ព្រះសាស្តា អ៊ីបរ៉ហ៊ីមعليه السلامបានដាក់ពូថៅក្នុងដៃរូបព្រះធំជាងគេដែលមិនបាក់បែកនោះ ។

ព្រះគម្ពីរគួរអានចែងថា៖

إِذْ قَالَ لِأَبِيهِ وَقَوْمِهِۦ مَا هَٰذِهِ ٱلتَّمَاثِيلُ ٱلَّتِىٓ أَنتُمْ لَهَا عَٰكِفُونَ ﴿٥٢﴾ قَالُوا۟ وَجَدْنَآ ءَابَآءَنَا لَهَا عَٰبِدِينَ ﴿٥٣﴾ قَالَ لَقَدْ
كُنتُمْ أَنتُمْ وَءَابَآؤُكُمْ فِى ضَلَٰلٍ مُّبِينٍ ﴿٥٤﴾ قَالُوٓا۟ أَجِئْتَنَا بِٱلْحَقِّ أَمْ أَنتَ مِنَ ٱللَّٰعِبِينَ ﴿٥٥﴾ قَالَ بَل رَّبُّكُمْ رَبُّ
ٱلسَّمَٰوَٰتِ وَٱلْأَرْضِ ٱلَّذِى فَطَرَهُنَّ وَأَنَا۠ عَلَىٰ ذَٰلِكُم مِّنَ ٱلشَّٰهِدِينَ ﴿٥٦﴾ وَتَٱللَّهِ لَأَكِيدَنَّ أَصْنَٰمَكُم بَعْدَ أَن تُوَلُّوا۟
مُدْبِرِينَ ﴿٥٧﴾ فَجَعَلَهُمْ جُذَٰذًا إِلَّا كَبِيرًا لَّهُمْ لَعَلَّهُمْ إِلَيْهِ يَرْجِعُونَ ﴿٥٨﴾

*52. កាលគេបានថ្លែងប្រាប់បិតា (ឪពុកធំ ឬ ឪពុកមា) និងប្រជារាស្ត្ររបស់គេថា៖ "រូបបដិមាទាំងឡាយដែលអស់លោកគោរពបូជានោះគឺអ្វី ?" 53. ពួកគេបានថា៖ "យើងធ្លាប់បានឃើញដូនតាយើងគោរពបូជារូបទាំងនេះ ។" 54. គេបានថ្លែងថា៖ "អស់លោកនិងដូនតាអស់លោកនៅក្នុងសេចក្តីវង្វេង យ៉ាងជាក់ស្តែងមែន ។" 55. ពួកគេបានថា៖ "អ្នកនាំការពិតមកឲ្យយើង ឬមួយអ្នកគ្រាន់តែជាអ្នកលេងសើចម្នាក់ក្នុងចំណោមអ្នកលេងសើច ?" 56. គេបានថ្លែងថា៖ "ទេ ព្រះម្ចាស់អស់លោកគឺព្រះម្ចាស់មេឃទាំងឡាយនិងផែនដី ។ ព្រះអង្គជាអ្នកង្កើតអ្វីទាំងនេះមុនគេបង្អស់ ។ ខ្ញុំជាសាក្សីម្នាក់ចំពោះរឿងនោះ ។ 57. សូមស្បថចំពោះអល់ឡោះហ៍ ខ្ញុំនឹងប្រើល្បិចប្រឆាំងរូបបដិមាទាំងឡាយរបស់អស់លោក កាលណាអស់លោកចាកចេញផុត ទៅអស់ ។" 58. គេក៏បានកម្ទេចរូបបដិមាទាំងនោះចោល លើកលែងតែរូបបដិមាធំជាងគេមួយ ដើម្បីនឹងឲ្យពួកគេត្រឡប់មករកវាវិញ ។ (ស៊ូរ៉ោះត៍ អាល់-*

អាន់បីយ៉ាអ៊្ អាយ៉ាស្ទ 52-58 (21:52-58))

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. អ្នកណាជាស្តេចសោយរាជ្យសម័យព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ? ស្តេចនោះបានបង្ខំមនុស្សឲ្យជឿអ្វី ?

២. ហេតុអ្វីណាំរ៉ូដលعنه الله បានបញ្ជាឲ្យគេពិនត្យមើលទារកទើបនឹងកើត ដើម្បីស្គាល់ភិនភាគឬសញ្ញាអស្ចារ្យ ?

៣. ហេតុអ្វីមាតាព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامលាក់ព្រះអង្គعليه السلامក្នុងរូង ? ព្រះអង្គعليه السلامបៅដូចម្តេច ?

៤. ឪពុកមា (ឬឪពុកធំ) របស់ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានឲ្យព្រះអង្គعليه السلامធ្វើការអ្វី ? ហេតុអ្វីគាត់បានហាមព្រះអង្គعليه السلامធ្វើការនេះទៀត ?

៥. ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានធ្វើអ្វីថ្ងៃបុណ្យខួបប្រចាំឆ្នាំ ពេលគេចេញអស់ពីក្នុងស្រុក ?

## មេរៀនទី ១៦

# ព្រះសាស្ដា អ៊ីបរ៉ហ៊ីម عليه السلام - ភាគ ២

ព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام បានវាយកម្ទេចរូបព្រះទាំងអស់ ទុកតែរូបព្រះធំជាងគេមួយនៅក្នុងវិហារធំ ពេលពួកអ្នកស្រុកកំពុងធ្វើបុណ្យនៅខាងក្រៅស្រុក ។ ពេលត្រឡប់មកវិញ ឃើញព្រះពួកគេបែកបាក់ពាសពេញដី ពួកគេរន្ធត់ខ្លាំងណាស់ ថា៖ "អ្នកណាប្រព្រឹត្តបែបនេះចំពោះព្រះយើង ?" ម្នាក់បានថា៖ "ច្បាស់ជាអ៊ីបរ៉ហ៊ីម ។ វាតែងតែស្អប់ធ្វើសក្ការៈរូបព្រះ ។" គេបាននាំខ្លួនព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ទៅតុលាការក្នុងបទបណ្ដឹងបំផ្លាញរូបព្រះ ។

ពេលគេសួរព្រះអង្គ عليه السلام ថាតើព្រះអង្គ عليه السلام បានធ្វើកំហុសនេះទេ ព្រះអង្គ عليه السلام បានឆ្លើយថា៖ "រូបព្រះធំជាងទេដែលបានធ្វើកំហុសនេះ ។ សួរវាទៅ ។" តែគេបានថា៖ "រូបព្រះយើងមិនចេះនិយាយ មិនចេះឆ្លើយសំណួរទេ ។" ព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ក៏បានឆ្លៀតយកឱកាសនេះពន្យល់ប្រាប់មនុស្ស ថារូបព្រះពួកគេនោះឥតប្រយោជន៍សោះ ។ ព្រះអង្គ عليه السلام មានវចនៈថា៖ "អស់លោកគួរតែខ្មាសគេ ។ ម្ដេចក៏អស់លោកធ្វើសក្ការៈដុំឈើឬដុំថ្ម ។ ពួកវាមិនដឹងអ្វីសោះ មិនអាចផ្ដល់ផលប្រយោជន៍ មិនអាចផ្ដល់ផលអាក្រក់ដល់អស់លោកបានទេ ។" តែគេមិនចង់ស្ដាប់ព្រះអង្គ عليه السلام ទេ ហើយបានប្រកាសកាត់ទោសព្រះអង្គ عليه السلام ។ ប្រជារាស្ត្របានស្រែកថា៖ "យើងដុតវា عليه السلام ទាំងរស់ទៅ ។ ឲ្យវា عليه السلام នៅជាមួយព្រះវា عليه السلام ទៅ ។"

ណាំរ៉ូដ្ធ لعنه الله បានសម្រេចដុតព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ទាំងរស់ ដើម្បីផ្គាប់រូបព្រះខ្លួន لعنه الله ។ ណាំរ៉ូដ្ធ لعنه الله បានបញ្ជាឲ្យយកឧសមកដាក់ជាគំនរធំដើម្បីដុត ។ គេបានយកឧសមកច្រើនណាស់ ពេលដុតឧសនោះភ្លើងឆេះខ្លាំងណាស់ ពុំមានអ្នកណាអាចទៅជិតបានទេដើម្បីបោះព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ទៅក្នុងនោះ ។ ណាំរ៉ូដ្ធ لعنه الله បានសម្រេចឲ្យធ្វើដង្ហក់ធំមួយ ព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام ត្រូវចោលទៅក្នុងភ្លើងនោះ ដោយដង្ហក់នេះ ។ ពេលព្រះអង្គ عليه السلام នៅលើអាកាស កំពុងឆ្ពោះទៅរកគំនរភ្លើង ទេវតាយ៉ិបរ៉អ៊ីល عليه السلام បានមករកព្រះអង្គ



عليه السلام សួរព្រះអង្គعليه السلامថាតើត្រូវការឲ្យព្រះអង្គعليه السلامជួយទេ ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلامបានតបថា៖ "ទេ ទូលបង្គំعليه السلامត្រូវការតែជំនួយពីអល់ឡោះហ៍عز وجلទេ ។"

ព្រះគម្ពីរគួរអានថែងថា៖

قَالُواْ حَرِّقُوهُ وَٱنصُرُوٓاْ ءَالِهَتَكُمۡ إِن كُنتُمۡ فَٰعِلِينَ ﴿٦٨﴾ قُلۡنَا يَٰنَارُ كُونِي بَرۡدٗا وَسَلَٰمًا عَلَىٰٓ إِبۡرَٰهِيمَ ﴿٦٩﴾

*68. ពួកគេបានថា៖ "អស់លោកចូរដុតវាទៅ ហើយចូរជួយស្រោចស្រង់ព្រះទាំងឡាយ (រូបបដិមា) របស់អស់លោក បើអស់លោកចង់ធ្វើ[ដើម្បីជួយព្រះរបស់អស់លោក] ។" 69. យើងមានព្រះបន្ទូលថា៖ "ភ្លើងអើយ ចូរអ្នកទៅជាត្រជាក់និងគ្មានអន្តរាយសម្រាប់អ៊ិបរ៉ហ៊ីម ។"* (ស៊ូរ៉ោះត៍ អាល់-អាន់ប៊ីយ៉ាអ៍ អាយ៉ាស់ 68-69 (21:68-69))

ពេលព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامចូលទៅក្នុងភ្លើង ព្រះអង្គعليه السلامបានបួងសួងអល់ឡោះហ៍عز وجلសូមឲ្យការពារព្រះអង្គعليه السلام ។ ភ្លើងក៏ទៅជាត្រជាក់ គ្មានអន្តរាយតាមព្រះបញ្ជាអល់ឡោះហ៍عز وجل ។ ណាំរូដ្ធلعنه اللهនិងបក្សពួកភ្ញាក់ផ្អើលដែលឃើញព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامអង្គុយតាមសម្រួលនៅកណ្តាលភ្លើងកំពុងឆាបឆេះ ។ មនុស្សភាគច្រើនដែលបានឃើញអព្ភូតហេតុអស្ចារ្យនេះ ដឹងថាពាក្យពេជន៍របស់ព្រះអង្គعليه السلامដែលពួកគេបានឮនោះជាការពិតឥតមុសា តែមនុស្សឯទៀត ជាពិសេសណាំរូដ្ធلعنه الله នៅតែក្រអឺតក្រទម មានះដដែល ។ ក្រោយមកបន្តិច ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامចេញពីក្នុងភ្លើង ជួបណាំរូដ្ធلعنه الله ។ ណាំរូដ្ធلعنه اللهប្រាប់ព្រះអង្គعليه السلامថា៖ "ឯងعليه السلامកំពុងបង្កឲ្យមានការច្របូកច្របល់ក្នុងសហគមន៍អញلعنه الله ដោយហៅពួកគេទៅធ្វើសក្ការៈព្រះផ្សេងពីអញلعنه الله ។ ប្រាប់អញلعنه اللهមក អ្នកណាព្រះឯងعليه السلام ?"

ព្រះគម្ពីរគួរអានថែងថា៖

أَلَمۡ تَرَ إِلَى ٱلَّذِي حَآجَّ إِبۡرَٰهِـۧمَ فِي رَبِّهِۦٓ أَنۡ ءَاتَىٰهُ ٱللَّهُ ٱلۡمُلۡكَ إِذۡ قَالَ إِبۡرَٰهِـۧمُ رَبِّيَ ٱلَّذِي يُحۡيِۦ وَيُمِيتُ قَالَ أَنَا۠ أُحۡيِۦ وَأُمِيتُۖ قَالَ إِبۡرَٰهِـۧمُ فَإِنَّ ٱللَّهَ يَأۡتِي بِٱلشَّمۡسِ مِنَ ٱلۡمَشۡرِقِ فَأۡتِ بِهَا مِنَ ٱلۡمَغۡرِبِ فَبُهِتَ ٱلَّذِي كَفَرَۗ وَٱللَّهُ لَا يَهۡدِي ٱلۡقَوۡمَ ٱلظَّٰلِمِينَ ﴿٢٥٨﴾

*258. អ្នកមិនឃើញទេឬ បុរសម្នាក់ដែលឈ្លោះប្រកែកជាមួយអ៊ិបរ៉ហ៊ីមរឿងព្រះម្ចាស់គេ ព្រោះអល់ឡោះហ៍បានប្រទានឲ្យបុរសនោះនូវអំណាចគ្រងរាជ្យ ? លុះអ៊ិបរ៉ហ៊ីមបានថ្លែងថា៖ "ព្រះម្ចាស់ខ្ញុំគឺព្រះអ្នកប្រទានជីវិតនិងការស្លាប់" បុរសនោះបានថា៖ "ខ្ញុំ[ក៏]ជាអ្នកឲ្យជីវិតនិងការស្លាប់[ដែរ] ។" អ៊ិបរ៉ហ៊ីមបានថា៖*

*"អល់ឡោះហ្ស៎នាំដួងអាទិត្យមកពីទិសខាងកើត ចូរនាំដួងអាទិត្យមកពីទិសខាងលិច ។" ដូច្នេះបុគ្គលបដិសេធសទ្ធានោះទីទើរ ។ អល់ឡោះហ្ស៎មិនដឹកនាំនូវជនទុច្ចរិតទេ ។* ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 258 (2:258))

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامប្រាប់ណាំរ៉ូដលعنه اللهថា អល់ឡោះហ្ស៎عز وجلធ្វើឲ្យរស់និងធ្វើឲ្យស្លាប់ ។ ណាំរ៉ូដលعنه اللهថា៖ "អញលعنه اللهក៏អាចធ្វើដូចនេះបានដែរ ។ បើអញលعنه اللهហៅអ្នកទោសប្រហារជីវិតដោយព្យួរកពីរនាក់ ដោយឲ្យម្នាក់រួចខ្លួន ឲ្យម្នាក់ទៀតស្លាប់ អញលعنه اللهបានឲ្យម្នាក់រស់ ម្នាក់ទៀតស្លាប់ ។" ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامមានវចនៈថា៖ "ទេ ព្រះអង្គលعنه اللهនិយាយត្រូវបើព្រះអង្គលعنه اللهធ្វើឲ្យមនុស្សស្លាប់រស់វិញ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះទូលបង្គំعليه السلامធ្វើឲ្យថ្ងៃរះពីទិសខាងកើត បើព្រះអង្គលعنه اللهខ្លាំងពូកែមែន ចូរធ្វើឲ្យវារះពីទិសខាងលិចទៅ ។" ណាំរ៉ូដលعنه اللهមិនអាចឆ្លើយតបវិញបាន ត្រូវបរាជ័យ ។ តែណាំរ៉ូដលعنه اللهនៅតែមានះចង់ឈ្នះ មិនព្រមទទួលស្គាល់សាសនារបស់ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامទេ ។

ណាំរ៉ូដលعنه اللهដឹងថាមិនអាចបៀតបៀនព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានទេ ព្រោះអល់ឡោះហ្ស៎عز وجلការពារព្រះអង្គعليه السلام ។ ដូច្នេះណាំរ៉ូដលعنه اللهបានដាក់បញ្ជាឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامចាកចេញពីរាជាណាចក្រខ្លួនលعنه الله ហាមមនុស្សមិនឲ្យតាមសាសនាព្រះអង្គعليه السلامទេ ។

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامក៏បានចាកចេញពីស្រុកកំណើត ជាមួយគ្រួសារព្រះអង្គعليه السلامនិងពពែ ។ ព្រះអង្គعليه السلامបាននាំ សារ៉ោះត៍ (سارة) មហេសីព្រះអង្គعليه السلام ព្រះសាស្តាលូតعليه السلام បងប្អូនជីតាមួយរបស់ព្រះអង្គعليه السلام ទៅជាមួយផង ទៅកាន់បៃទុល-ម៉ាក់ឌីសនៅឯដែនដីប៉ាលេស្ទីន ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានឆ្លើយថាអ្វី ពេលគេសួរព្រះអង្គعليه السلامថាតើបានធ្វើកំហុសវាយបំបាក់រូបព្រះទេ ?

២. ណាំរូដلعنه اللهបានសម្រេចធ្វើអ្វីចំពោះព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ដើម្បីផ្គាប់រូបព្រះខ្លួនلعنه الله ?

៣. ទេវតាយ៉ីបរ៉អ៊ីលعليه السلامបានសួរអ្វីព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ? ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានឆ្លើយអ្វី ?

៤. អ្វីកើតឡើងចំពោះព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام កាលគេចោលព្រះអង្គعليه السلامដោយដង្ហក់ទៅក្នុងភ្លើងកំពុងឆាបឆេះ ?

៥. ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានពន្យល់ណាំរូដلعنه الله ឲ្យស្គាល់អល់ឡោះហ្វ៍عز وجل ដូចម្តេច ?

**មេរៀនទី ១៧**

# ព្រះសាស្តា អ៊ីបរ៉ហ៊ីមﷺ - ភាគ ៣

ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺត្រូវស្តេចណាំរូដ្ធﷻបណ្តេញចេញពីមាតុភូមិ ។ ព្រះអង្គﷺបានចាកចេញជាមួយគ្រួសារព្រះអង្គﷺទៅកាន់បៃទុល-ម៉ាក់ឌីស ឯដែនដីប៉ាលេស្ទីន ។ ព្រះនាងសារ៉ោះត៏ មហេសីព្រះអង្គﷺ ជាស្រ្តីមានឆោមលំអដូច្នេះ ដើម្បីការពារព្រះនាងពីខ្សែភ្នែកអគប្បី ព្រះអង្គﷺឲ្យព្រះនាងនៅក្នុងកូបបិតជិតពេលទៅដល់ក្នុងស្រុក ។ ពេលធ្វើដំណើរឯវាលគ្មានមនុស្សនៅ ព្រះនាងចេញក្រៅកូប ។

លុះបានធ្វើដំណើរអស់មួយរយៈពេល ក៏បានទៅដល់ស្រុកថ្មីមួយសោយរាជ្យដោយស្តេចអារ៉ាប់ ។ ឆ្មាំយាមផ្លូវចូលចង់ឆែកឆេរកូបដែលព្រះនាងសារ៉ោះត៏នៅខាងក្នុង ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺមានវចនៈថា៖ "លោកអាចស្មានបានថានៅក្នុងនោះមានមាសប្រាក់ ខ្ញុំﷺនឹងបង់ពន្ធលើមាសប្រាក់នោះ តែកុំបើកកូបនេះ ។" តែឆ្មាំទាមទារចង់ឃើញ អ្វីដែលព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺដឹកជញ្ជូននៅក្នុងកូបនោះ ហើយក៏បានបើកមើល ។ ពេលបានឃើញព្រះនាងសារ៉ោះត៏ ឆ្មាំបានបញ្ជូនព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺទៅជួបស្តេច ។

ពេលជួបស្តេច ឆោមលំអព្រះនាងសារ៉ោះត៏ទាក់ទាញអារម្មណ៍ក្សត្ររូបនេះចៀសវាងប៉ះព្រះនាងមិនបាន ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺបួងសួងអល់ឡោះហ៊ូﷻសូមឲ្យការពារកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់មហេសីព្រះអង្គﷺ ។ ពេលបួងសួងភ្លាម ដៃស្តេចនេះក្លាយទៅជាដុំឈើមួយរំពេច ។ ស្តេចអង្វរព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺឲ្យជួយបួងសួងអល់ឡោះហ៊ូﷻសូមឲ្យដៃខ្លួនទៅជាដូចដើមវិញ ដោយសន្យាថានឹងមិនសម្លឹងមើលព្រះនាងសារ៉ោះត៏ទេ ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺក៏បានបួងសួងអល់ឡោះហ៊ូﷻ ដៃស្តេចទៅជាធម្មតាវិញ ។ បន្ទាប់ពីបាននិយាយជាមួយព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺបន្តិច ស្តេចបានសម្លឹងមើលព្រះនាងសារ៉ោះត៏ម្តងទៀត ហើយមិនអាចអត់ទ្រាំធ្វើកំហុសដូចមុនបានទេ ។ ពេលចង់ប៉ះព្រះនាងភ្លាម ដៃស្តេចនោះក៏ក្លាយទៅជាស្វួតដូចដុំឈើភ្លាម ។ ស្តេចបានបែរទៅរកព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺ

ម្ដងទៀតដោយអង្វរព្រះអង្គ عليه السلام ឲ្យជួយសូមខមាទោសអល់ឡោះហ៊្ ជل ឲ្យខ្លួន ឲ្យដៃខ្លួនក្លាយទៅជាដូចដើមវិញ ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام បានប្រាប់ស្តេចនោះថាព្រះអង្គ عليه السلام នឹងបួងសួងអល់ឡោះហ៊្ ជل ឲ្យស្តេចនោះជាលើកចុងក្រោយបង្អស់ ។ ព្រះអង្គបានទូលអល់ឡោះហ៊្ عز وجل ថា៖ "ព្រះម្ចាស់ عز وجل ទូលព្រះបង្គំជាខ្ញុំអើយ បើបុរសនេះស្តាយក្រោយដោយស្មោះមែន សូមព្រះអង្គ عز وجل ឲ្យដៃគេទៅជាដូចដើមវិញ ។" ក្នុងពេលបួងសួង ដៃស្តេចបានជាវិញ ។ ស្តេចស្ងប់ស្ញែងអំណាចព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ណាស់ ហើយបានផ្លាស់ប្តូរសាសនាមកចូលសាសនារបស់ព្រះអង្គ عليه السلام ។ ស្តេចប្រព្រឹត្តចំពោះព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ បានប្រទានស្រីបម្រើម្នាក់ឈ្មោះ ហាយ៉ាជើរ៍ (هاجر) ឲ្យព្រះអង្គ عليه السلام សម្រាប់នៅបម្រើព្រះនាងសារ៉ោះត៏ បានអនុញ្ញាតឲ្យព្រះអង្គ عليه السلام និងគ្រួសារអាចចាកចេញបានកាលណាក៏បាន ។

តាមផ្លូវទៅកាន់បៃទុល-ម៉ាក់ឌីស ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام បានជួបប្រជារាស្ត្រមួយក្រុមដែលធ្វើសក្ការៈផ្កាយ ។ គេហៅជនានុជននេះថា ម៉ាយូស (مَجُوسُ) ។ ព្រះអង្គ عليه السلام បានសម្រេចចិត្តដឹកនាំពួកនេះទៅរកអល់ឡោះហ៊្ عز وجل ។ ដើម្បីធ្វើឲ្យពួកគេយល់កំហុសខ្លួន ព្រះអង្គ عليه السلام បានប្រើមធ្យោបាយត្រជាក់ ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام បានណែនាំខ្លួនឲ្យពួកគេស្គាល់ព្រះអង្គ عليه السلام ជាអ្នកគោរពផ្កាយដែរ ហើយបានអង្គុយជាមួយពួកគេពេលយប់ដើម្បីធ្វើសក្ការៈ ។

ព្រះគម្ពីរគួរអានថែងថា៖

وَكَذَٰلِكَ نُرِيٓ إِبۡرَٰهِيمَ مَلَكُوتَ ٱلسَّمَٰوَٰتِ وَٱلۡأَرۡضِ وَلِيَكُونَ مِنَ ٱلۡمُوقِنِينَ ۝٧٥ فَلَمَّا جَنَّ عَلَيۡهِ ٱلَّيۡلُ رَءَا كَوۡكَبٗاۖ قَالَ
هَٰذَا رَبِّيۖ فَلَمَّآ أَفَلَ قَالَ لَآ أُحِبُّ ٱلۡأٓفِلِينَ ۝٧٦ فَلَمَّا رَءَا ٱلۡقَمَرَ بَازِغٗا قَالَ هَٰذَا رَبِّيۖ فَلَمَّآ أَفَلَ قَالَ لَئِن لَّمۡ يَهۡدِنِي رَبِّي
لَأَكُونَنَّ مِنَ ٱلۡقَوۡمِ ٱلضَّآلِّينَ ۝٧٧ فَلَمَّا رَءَا ٱلشَّمۡسَ بَازِغَةٗ قَالَ هَٰذَا رَبِّي هَٰذَآ أَكۡبَرُۖ فَلَمَّآ أَفَلَتۡ قَالَ يَٰقَوۡمِ إِنِّي
بَرِيٓءٞ مِّمَّا تُشۡرِكُونَ ۝٧٨

*75. ដូច្នេះឯងដែលយើងបានធ្វើឲ្យអ៊ិបរ៉ហ៊ីមឃើញអាណាចក្រមេឃ និងផែនដី ដើម្បីនឹងឲ្យគេនៅក្នុងចំណោមបណ្តាអ្នកជឿជាក់ ។ 76. ពេលរត្តិកាល (គឺរាត្រីកាល) បានគ្របដណ្តប់លើគេ គេបានឃើញផ្កាយមួយដួងហើយបានថា៖ "តើនេះជាព្រះម្ចាស់ខ្ញុំឬ ?" លុះវាលិចបាត់ទៅ គេបានថា៖ "ខ្ញុំមិនចូលចិត្តអ្នកលិចបាត់ទេ ។" 77. ពេលគេបានឃើញខែរះ គេបានថា៖ "តើនេះជាព្រះម្ចាស់ខ្ញុំឬ ?" តែលុះ*

*ខែនេះលិចបាត់ទៅ គេបានថា៖ "បើព្រះម្ចាស់ខ្ញុំមិនដឹកនាំខ្ញុំទេ ខ្ញុំនឹងនៅក្នុងចំណោមជនដើរខុសផ្លូវ ។" 78. ពេលគេបានឃើញថ្ងៃរះ គេបានថា៖ "តើនេះជាព្រះម្ចាស់ខ្ញុំឬ ? នេះធំជាងគេ !" តែលុះថ្ងៃលិចបាត់ទៅ គេបានថា៖ "ប្រជារាស្ត្រអើយ ខ្ញុំសូមបដិសេធចោលនូវអ្វីដែលអស់លោកយកមកផ្គួបផ្គុំ [ចូលរួមហ៊ុនហាយជាដៃគូជាមួយអល់ឡោះហ៍] ។*(ស៊ូរ៉ោះត៊ អាល់-អាន់អ៊ាំ អាយ៉ាស់ 75-78 (6:75-78)) ។

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានធ្វើឲ្យគេចាប់អារម្មណ៍ព្រះអង្គعليه السلام ដោយថា ផ្កាយ ខែ ថ្ងៃ ជាព្រះរបស់ព្រះអង្គعليه السلام ។ តែ ព្រោះតែវត្ថុទាំងបីនេះលិចបាត់ ព្រះអង្គعليه السلامដកខ្លួនចេញពីវត្ថុទាំងបីនេះដោយថា៖ "ខ្ញុំعليه السلامមិនជឿមាបនកម្មទាំងនេះដែលចេះតែផ្លាស់ប្តូរជានិច្ចនោះទេ ។ ខ្ញុំعليه السلامជឿអល់ឡោះហ៍عَزَّ وَجَلَّ ព្រះអ្នកបង្កើតមេឃនិងដី ។ ខ្ញុំعليه السلامមិននៅក្នុងចំណោមជនហ៊ុនហាយជាមួយអល់ឡោះហ៍عَزَّ وَجَلَّ ឬជនធ្វើសក្ការៈរូបព្រះទេ ។" ទោះបីព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامប្រើមធ្យោបាយត្រជាក់ដើម្បីបង្ហាញពួកគេឲ្យដឹងថាការគោរពបូជារបស់ពួកគេនោះឥតប្រយោជន៍ក៏ដោយ ពួកម៉ាយូសនៅតែជំទាស់ព្រះអង្គعليه السلام ។ ព្រះអង្គعليه السلامមានវចនៈថា៖ "ហេតុអ្វីអស់លោកបដិសេធអល់ឡោះហ៍عَزَّ وَجَلَّ ព្រោះព្រះអង្គعَزَّ وَجَلَّបានដឹកនាំខ្ញុំعليه السلامនៅលើផ្លូវត្រូវ ?" ពួកគេមិនព្រមជឿសម្តីព្រះអង្គعليه السلامទេ ហើយបានគំរាមធ្វើបាបព្រះអង្គعليه السلام បន្លាចព្រះអង្គعليه السلامឲ្យខ្លាចការសងសឹករបស់ផ្កាយ ។ ទីបំផុតព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام បានចាកចោលប្រជារាស្ត្រភ្លីភ្លើនេះ បន្តដំណើរទៅកាន់បៃទុល-ម៉ាក់ឌីស ។

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامនិងព្រះនាងសារ៉ោះត៊ពុំមានកូនទេ ធ្វើឲ្យព្រះអង្គعليه السلامក្រៀមក្រំខ្លាំង ។ ព្រះនាងសារ៉ោះត៊ស្នើព្រះអង្គعليه السلامឲ្យរៀបការជាមួយហ្វាយ៉ារ៍ស្រីបម្រើ អល់ឡោះហ៍عَزَّ وَجَلَّអាចនឹងឲ្យព្រះអង្គعليه السلامនិងហ្វាយ៉ារ៍មានកូនបាន ។ ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامនិងហ្វាយ៉ារ៍ក៏បានរៀបការជាមួយគ្នា អល់ឡោះហ៍عَزَّ وَجَلَّឲ្យគូស្វាមីភរិយាបានកូនប្រុសម្នាក់ គឺព្រះសាស្តាអ៊ីសម៉ាអ៊ីលعليه السلام ។

ប្រាំឆ្នាំក្រោយមក ព្រះនាងសារ៉ោះត៊បានកូនប្រុសម្នាក់ដែរ គឺព្រះសាស្តាអ៊ីសហ្វាក់عليه السلام ។

គេហៅព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامថា ព្រះបិតារបស់បណ្តាព្រះសាស្តាعليهم السلام ព្រោះបណ្តាព្រះសាស្តាអារ៉ាប់កើតមកពីព្រះរាជបុត្រព្រះអង្គعليه السلام ព្រះសាស្តាអ៊ីសម៉ាអ៊ីលعليه السلام រាប់បញ្ចូលព្រះសាស្តាមូហ៊ាំម៉ាដ់ﷺដែរ ឯព្រះសាស្តាអ៊ីសហ្វាក់

ﷺបានឲ្យកំណើតដល់ព្រះសាស្តាសាសន៍អ៊ីសរ៉អ៊ីលច្រើនអង្គ ដោយរាប់បញ្ចូលព្រះសាស្តាអ៊ីសាﷺដែរ ។

ងាររបស់ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺគឺ "ខ៊លីលុលឡោះហ៍ (خَلِيلُ اللهِ)" មានន័យថា "មិត្តរបស់អល់ឡោះហ៍ﷻ" ។ ដល់ពេលសោយទិវង្គត ព្រះអង្គﷺបានប្រាប់ទេវតាដែលមកយកព្រលឹងព្រះអង្គﷺថា៖ "ចូរព្រះអង្គﷺសួរអល់ឡោះហ៍ﷻថា តើមិត្តអាចយកជីវិតរបស់មិត្តកើតទេ ?" ព្រះអង្គﷺចង់និយាយថាអល់ឡោះហ៍ﷻ មិនត្រូវដាក់បញ្ហាឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺស្លាប់ទេ ព្រោះព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺជាមិត្តរបស់អល់ឡោះហ៍ﷻ ។ អ៊ីស្ររ៉អ៊ីល(عِزْرَائِيل)ﷺ ទេវតាយកព្រលឹង មិនអាចឆ្លើយសំណួរនេះបានទេ ដូច្នេះព្រះអង្គﷺត្រឡប់ទៅជួបអល់ឡោះហ៍ﷻវិញ អល់ឡោះហ៍ﷻបានប្រាប់ព្រះអង្គﷺ ឲ្យវិលត្រឡប់ទៅប្រាប់ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺវិញថា៖ "អ៊ីបរ៉ហ៊ីមﷺអើយ តើមិត្តអាចបដិសេធការសូមជួបរបស់មិត្តកើតទេ ?

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានការពារព្រះនាងសារ៉ោះត៍ ពេលចូលទៅក្នុងស្រុក ?

២. ស្តេចបានធ្វើអ្វីពេលបានឃើញព្រះនាងសារ៉ោះត៍ ? មានអ្វីកើតឡើង ?

៣. ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបាននិយាយអំពីអល់ឡោះហ្ស៊ុعز وجلដូចម្តេច នៅក្នុងចំណោមពួកធ្វើសក្ការៈរូបព្រះ ?

៤. ហេតុអ្វីគេហៅព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلام ថាព្រះបិតារបស់បណ្តាព្រះសាស្តាعليهم السلام ?

៥. ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបានប្រាប់ទេវតាយកព្រលឹងថាអ្វី កាលទេវតានោះមកយកព្រលឹងព្រះអង្គعليه السلام ? អល់ឡោះហ្ស៊ុعز وجلបានឆ្លើយថាអ្វី ?

## មេរៀនទី ១៨

# ព្រះសាស្តា អ៊ីសម៉ាអ៊ីលعليه السلام

កាលព្រះសាស្តាអ៊ីសម៉ាអ៊ីលعليه السلامប្រសូត ព្រះបិតាព្រះអង្គعليه السلامមានព្រះជន្ម ៨៦ ឆ្នាំ ។ ព្រះរាជទារកជាកែវភ្នែកព្រះបិតា ព្រះនាងសារ៉ោះត៊្រៀមក្រំព្រោះពុំមានបុត្រ ពេលឃើញព្រះអង្គទាំងពីរعليهم السلام ។ ក្រោយមកបន្តិច ព្រះនាងលែងអាចទ្រំមើលព្រះនាងហាយ៉ារ៍និងព្រះរាជបុត្របាន ក៏បានសូមឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامយកអ្នកទាំងពីរទៅនៅកន្លែងផ្សេង ។

ព្រះសាស្តាអ៊ីបរ៉ហ៊ីមعليه السلامបាននាំហាយ៉ារ៍ និងព្រះសាស្តាអ៊ីសម៉ាអ៊ីលعليه السلامទៅម៉ាក់កាស់ តាមព្រះបញ្ជាអល់ឡោះហ៍عز وجل ។ ព្រះអង្គعليه السلامបានទុកមហេសីព្រះអង្គعليه السلامនិងព្រះសាស្តាអ៊ីសម៉ាអ៊ីលعليه السلامនៅឯរហោឋាននេះ ក្រោមការថែរក្សារបស់អល់ឡោះហ៍عز وجل ហើយវិលត្រឡប់ទៅដែនដីប៉ាលេស្ទីនវិញ ។ ព្រះគម្ពីរគួរអានថែងថាព្រះអង្គعليه السلامបានបួងសួងថា៖

رَّبَّنَآ إِنِّيٓ أَسۡكَنتُ مِن ذُرِّيَّتِي بِوَادٍ غَيۡرِ ذِي زَرۡعٍ عِندَ بَيۡتِكَ ٱلۡمُحَرَّمِ رَبَّنَا لِيُقِيمُواْ ٱلصَّلَوٰةَ فَٱجۡعَلۡ أَفۡـِٔدَةٗ مِّنَ ٱلنَّاسِ تَهۡوِيٓ إِلَيۡهِمۡ وَٱرۡزُقۡهُم مِّنَ ٱلثَّمَرَٰتِ لَعَلَّهُمۡ يَشۡكُرُونَ ٣٧

*37. ព្រះម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ ទូលព្រះបង្គំជាខ្ញុំបានតាំងទីលំនៅឲ្យកូនចៅទូលព្រះបង្គំជាខ្ញុំមួយចំនួននៅឯជ្រលងភ្នំមួយដែលពុំមានរុក្ខជាតិ ក្បែរបូជនីយដ្ឋានព្រះអង្គ (កាក់បាស់) ។ ឱព្រះម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ ដើម្បីនឹងឲ្យពួកគេធ្វើនមស្ការ[បូជាព្រះអង្គ] ។ ដូច្នេះសូមព្រះមេត្តាធ្វើឲ្យចិត្តមនុស្សមួយចំនួនទន់ទេរទៅរកពួកគេ សូមព្រះអង្គព្រះមេត្តាជួយផ្តត់ផ្គង់ពួកគេដោយផលានុផលផង ដើម្បីពួកគេនឹងមានកតញ្ញូតា ។* (ស៊ូរ៉ោះត៊ អ៊ីបរ៉ហ៊ីម អាយ៉ាស់ 37 (14:37))

ទោះបីព្រះនាងហាយ៉ារ៍នៅតែឯងក្នុងរហោឋានក៏ដោយ តែព្រះស្វាមីព្រះនាងបានបង្ហាត់ព្រះនាងឲ្យចេះទុកចិត្តលើអល់ឡោះហ៍عز وجلនិងមានអំណត់ ។ ពេលឃ្លាននិងស្រេកទឹក មិនមានចំណីឲ្យកូន ព្រះនាងព្យាយាមដើររកទឹករវាងទួលស្វ៍ហ្វា



និងម៉ារវ៉ាស់ តែរកពុំបាន ។ ទីបំផុតព្រះនាងត្រឡប់មករកកូនវិញដោយអស់សង្ឃឹម ។ រំពេចនោះ ព្រះនាងបានឃើញទឹកហូរចេញពីកន្លែង ដែលព្រះសាស្ដាអ៊ីសម៉ាអ៊ីលﷺបានវាយដីដោយជើង ។ ព្រះនាងសប្បាយចិត្តណាស់ ហើយបានផឹកទឹកមួយចម្អែត ។

បន្ទាប់ពីនោះ សត្វស្លាបនានាបានមករកទឹកនេះ ។ ប្រជាជាតិយ៉ូរហ្វាំ (جرهم) ដែលរស់នៅក្បែរនោះ ដើរតាមដានជើងសត្វស្លាបដើម្បីរកទឹកផឹក ។ ពេលបានឃើញព្រះនាងហាយ៉ារ៍និងព្រះសាស្ដាអ៊ីសម៉ាអ៊ីលﷺនៅតែឯងក៏បានស្នើសូមឲ្យទៅនៅជាមួយកុលសម្ព័ន្ធពួកគេ ។

ព្រះនាងហាយ៉ារ៍ និងព្រះសាស្ដាអ៊ីសម៉ាអ៊ីលﷺក៏បានរស់នៅជាមួយប្រជាជាតិយ៉ូរហ្វាំ ។ ព្រះសាស្ដាអ៊ីបរ៉ហ៊ីមﷺមកលេងព្រះអង្គទាំងពីរម្ដងៗ ។ ថ្ងៃមួយពេលព្រះអង្គﷺមកលេង កាលព្រះសាស្ដាអ៊ីសម៉ាអ៊ីលﷺមានព្រះជន្ម ១៣ ឆ្នាំ ព្រះសាស្ដាអ៊ីបរ៉ហ៊ីមﷺ បានសុបិនឃើញបូជាជីវិតព្រះរាជបុត្រព្រះអង្គﷺ ។ កាលនោះថ្ងៃទី ៨ ខែ ស៊ុល-ហ៊ីច្ចយ៉ាស់ គេហៅថ្ងៃនោះថា "យ៉ៅម៍ អាល់-តារវីយ៉ាស់" (يَوْمَ التَّرْوِيَةِ ថ្ងៃសុបិនដំបូង) ។ ព្រះសាស្ដាអ៊ីបរ៉ហ៊ីមﷺទទួលព្រះរាជបញ្ជាពីអល់ឡោះហ៍ﷻជាញឹកញយតាមរយៈសុបិន តែព្រោះតែគេឲ្យសម្លាប់កូនឯងទើបព្រះអង្គﷺនឹកក្នុងចិត្តថាសុបិននេះពិតឬទេ ។ ថ្ងៃបន្ទាប់ ព្រះអង្គﷺសុបិនដដែល ហើយជឿជាក់ក្នុងចិត្តថានេះជាព្រះរាជបញ្ជាពិត ។ ដូច្នេះ គេហៅថ្ងៃទី ៩ ខែ ស៊ុល-ហ៊ីច្ចយ៉ាស់ ថា "យ៉ៅម៍ អាល់-អារ៉ហ្វាស់" (يَوْمَ الْعَرَفَةِ ថ្ងៃដឹងច្បាស់) ។ ព្រះគម្ពីរគួរអានចែងថា៖

فَلَمَّا بَلَغَ مَعَهُ ٱلسَّعۡىَ قَالَ يَٰبُنَىَّ إِنِّىٓ أَرَىٰ فِى ٱلۡمَنَامِ أَنِّىٓ أَذۡبَحُكَ فَٱنظُرۡ مَاذَا تَرَىٰۚ قَالَ يَٰٓأَبَتِ ٱفۡعَلۡ مَا تُؤۡمَرُۖ سَتَجِدُنِىٓ إِن شَآءَ ٱللَّهُ مِنَ ٱلصَّٰبِرِينَ ١٠٢

*102. លុះគេ (អ៊ីសម៉ាអ៊ីល) មានអាយុអាចប្រកបកិច្ចការជាមួយគេបានហើយ គេបានថា៖ "កូនឪពុកអើយ ឪពុកបានសុបិនឃើញឪពុកកំពុងតែសំឡេះកូនដើម្បីធ្វើពលីទាន ។ តើកូនយល់ឃើញយ៉ាងណា ?" គេបានថា៖ "លោកឪពុក សូមលោកឪពុកធ្វើតាមអ្វីដែលគេបានបញ្ជាឲ្យលោកឪពុកធ្វើទៅ ។ បើអល់ឡោះហ៍ទ្រង់ប្រាថ្នា លោកឪពុកនឹងឃើញថាកូនជាម្នាក់ក្នុងចំណោមអ្នកអត់ធ្មត់[នៅលើមាគ៌ា*

*អល់ឡោះហ៍] ។"*(ស៊ូរ៉ោះត៍ អាស្ស-ស្វហ្វហ្វាត អាយ៉ាស់ 102 (37:102))

ព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇បានយកខ្សែនិងកាំបិត ហើយនាំកូនទៅឯរហោឋាន ។ តាមផ្លូវ ស្ហៃតន្ត لعن الله បានកាឡៃខ្លួនជាមនុស្សចាស់មកជួបព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇ ញុះញង់ព្រះអង្គ﵇ថាព្រះអង្គ﵇កំពុងតែធ្វើកំហុសធំដែលចង់សម្លាប់កូនឯងនោះ ។ ស្ហៃតន្ត لعن الله បានមកទាក់ទាញព្រះអង្គ﵇បីដង ព្រះអង្គ﵇បានដេញវា لعن الله បីដងដោយចោលវា لعن الله នឹងដុំថ្មប្រាំពីរដុំ ។

ពេលបានទៅដល់ម៉ាឌ្ហីណាស់ ព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇បានឲ្យកូនដេកលើដីហើយយកកាំបិត ។ ព្រះសាស្តាអ៊ីសម៉ាអ៊ីល﵇ ពេលឃើញបិតាពិបាកចិត្តចុះដៃសម្លាប់ព្រះអង្គ﵇ ក៏បានថា៖ "លោកឪពុកអើយ សូមលោកឪពុកចងដៃចងជើងកូនដើម្បីកុំឲ្យកូនរើបម្រះ ។ សូមលោកឪពុកយកក្រណាត់បិទភ្នែកលោកឪពុកដើម្បីនឹងកុំឲ្យឃើញកូនស្លាប់ រឹតអាវក្រៅលោកឪពុកឲ្យតឹងដើម្បីនឹងកុំឲ្យអ្នកម្តាយឃើញឈាមខ្ទាតប្រឡាក់ខោអាវលោកឪពុក ។ សូមលោកឪពុកសំលៀងកាំបិតឲ្យមុតដើម្បីលោកឪពុកនឹងអាចបំពេញករណីយកិច្ចបានយ៉ាងឆាប់ ។ ដូច្នេះ កូននឹងមិនឈឺទេ ។"



ព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇បានធ្វើដូចកូនប្រាប់ ហើយក៏បានសំឡេះកូន ។ តែពេលព្រះអង្គ﵇បើកក្រណាត់បិទមុខចេញ ព្រះអង្គ﵇ភ្ញាក់ព្រើត ដោយឃើញកូនព្រះអង្គ﵇ឈរក្បែរព្រះអង្គ﵇ ហើយឃើញថាព្រះអង្គ﵇បានសំឡេះបាចៀមជួសកូន ។ ព្រះគម្ពីរគួរអានចែងថា៖

وَنَٰدَيْنَٰهُ أَن يَٰٓإِبْرَٰهِيمُ ﴿١٠٤﴾ قَدْ صَدَّقْتَ ٱلرُّءْيَآ ۚ إِنَّا كَذَٰلِكَ نَجْزِى ٱلْمُحْسِنِينَ ﴿١٠٥﴾ إِنَّ هَٰذَا لَهُوَ ٱلْبَلَٰٓؤُا۟ ٱلْمُبِينُ ﴿١٠٦﴾
وَفَدَيْنَٰهُ بِذِبْحٍ عَظِيمٍ ﴿١٠٧﴾ وَتَرَكْنَا عَلَيْهِ فِى ٱلْءَاخِرِينَ ﴿١٠٨﴾ سَلَٰمٌ عَلَىٰٓ إِبْرَٰهِيمَ ﴿١٠٩﴾

*104. យើងបានប្រាប់គេថា៖ "អ៊ិបរ៉ហ៊ីមអើយ 105. អ្នកបានបំពេញតាមសុបិនហើយ ។ បែបនេះឯងដែលយើងតបស្នងជនទាំងឡាយណាដែលប្រព្រឹត្តល្អ ។" 106. ការពិត នេះគឺបទល្បងពិសោធន៍មួយដ៏ជាក់ស្តែង ។ 107. យើងបានលោះខ្លួនគេដោយពលីកម្មឧឡារិកមួយ ។ 108. ហើយយើងបានទុកកេរ្តិ៍ឈ្មោះល្អឲ្យគេក្នុងពូជពង្សជំនាន់ក្រោយ ។ 109. ចូរសិរីសួស្តីកើតមានដល់អ៊ិបរ៉ហ៊ីម!* (ស៊ូរ៉ោះត៍

អាស្ស៎-ស្វហ្វ៉ហ្វាត អាយ៉ាស់ 104-109 (37:104-109))

ដូច្នេះ អល់ឡោះហ៊្វ عز وجل បានប្រាប់ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ថាព្រះអង្គ عز وجل តបស្នងជំនឿព្រះអង្គ عليه السلام ដោយសង្គ្រោះជីវិតព្រះសាស្តាអ៊ីសម៉ាអ៊ីល عليه السلام ។ ជួសព្រះរាជបុត្រព្រះអង្គ عليه السلام ព្រះពលីកម្មនៅលើព្រះមាគ៌ាអល់ឡោះហ៊្វ عز وجل នឹងត្រូវឲ្យទៅបុគ្គលម្នាក់ទៀតនៅក្នុងអនាគតកាល ។ បុគ្គលនោះមិនមែនអ្នកណាផ្សេងពីអ៊ីម៉ាំហ៊ូសៃន៍ صلوات الله عليه والسلام ទេដែលបានបូជាជីវិតខ្លួនឯង صلوات الله عليه والسلام បន្ទាប់ពីបានបូជាជីវិតសាច់ញាតិនិងមិត្តរបស់ព្រះអង្គ صلوات الله عليه والسلام នៅឯវាលការបាឡាអ៊ ដើម្បីការពារសាសនាអ៊ីស្លាមឲ្យគង់វង្ស ។

បន្ទាប់ពីព្រះរាជបុត្រព្រះអង្គ عليه السلام រួចជីវិត ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام បានចាកចេញទៅកាន់ដែនដីប៉ាលេស្ទីន ទៅរកព្រះនាងសារ៉េាះត៍វិញ ។ អល់ឡោះហ៊្វ عز وجل បានតម្រូវឲ្យទង្វើរបស់ព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام ទៅជាវ៉ាយ៉ិបសម្រាប់មុស្លីមទាំងអស់ ។ ដូច្នេះ ពេលយើងបំពេញពិធីហាជ្ជ៍ យើងដើរត្រង់ចន្លោះទួលស្វ៏ហ្វានិងម៉ារវ៉ាស់ ដូចព្រះនាងហាយ៉ាជ៍បានធ្វើដែរកាលពីមុន ។ យើងទៅឯមីណាដែរដើម្បីសំឡេះសត្វធ្វើពលីកម្មនិងចោលស្ហៃតួន لعنه الله ដោយដុំថ្ម ។

សម័យថ្ងៃមួយ កាលព្រះអង្គ عليه السلام មកលេងព្រះសាស្តាអ៊ីសម៉ាអ៊ីល عليه السلام អល់ឡោះហ៊្វ عز وجل បានដាក់ព្រះរាជបញ្ជា ឲ្យព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام កសាងព្រះមហាគ្រឹះកាក់បាស់ឡើងវិញ ក្រោយពីបានបាក់បែក ។

ព្រះគម្ពីរគួរអានចែងថា៖

وَإِذْ يَرْفَعُ إِبْرَٰهِـۧمُ ٱلْقَوَاعِدَ مِنَ ٱلْبَيْتِ وَإِسْمَـٰعِيلُ رَبَّنَا تَقَبَّلْ مِنَّآ ۖ إِنَّكَ أَنتَ ٱلسَّمِيعُ ٱلْعَلِيمُ ١٢٧

*127. កាលអ៊ីបរ៉ហ៊ីមនិងអ៊ីសម៉ាអ៊ីលបានលើកគ្រឹះព្រះមហាវិមាន (គឺកាក់បាស់) ឡើង [អ្នកទាំងពីរបានទូលថា៖] "ព្រះម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ សូមព្រះអង្គទទួលពីអស់ទូលព្រះបង្គំជាខ្ញុំ[នូវសំណង់នេះ] ។ ពិតណាស់ព្រះអង្គទ្រង់សវនាការ ព្រះអង្គទ្រង់ញាណ ។"* ស៊ូរ៉េាះត៍ អាល់-បាក៏រ៉េាះត៍ អាយ៉ាស់ 127 (2:127))





ព្រះអង្គទាំងពីរعليهم السلام បានសាងកាក់បាស់។ ព្រះសាស្ដាអ៊ីសម៉ាអ៊ីលعَلَيْهِ السَّلَامُជញ្ជូនថ្ម ព្រះសាស្ដាអ៊ីបរ៉ហ៊ីមعَلَيْهِ السَّلَامُតម្រៀបថ្មនោះ។ ទេវតាយ៉ីបរ៉អ៊ីលعَلَيْهِ السَّلَامُជាអ្នកដឹកនាំគ្រប់ដំណាក់ការ ប្រាប់ឲ្យដាក់ថ្មខ្មៅ (اَلْحَجَرَ الْأَسْوَدَ) នៅកន្លែងណា។ ក្រោយពីបានសាងសង់ចប់ស្រេចបាច់ហើយ ទាំងអស់គ្នាعليهم السلامបានបំពេញពិធីហាជ្ជ។ ព្រះសាស្ដាអ៊ីសម៉ាអ៊ីលعَلَيْهِ السَّلَامُបានតាំងលំនៅនៅឯម៉ាក់កាស្ហ បានរស់នៅទីនេះមួយជីវិត។ ព្រះសាស្ដាមូហាំម៉ាដ្ឋយើងصلى الله عليه وآله وسلمជាព្រះរាជបុត្ររាជនត្តាជាន់ក្រោយរបស់ព្រះអង្គعَلَيْهِ السَّلَامُ។

## លំហាត់

ចូរឆ្លើយសំណួរតទៅគឺះ

១. ព្រះសាស្ដាអ៊ីបរ៉ហ៊ីមعَلَيْهِ السَّلَامُបានឲ្យព្រះនាងហាយ៉ារ៍ និងព្រះសាស្ដាអ៊ីសម៉ាអ៊ីលعَلَيْهِ السَّلَامُនៅកន្លែងណា ? ហេតុអ្វី ?

២. ព្រះនាងហាយ៉ារ៍បានដើររកទឹកនៅត្រង់ណា ? ទីបំផុតព្រះនាងរកទឹកបាននៅកន្លែងណា ?

៣. "យ៉ៅម៍ អាល់-តារវីយ៉ាស្ទ" និង "យ៉ៅម៍ អាល់-អារ៉ហ្វាស្ទ" មានន័យថាអ្វី ? ត្រូវនឹងអ្វី ?

៤. អ្នកណាកាឡែខ្លួនជាមនុស្សចាស់ ? វាلَعَنَهُ اللّٰهُបានប្រាប់អ្វីព្រះសាស្ដាអ៊ីបរ៉ហ៊ីមعَلَيْهِ السَّلَامُ ? ព្រះអង្គعَلَيْهِ السَّلَامُបានតបវាلَعَنَهُ اللّٰهُថាអ្វី ?

៥. ហេតុអ្វីគេសំឡែះចៀមធ្វើពលីកម្មពេលគេទៅបំពេញពិធីហាជ្ជ ?

## មេរៀនទី ១៩

# ព្រះសាស្ដា អៃយូបعليه السلام

ព្រះសាស្ដាអៃយូបعليه السلامជាចៅរបស់ព្រះសាស្ដាអ៊ីសហាក់عليه السلام ព្រះរាជបុត្ររបស់ព្រះសាស្ដាអ៊ីបរ៉ហ៊ីមعليه السلام ។ ព្រះមហេសីរបស់ព្រះអង្គعليه السلامជាចៅស្រីរបស់ព្រះសាស្ដាយូស៊ុហ្វعليه السلام ។ ព្រះអង្គعليه السلامសម្បូរទ្រព្យសត្វចៀមទាំងហ្វូងៗនិងដីធ្លីច្រើន ។ ព្រះអង្គعليه السلامមានកូនច្រើន ប្រជារាស្ត្រគោរពព្រះអង្គعليه السلامណាស់ ។

ព្រះសាស្ដាអៃយូعليه السلامចិត្តទូលាយណាស់ ព្រះអង្គعليه السلامមើលថែរក្សាកូនកំព្រា ចិញ្ចឹមជនក្រីក្រ ។ ព្រះអង្គعليه السلامគិតដល់មនុស្សរាល់គ្នា ជាពិសេសក្រុមគ្រួសារព្រះអង្គعليه السلامនិងសាច់ញាតិទូទៅ ព្រះអង្គعليه السلامប្រព្រឹត្តិចំពោះបុគ្គលទាំងនេះដោយមេត្តាករុណា ។ ព្រះអង្គعليه السلامអរព្រះគុណអល់ឡោះហ្ទ៍عز وجلជានិច្ចដែលប្រទានអំណោយទាំងនេះឲ្យព្រះអង្គعليه السلام ។

ដោយឃើញព្រះសាស្ដាអៃយូបعليه السلامស្ម័គ្រស្មោះ ដោយស៊ប់ចិត្តចំពោះអល់ឡោះហ្ទ៍عز وجل ស្ហៃតនលعنه اللهគិតធ្វើឲ្យព្រះអង្គعليه السلامលំអៀងចេញពីមាគ៌ាល្អ ។ ព្រោះតែទាក់ទងនឹងព្រះសាស្ដា វាلعنه اللهបានសូមអល់ឡោះហ្ទ៍عز وجلឲ្យវាلعنه اللهមានអំណាចលើរឿងផ្ទាល់ខ្លួនរបស់ព្រះសាស្ដាអៃយូបعليه السلامថា៖ "អល់ឡោះហ្ទ៍عز وجلអើយ ដរាបណាអៃយូបعليه السلامទទួលបាននូវអំណោយព្រះអង្គعز وجل ដរាបនោះគេعليه السلامដឹងព្រះគុណព្រះអង្គعز وجلមិនដាច់ ។ តែបើព្រះអង្គعز وجلឲ្យទូលព្រះបង្គំជាខ្ញុំلعنه اللهមានអំណាចលើរឿងផ្ទាល់ខ្លួនរបស់គេعليه السلام ទូលព្រះបង្គំជាខ្ញុំلعنه اللهនឹងធ្វើឲ្យគេعليه السلامលំអៀងចេញពីព្រះអង្គعز وجل ។"

អល់ឡោះហ្ទ៍عز وجلទ្រង់ញាណច្បាស់ថាព្រះសាស្ដាអៃយូបعليه السلامមានអំណត់ និងខ្ជាប់ខ្ជួន តែដើម្បីជាការពិសោធន៍សម្រាប់ព្រះសាស្ដាព្រះអង្គعز وجلនិងជាមេរៀនសម្រាប់មនុស្សលោក អល់ឡោះហ្ទ៍عز وجلព្រមបំពេញបំណងស្ហៃតនលعنه الله ។

ស្ហៃតនលعنه اللهចាប់ផ្ដើមចុះដៃ ដោយសម្លាប់សត្វទាំងអស់របស់ព្រះសាស្ដាអៃយូបعليه السلام បំផ្លាញដីធ្លីទាំងអស់របស់ព្រះអង្គعليه السلام ។ អាក្រក់លើសនេះ វាلعنه اللهបានសម្លាប់កូនៗព្រះអង្គعليه السلامដែរ ។ តែព្រះសាស្ដាអៃយូបعليه السلامបែរទៅរកអល់ឡោះហ្ទ៍عز وجلដោយសេចក្ដីគោរពខ្លាំងជាងមុន ។

ពេលឃើញផែនការណ៍វាلعنه اللهបរាជ័យ សៃតនلعنه اللهបានបំផ្លាញសុខភាពព្រះសាស្ដាអៃយូបعليه السلام ធ្វើឲ្យព្រះអង្គعليه السلامធ្លាក់ខ្លួនឈឺធ្ងន់ ។ ឃើញព្រះសាស្ដាអៃយូបعليه السلامរងគ្រោះ ប្រជារាស្ត្រព្រះអង្គعليه السلامគិតថាព្រះអង្គعليه السلامប្រាកដជាបានធ្វើប្រការអាក្រក់ណាមួយបានជាអល់ឡោះហ្ទ៍عز وجلធ្វើទណ្ឌកម្មព្រះអង្គعليه السلامបែបនេះ ។ មនុស្សម្នាក៏បានចៀសចេញឆ្ងាយពីព្រះអង្គعليه السلام ។ ទីបំផុត គេបានដេញព្រះអង្គعليه السلامចេញពីសហគមន៍ ព្រះអង្គعليه السلامត្រូវចាកចេញពីស្រុក ។

ព្រះសាស្ដាអៃយូបعليه السلامរស់នៅឯរហោឋាន ចំណាយពេលវេលាបួងសួងអល់ឡោះហ្ទ៍عز وجل ។ ព្រះអង្គعليه السلامមានតែរ៉ោះហ្ម៉ាស្ទ ព្រះមហេសីព្រះអង្គعليه السلام ម្នាក់គត់ជាមិត្ត ។ ព្រះនាងរ៉ោះហ្ម៉ាស្ទជាបង្អែកព្រះអង្គعليه السلام ព្រះនាងប្រកបការងារស្រាលៗនៅឯផ្ទះគេដើម្បីចិញ្ចឹមជីវិត ។

ច្រើនឆ្នាំកន្លងមក សៃតនلعنه اللهបានតែមើល វាلعنه اللهពុំអាចធ្វើឲ្យព្រះសាស្ដាអៃយូបعليه السلامបាត់បង់អំណត់និងសេចក្ដីខ្ជាប់ខ្ជួនបានឡើយ ក្នុងការស្មោះស្ម័គ្រស៊ប់ចិត្តនិងក្នុងការបួងសួងទៅរកអល់ឡោះហ្ទ៍عز وجل ។ ទីបំផុត វាلعنه اللهគិតបំផ្លាញអំណត់ព្រះសាស្ដាអៃយូបعليه السلامតាមរយៈព្រះមហេសីព្រះអង្គعليه السلام ។

ថ្ងៃមួយសៃតនلعنه اللهបានមករកព្រះនាងរ៉ោះហ្ម៉ាស្ទ ដោយកាឡៃខ្លួនជាមនុស្សប្រាប់ព្រះនាងថាមានមធ្យោបាយមួយ សម្រាប់ព្យាបាលជម្ងឺធ្ងន់របស់ស្វាមីព្រះនាង ។ វាلعنه اللهបានប្រាប់ឲ្យព្រះនាងសំឡែះពពែមួយក្នុងនាមវាلعنه الله កុំសំឡែះពពែនោះក្នុងព្រះនាមអល់ឡោះហ្ទ៍عز وجلកុំ ។ វាلعنه اللهបានធានាថាសាច់ពពែនោះនឹងធ្វើឲ្យព្រះសាស្ដាអៃយូបعليه السلامជាភ្លាម ។

មកដល់ផ្ទះវិញ ព្រះនាងបានស្នើសូមឲ្យស្វាមីព្រះនាងធ្វើតាមមធ្យោបាយនេះ ព្រះស្វាមីព្រះនាងយល់ដឹងការណ៍ភ្លាម ។ ព្រះអង្គعليه السلامប្រាប់ព្រះនាងថា៖ "សត្រូវរបស់ព្រះម្ចាស់عز وجلខ្ញុំعليه السلامធ្វើនាងវង្វេងមែនទេ ? គួរឲ្យស្ដាយណាស់ យើងបានរស់នៅដោយសុខសាន្តអាស្រ័យព្រះមេត្តាករុណារបស់អល់ឡោះហ្ទ៍عز وجل អស់រយៈពេលប៉ុន្មានឆ្នាំហើយ ?" ព្រះនាងតបថា៖ "ប៉ែតសិបឆ្នាំ ។" ព្រះអង្គعليه السلامមានវចនៈថា៖ "យើងបានរងគ្រោះអស់រយៈពេលប៉ុណ្ណា ?" ព្រះនាងបានថា៖ "ប្រាំពីរឆ្នាំ ។" ព្រះសាស្ដាអៃយូបعليه السلامបានប្រាប់ព្រះនាងដោយក្រោធថា៖ "ហេតុអ្វីយើងមិនអត់ទ្រាំរងគ្រោះ ឲ្យស្មើនឹងអំឡុងពេលដែលយើងបានរស់នៅដោយសុភមង្គល

នោះដែរ ? សូមស្បថចំពោះអល់ឡោះហ៍﷿ បើខ្ញុំﷷជាពីជម្ងឺនេះ ខ្ញុំﷷនឹងវាយនាង ១០០ រំពាត់ព្រោះតែនាងស្នើសូមមិនត្រឹមត្រូវ ។" បន្ទាប់មកព្រះអង្គﷷឲ្យព្រះនាងចាកចេញពីមុខព្រះអង្គﷷ ទុកឲ្យព្រះអង្គﷷនៅតែឯង ។ ទីបំផុត ព្រះសាស្តាអៃយូបﷷបែរទៅរកអល់ឡោះហ៍﷿ ប្តឹងអល់ឡោះហ៍﷿អំពីស៊ៃតន(لعنه الله)ដែលព្យាយាមបំបែរព្រះអង្គﷷចេញពីជំនឿព្រះអង្គﷷ ។

ព្រះគម្ពីរគួរអានថែងថា៖

۞وَأَيُّوبَ إِذْ نَادَىٰ رَبَّهُۥٓ أَنِّي مَسَّنِيَ ٱلضُّرُّ وَأَنتَ أَرْحَمُ ٱلرَّٰحِمِينَ ﴿٨٣﴾ فَٱسْتَجَبْنَا لَهُۥ فَكَشَفْنَا مَا بِهِۦ مِن ضُرٍّۖ وَءَاتَيْنَٰهُ أَهْلَهُۥ وَمِثْلَهُم مَّعَهُمْ رَحْمَةً مِّنْ عِندِنَا وَذِكْرَىٰ لِلْعَٰبِدِينَ ﴿٨٤﴾

*83. អៃយូប កាលគេបានបួងសួងព្រះម្ចាស់គេថា៖ "ទុក្ខវេទនាពើបពះលើទូលព្រះបង្គំជាខ្ញុំ ។ មានតែព្រះអង្គទេដែលមានព្រះធម៌មេត្តាលើសបណ្តាអ្នកមានធម៌មេត្តា ។" 84 ច្នេះយើងបានឆ្លើយតបគេ យើងបានកម្ចាត់ទុក្ខវេទនារបស់គេ ហើយយើងបានឲ្យគ្រួសារគេមកគេនិងអ្នកឯទៀតដូចពួកគេដែរ ជាមេត្តាធម៌ដែលមកពីយើងនិងជាសេចក្តីរំឭកសម្រាប់អ្នកសក្ការៈបូជាទាំងឡាយ ។* ស៊ូរ៉ោះតុ៏ អាល់-អាន់ប៊ីយ៉ាអ៊ុ អាយ៉ាស្ទ៊ 83-84 (21:83-84))

អល់ឡោះហ៍﷿បានទទួលការបួងសួងរបស់ព្រះសាស្តាអៃយូបﷷ បានឲ្យព្រះអង្គﷷជាពីទុក្ខវេទនាទាំងអស់ ។

ព្រះគម្ពីរគួរអានថែងថា៖

ٱرْكُضْ بِرِجْلِكَۖ هَٰذَا مُغْتَسَلٌۢ بَارِدٌ وَشَرَابٌ ﴿٤٢﴾ وَوَهَبْنَا لَهُۥٓ أَهْلَهُۥ وَمِثْلَهُم مَّعَهُمْ رَحْمَةً مِّنَّا وَذِكْرَىٰ لِأُو۟لِى ٱلْأَلْبَٰبِ ﴿٤٣﴾ وَخُذْ بِيَدِكَ ضِغْثًا فَٱضْرِب بِّهِۦ وَلَا تَحْنَثْۗ إِنَّا وَجَدْنَٰهُ صَابِرًاۚ نِّعْمَ ٱلْعَبْدُ إِنَّهُۥٓ أَوَّابٌ ﴿٤٤﴾

*42. [គេបានទទួលព្រះតម្រាស់បញ្ជាមកថា៖] "ចូរអ្នកតន្ត្រំ[ដី]ដោយជើងអ្នក ! នេះគឺទឹកត្រជាក់សម្រាប់ឲ្យងូតនិងផឹក ។" 43. ហើយយើងបានប្រគល់គ្រួសារគេមកឲ្យគេវិញ និងដូចពួកគេជាមួយពួកគេផង (ពោលគឺ ច្រើនលើសនោះពីរដង) ជាមេត្តាធម៌នៃយើង និងជាការរំឭកសម្រាប់ជនទាំងឡាយណាដែលមានវិចារណញ្ញាណ ។ 44. [យើងមានតម្រាស់ប្រាប់គេថា៖] "ចូរអ្នកយកដៃចាប់មែកឈើមួយបាច់ ហើយ*

*ចូរអ្នកវាយ[នាង]ដោយមែកឈើមួយបាច់នេះ ។ ចូរអ្នកកុំក្បថពាក្យសម្បថឡើយ ។" យើងបានឃើញថាគេមានអំណត់ ។ គេជាបាវបម្រើដ៏ឧត្តមម្នាក់ គេបានដឹងកំហុសនិងស្មារលោ ។* ស៊ូរ៉ោះត៍ ស្វដ្ទ៍ អាយ៉ាស់ 42-44 (38:42-44))

ព្រះសាស្តាអៃយូបعليه السلامបានតន្ត្រំដីដោយជើង ខ្សែទឹកមួយបាញ់ចេញមក ។ ពេលព្រះអង្គعليه السلامយកទឹកនេះមកលាងខ្លួន ជម្ងឺព្រះអង្គعليه السلامបាត់អស់ ព្រះអង្គعليه السلام ទៅជាធម្មតាវិញ ។ ព្រះមហេសីព្រះអង្គعليه السلام ព្រះនាងរ៉ោះហ៊្មាស់ ព្រួយបារម្ភអំពីព្រះអង្គعليه السلامណាស់ តែពេលព្រះនាងត្រឡប់មកវិញ ព្រះនាងភ្ញាក់ព្រើតដែលឃើញព្រះអង្គعليه السلامមានសុខភាពដូចដើមវិញ ។

ព្រះសាស្តាអៃយូបعليه السلامត្រេកអរ ដែលបានជួបមុខព្រះមហេសីព្រះអង្គعليه السلام វិញ តែបន្ទាប់មកបន្តិចព្រះអង្គعليه السلامនឹកឃើញពាក្យសម្បថដែលព្រះអង្គعليه السلامបានស្បថថានឹងធ្វើទណ្ឌកម្មព្រះនាងរ៉ោះហ៊្មាស់ ។ តែអល់ឡោះហ៍عز وجلបានបើកឲ្យដឹងថាឲ្យវាយព្រះនាងស្រាលៗ ដើម្បីនឹងឲ្យព្រះអង្គعليه السلامអាចធ្វើតាមពាក្យសម្បថបានដោយមិនបាច់ធ្វើឲ្យព្រះនាងឈឺ ព្រោះព្រះនាងបាននៅបម្រើព្រះអង្គعليه السلامដោយស្មោះក្នុងគ្រាលំបាក ។

បន្ទាប់មក អល់ឡោះហ៍عز وجلបានប្រទានកូនចៅមុនៗរបស់ព្រះអង្គعليه السلامឲ្យព្រះអង្គعليه السلامវិញ ។ អល់ឡោះហ៍عز وجلបានឲ្យព្រះអង្គعليه السلامមានកូនច្រើន មានអ្នកតាមច្រើនជាងមុន ។

មានមេរៀនសំខាន់មួយសម្រាប់យើង នៅក្នុងអំណត់ដ៏ល្បីល្បាញរបស់ព្រះសាស្តាអៃយូបعليه السلام ។ ព្រះអង្គعليه السلامបានរងការលំបាកដោយគ្មានសេចក្តីជូរចត់ ព្រះអង្គعليه السلامចុះចូលក្រោមព្រះឆន្ទៈរបស់អល់ឡោះហ៍عز وجل អល់ឡោះហ៍عز وجلតបស្នងយ៉ាងច្រើនបណ្តាអ្នកដែលខ្ជាប់ខ្ជួនក្នុងការផ្គាប់ព្រះអង្គعز وجل ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺ៖

១. ព្រះសាស្តាអៃយូប عليه السلام និងព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام មានទំនាក់ទំនងសាច់សាលោហិតអ្វីនឹងគ្នា ?

២. ស្ហៃតន لعنه الله បានសូមអ្វីពីអល់ឡោះហ៍ عز وجل ដើម្បីនឹងអាចធ្វើឲ្យព្រះសាស្តាអៃយូប عليه السلام វង្វេងបាន ? ហេតុអ្វីអល់ឡោះហ៍ عز وجل ព្រមបំពេញបំណងវា لعنه الله ?

៣. ស្ហៃតន لعنه الله ធ្វើឲ្យព្រះសាស្តាអៃយូប عليه السلام វិនាសអ្វីខ្លះ ?

៤. ស្ហៃតន لعنه الله បានស្នើឲ្យព្រះមហេសីរបស់ព្រះសាស្តាអៃយូប عليه السلام ធ្វើអ្វី ? ព្រះសាស្តាអៃយូប عليه السلام មានប្រតិកម្មអ្វី ?

៥. ព្រះសាស្តាអៃយូប عليه السلام បានជាសះស្បើយដូចម្តេច ?

## មេរៀនទី ២០

# ព្រះសាស្ដា យូនុសعليه السلام

ព្រះសាស្ដាយូនុសعليه السلامត្រូវចាត់បញ្ជូនទៅរកប្រជារាស្ត្រណៃនីវ៉ា (បាប៊ីល بابل) ដើម្បីដឹកនាំពួកគេនៅលើផ្លូវត្រូវ ។ មនុស្សពួកនេះធ្វើសក្ការៈរូបព្រះ ទោះបីព្រះសាស្ដាយូនុសعليه السلامព្យាយាមពន្យល់ប្រាប់ពួកគេទាំងថ្ងៃទាំងយប់ ថាការធ្វើសក្ការៈរូបព្រះនោះមិនមានប្រយោជន៍ទេក៏ដោយ ពួកគេមិនស្ដាប់ព្រះអង្គعليه السلامទេ ។ ពួកគេនិយាយដាក់ព្រះអង្គعليه السلامថា៖ "លោកعليه السلامនិយាយកុហក ។ ដូនតាយើងធ្លាប់តែធ្វើសក្ការៈរូបព្រះយូរណាស់មកហើយ យើងនឹងធ្វើដូចដូនតាយើងដែរ ។"

ព្រះសាស្ដាយូនុសعليه السلامព្យាយាមទាក់ទាញមនុស្សអស់រយៈពេលដ៏យូរ ឲ្យធ្វើសក្ការៈព្រះតែមួយគត់ ។ ព្រះអង្គعليه السلامបានព្រមានពួកគេអំពីទណ្ឌកម្មអល់ឡោះហ្ទ៍عز وجلបើពួកគេនៅតែប្រព្រឹត្តតាមទម្លាប់ប្រកបដោយទោសនេះ តែពួកគេមិនព្រមលះបង់ចោលការធ្វើសក្ការៈរូបព្រះទេ ។ ពួកគេបានថា៖ "យូនុសعليه السلامអើយ កុំបារម្ភយើង យើងមិនជឿព្រះម្ចាស់អ្នកعليه السلامជាដាច់ខាត យើងមិនខ្លាចទណ្ឌកម្មណាមួយឡើយ ។"

ទីបំផុត ព្រះសាស្ដាយូនុសعليه السلامធុញទ្រាន់នឹងប្រជារាស្ត្រចចេសរឹងរូសនេះ ។ ព្រះអង្គعليه السلامបានសូមឲ្យអល់ឡោះហ្ទ៍عز وجل ដាក់ទណ្ឌកម្មព្រះអង្គعز وجلមកលើប្រជារាស្ត្រនេះ ហើយចាកឆ្ងាយពីស្រុកនេះ ។ តែព្រះសាស្ដាយូនុសعليه السلامបានធ្វើខុសព្រោះដោយសារតែព្រះអង្គعليه السلامក្រោធ បានជាព្រះអង្គعليه السلامចាកចោលប្រជារាស្ត្រព្រះអង្គعليه السلامមុនអល់ឡោះហ្ទ៍عز وجلដាក់ព្រះបញ្ជាឲ្យធ្វើដូច្នេះ ។

បន្ទាប់ពីព្រះអង្គعليه السلامបានចាកចេញផុត សញ្ញាទណ្ឌកម្មអល់ឡោះហ្ទ៍عز وجلបានប្រាកដឡើងនៅលើស្រុកណៃនីវ៉ា ។ ដុំពពកធំមួយបាំងពីលើតំបន់នេះ បណ្ដាលឲ្យដែនដីងងឹត ។ ប្រជារាស្ត្រដឹងខ្លួនថានឹងទទួលរងទណ្ឌកម្មព្រោះតែបានសាងបាបកម្ម ។ បុរសអ្នកមានប្រាជ្ញាញាណម្នាក់បានណែនាំឲ្យពួកគេសូមខមាទោសអល់ឡោះហ្ទ៍عز وجلមុននឹងត្រូវកម្ទេចចោលទាំងអស់គ្នា ។ ទាំងអស់គ្នា ក្មេង ចាស់ ស្រីប្រុស ចេញពីក្នុងផ្ទះដើម្បីបួងសួងអល់ឡោះហ្ទ៍عز وجلដោយស្មោះ សូមឲ្យព្រះអង្គعز وجل

លើកលែងទោសឲ្យពួកគេ ។ អល់ឡោះហ៊្ញ﷿ព្រមទទួលការបួងសួងរបស់ពួកគេ ហើយបានដកទណ្ឌកម្មព្រះអង្គ﷿វិញ ។



ព្រមនឹងពេលនោះ ព្រះសាស្តាយូនុសعليه السلាមបានចាកចេញឆ្ងាយ ទៅដល់ជាយសមុទ្រ ។ ព្រះអង្គعليه السلامឃើញគេឡើងទូកជិតចេញដំណើរ ។ ព្រះអង្គعليه السلامសូម ដោយសារផង ។ អ្នកដំណើរ ព្រមឲ្យព្រះអង្គعليه السلامទៅជាមួយដោយរីករាយ ព្រោះគេឃើញព្រះអង្គعليه السلام ជាមនុស្សគួរឲ្យគោរព ។

នៅកណ្តាលសមុទ្រ នាវាត្រូវខ្យល់ព្យុះខ្លាំង ។ ដោយសារទម្ងន់ នាវាស្ថិតនៅក្នុងគ្រោះថ្នាក់លិចលង់ ដូច្នេះនាយនាវាបានប្រាប់ថា ត្រូវតែសម្រាលទម្ងន់នាវាពុំនោះទេទាំងអស់គ្នានឹងលង់ទឹកស្លាប់ ។ គេបានមូលមតិគ្នាថាត្រូវចោលមនុស្សម្នាក់ពីលើនាវាទៅក្នុងទឹក ។ ពួកគេបានចាប់ឆ្នោតផ្សងសំណាងដើម្បីនឹងដឹងថាត្រូវចោលអ្នកណា ។ ឆ្នោតផ្សងសំណាងធ្លាក់ទៅលើព្រះសាស្តាយូនុសعليه السلام តែព្រោះតែគេឃើញថាព្រះអង្គعليه السلامជាបុគ្គលថ្លៃថ្នូរ គេចាប់ឆ្នោតផ្សងម្តងទៀត ។ ព្រះសាស្តាយូនុសعليه السلامជាប់ឆ្នោតទៀត ។ ពួកគេលែងមានជម្រើស ត្រូវតែចោលព្រះអង្គعليه السلامទៅក្នុងទឹកសមុទ្រ ។

ពេលនោះ ព្រះសាស្តាយូនុសعليه السلامដឹងខ្លួនថាព្រះអង្គعليه السلامធ្វើខុសដែលបានចោលប្រជារាស្ត្រព្រះអង្គعليه السلامដោយពុំបានរង់ចាំព្រះបញ្ជាពីអល់ឡោះហ៊្ញ﷿ ។ ព្រះអង្គعليه السلامដឹងថាបញ្ហាទាំងនេះមកពីកំហុសព្រះអង្គعليه السلام តែព្រះអង្គعليه السلامទុកចិត្តលើព្រះប្រាជ្ញាញាណរបស់អល់ឡោះហ៊្ញ﷿ ហើយព្រះអង្គعليه السلامលោតទៅក្នុងទឹកសមុទ្រ

ដែលកំពុងរលកខ្លាំង ។

ព្រមនឹងពេលនោះ អល់ឡោះហ្ទ៍ﷻបានឲ្យត្រីធំមួយលេបព្រះសាស្តាយូនុស ﷺទៅក្នុងពោះវា ។ ព្រះសាស្តាយូនុសﷺក៏បាននៅក្នុងពោះត្រីដោយភ័យខ្លាច តែរស់រានមានជីវិត ។ ព្រះគម្ពីរគួរអានថែងថា៖

وَإِنَّ يُونُسَ لَمِنَ ٱلْمُرْسَلِينَ ﴿١٣٩﴾ إِذْ أَبَقَ إِلَى ٱلْفُلْكِ ٱلْمَشْحُونِ ﴿١٤٠﴾ فَسَاهَمَ فَكَانَ مِنَ ٱلْمُدْحَضِينَ ﴿١٤١﴾ فَٱلْتَقَمَهُ ٱلْحُوتُ وَهُوَ مُلِيمٌ ﴿١٤٢﴾ فَلَوْلَآ أَنَّهُۥ كَانَ مِنَ ٱلْمُسَبِّحِينَ ﴿١٤٣﴾ لَلَبِثَ فِى بَطْنِهِۦٓ إِلَىٰ يَوْمِ يُبْعَثُونَ ﴿١٤٤﴾

*139. យូនុសជាម្នាក់ក្នុងចំណោមសាស្តាទាំងឡាយ[របស់យើង] ។ 140. កាល គេបានរត់គេចខ្លួនទៅលើនាវាមួយដែលពេញពៀប ។ 141. គេបានចាប់ឆ្នោត ហើយបាននៅក្នុងចំណោមជនដែលត្រូវបោះបង់ចោល ។ 142. ត្រីមួយបានលេប គេខណៈដែលគេគួរឲ្យស្តីបន្ទោស[ខ្លួនឯង] ។ 143. បើសិនជាគេមិនមែនជាម្នាក់ ក្នុងចំណោមអ្នកថ្វាយសេចក្តីស្ញើចសរសើរ[ចំពោះអល់ឡោះហ្ទ៍] ទេនោះ 144. គេ ប្រាកដជានៅក្នុងពោះវា រហូតដល់ថ្ងៃមួយដែលពួកគេនឹងរស់ពីស្លាប់ឡើងវិញជា មិនខាន ។* ស៊ូរ៉ោះត្ញ៉ អាស្ស៊-ស្វហ្វ៊ហ្វាត អាយ៉ាស្ញ៉ 139-144 (37:139-144))

ព្រះសាស្តាយូនុសﷺនៅក្នុងពោះត្រីច្រើនថ្ងៃច្រើនយប់ ខណៈដែលវា ហែលក្នុងសមុទ្រ ។ ព្រះអង្គﷺបួងសួងអល់ឡោះហ្ទ៍ﷻនៅក្នុងភាពងងឹតនៃពោះ ត្រី សូមឲ្យអល់ឡោះហ្ទ៍ﷻអភ័យទោសឲ្យព្រះអង្គﷺដែលបានធ្វើខុស អល់ឡោះហ្ទ៍ﷻព្រមទទួលការបួងសួងរបស់ព្រះអង្គﷺ ។

ព្រះគម្ពីរគួរអានថែងថា៖

وَذَا ٱلنُّونِ إِذ ذَّهَبَ مُغَٰضِبًا فَظَنَّ أَن لَّن نَّقْدِرَ عَلَيْهِ فَنَادَىٰ فِى ٱلظُّلُمَٰتِ أَن لَّآ إِلَٰهَ إِلَّآ أَنتَ سُبْحَٰنَكَ إِنِّى كُنتُ مِنَ ٱلظَّٰلِمِينَ ﴿٨٧﴾ فَٱسْتَجَبْنَا لَهُۥ وَنَجَّيْنَٰهُ مِنَ ٱلْغَمِّ ۚ وَكَذَٰلِكَ نُۨجِى ٱلْمُؤْمِنِينَ ﴿٨٨﴾

*87. ស្សាន់-នូន (យូនុស) កាលគេបានចាកចេញទៅទាំងក្រេវក្រោធ ។ គេបានគិត ថាយើងនឹងមិនឲ្យគេរងទុក្ខវេទនាទេ ។ ដូច្នេះគេបានអង្វរបួងសួង[យើង]ក្នុងភាព ងងឹតថា៖ "ពុំមានព្រះទេក្រៅពីព្រះអង្គ ។ សូមថ្វាយសេចក្តីរុងរឿងចំពោះព្រះអង្គ ។ ទូលព្រះបង្គំជាខ្ញុំបាននៅក្នុងចំណោមជនទុច្ចរិត ។" 88. ដូច្នេះយើងបានឆ្លើយតប គេ យើងបានជួយសង្គ្រោះគេឲ្យផុតពីទុក្ខព្រួយ ។ បែបនេះឯងដែលយើងជួយ សង្គ្រោះបណ្តាអ្នកមានសទ្ធាជ្រះថ្លា ។* ស៊ូរ៉ោះត្ញ៉ អាល់-អាន់ប៊ីយ៉ាអ៊ុ អាយ៉ាស្ញ៉ 87-88 (21:87-88))

ត្រីបានចូលមកក្បែរច្រាំង ខ្ជាក់ព្រះសាស្ដាយូនុស عليه السلام មកលើដីគោកដោយសុវត្ថិភាព ។ ខ្លួនព្រះអង្គ عليه السلام រលាកទឹកអាស៊ីតក្នុងពោះត្រី អល់ឡោះហ៊្វ عز وجل ធ្វើឲ្យរុក្ខជាតិម្យ៉ាងដុះ ស្លឹកវាព្យាបាលព្រះអង្គ عليه السلام ឲ្យជាសះស្បើយ ផ្លែវាជាអាហារព្រះអង្គ عليه السلام ។ ព្រះសាស្ដាយូនុស عليه السلام មានសុខភាពល្អឡើងវិញ ហើយបានទទួលព្រះរាជបញ្ជាឲ្យទៅកាន់ស្រុកណៃនីវ៉ា ។

ពេលត្រឡប់មកដល់វិញ ព្រះអង្គ عليه السلام ភ្ញាក់ផ្អើលដែលឃើញប្រជារាស្ត្របោះបង់ចោលរូបព្រះ ធ្វើសក្ការៈអល់ឡោះហ៊្វ عز وجل ។ ប្រជារាស្ត្របានទទួលព្រះអង្គ عليه السلام ដោយសេចក្ដីអបអរសាទរ ព្រះអង្គ عليه السلام បានរស់នៅជាមួយពួកគេមួយជីវិត ដោយបង្ហាត់បង្រៀននិងដឹកនាំពួកគេនៅលើមាគ៌ាត្រូវ ។

# លំហាត់

ចូរឆ្លើយសំណួរតទៅគឺៈ

១. អល់ឡោះហ្ម៍ﷻដាក់ទណ្ឌកម្មប្រជារាស្ត្រស្រុកណៃនីវ៉ាដូចម្ដេច ? លទ្ធផលចុងក្រោយដូចម្ដេច ?

២. អ្វីកើតឡើងដល់នាវាដែលព្រះសាស្ដាយូនុសعليه السلامជិះ ? ទីបំផុតដូចម្ដេច ?

៣. ហេតុអ្វីព្រះសាស្ដាយូនុសعليه السلامព្រមរងគ្រោះទាំងអស់របស់ព្រះអង្គعليه السلام ?

៤. ព្រះសាស្ដាយូនុសعليه السلامធ្លាក់ទៅដល់ណា ក្រោយពីបានលោតទៅក្នុងទឹកសមុទ្រ ? ព្រះអង្គعليه السلامធ្វើអ្វីនៅក្នុងនោះ ?

៥. អ្វីបានកើតឡើងដល់ព្រះសាស្ដាយូនុសعليه السلام បន្ទាប់ពីអល់ឡោះហ្ម៍ﷻព្រមទទួលការសូមខទោសរបស់ព្រះអង្គعليه السلامដែលបានធ្វើខុស ?

## បទនិពន្ធ

ចូរសាកល្បងសរសេរបទនិពន្ធបីទំព័រ រៀបរាប់អំពីដំណាក់កាលសំខាន់ៗក្នុងព្រះជីវប្រវត្តិរបស់ព្រះសាស្តាមូហាំម៉ាដ់យើងﷺ ចាប់តាំងពីព្រះអង្គﷺបានទទួលអាយ៉ាស់ដំបូងបង្អស់នៃព្រះគម្ពីរគួរអាន រហូតដល់កាលព្រះអង្គﷺភៀសខ្លួនពីម៉ាក់កាស់ទៅម៉ាឌីណាស់ ។

ចូរដាក់ចំណងជើងឲ្យបទនិពន្ធរបស់អ្នក ។ ចូរចៀសវាងយកឃ្លាក្នុងមេរៀនមកប្រើ ចូរសរសេរដោយប្រើពាក្យសម្ដីនិងឃ្លាផ្ទាល់ខ្លួនរបស់អ្នក ។ ចូរប្រើពាក្យខាងក្រោមនេះក្នុងបទនិពន្ធរបស់អ្នក គឺ៖

អាប៊ូ ឡាហាប់
ស៊ុល អ៊ុស្វីរ៉ោះត៍
ការសង្កត់សង្កិន
បាដ្វារ៍
ប៊ីឡាល់
អ៊ុំម៉ារ យ៉ាសៀរ
ភ្នំហ៊ីរ៉អ៍
ស្វរ៉ោះត៍ អាល់-អាឡាក់
ព្រះនាងខ៍ឌីយ៉ាស់سلام الله عليها
ស្រែដ៍ ប៊ិន ហារីស្វ
អាប៊ូ ស៊ុហ្វយ៉ាន
ស្តេចណាយ៉ាស៊ី
យ៉ាក់ហ្វារ
ព្រះនាងម៉ារយ៉ាំسلام الله عليها
ពហិការ
ជ្រលង
អ៊ាក់បាស់

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីមុាំមេម៉ាស្ហ៊ុប្ហាប់ទាំង ៤ ។

| ឈ្មោះអ៊ីមុាំមេម៉ាស្ហ៊ុប្ហាប់ | ម៉ាស្ហ៊ុប្ហាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់ សករាជហ៊ីជ្ជរ៉ោះត៍ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហ្គានីហ្វាស្ហ៍ | ហ្គាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស្ហ៍-ស្ហាហ្វីអ៊ី | ស្ហាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស្ហ៍ម៉ាដ្ហ៍ ហ្គាន់បាល់ | ហ្គាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាសា មូហ្ហាំម៉ាដ្ហ៍ ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស.

អ៊ីមុាំអ្នកស្នងព្រះសាស្តាមូហ្ហាំម៉ាដ្ហ៍ﷺទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ឋានន្តរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អ៊ាលី | អាប៊ូ អាល់-ហ្គាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហ្គាសាន់ | អាប៊ូ មូហ្ហាំម៉ាដ្ហ៍ | អាល់-មុជ្ថាបា | 625-670/3-50 |
| 3 | ហ៊្គូសៃន៍ | អាប៊ូ អ៊ាប់ឌុលឡោះហ្វ៍ | សៃយីដ្ហ៍ អាស្ហ៍-ស្ហ៊ូហាដ្ឋាអ៊ុ | 626-680/4-61 |
| 4 | អ៊ាលី ប៊ិន ហ៊្គូសៃន៍ | អាប៊ូ មូហ្ហាំម៉ាដ្ហ៍ | អាស់-សាជ្ជ៍យ៉ាដ្ហ៍ ស្ហៃនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហ្ហាំម៉ាដ្ហ៍ អាល់-បាគៀរ | អាប៊ូ យ៉ាក្ហ៍ហ្វារ | បាគៀរ អាល់-អ៊្លូម | 676-733/57-114 |
| 6 | យ៉ាក្ហ៍ហ្វារ | អាប៊ូ អ៊ាប់ឌុលឡោះហ្វ៍ | អាស្ហ៍-ស្ហ៍ឌិក្ហ | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាក្ហ៍ហ្វារ | អាប៊ូ អាល់-ហ្គាសាន់ | អាល់-កាស្ហ៊ីម | 745-799/128-183 |
| 8 | អ៊ាលី ប៊ិន មូសា | អាប៊ូ អាល់-ហ្គាសាន់ | អារ-រីដ្ហ៍ | 765-819/148-203 |
| 9 | មូហ្ហាំម៉ាដ្ហ៍ ប៊ិន អ៊ាលី | អាប៊ូ យ៉ាក្ហ៍ហ្វារ | អាត់-តាគ្គី អាល់-យ៉ាវ៉ាដ្ហ៍ | 811-835/195-220 |
| 10 | អ៊ាលី ប៊ិន មូហ្ហាំម៉ាដ្ហ៍ | អាប៊ូ អាល់-ហ្គាសាន់ | អាល់-ហ្គាឌី អាន់-ណាគ្គី | 828-868/212-254 |

| | | | | |
|---|---|---|---|---|
| 11 | ហ្ចាសាន់ ប៊ិន អ៊្ចលី | អាប៊ូ មូហ្ចាំម៉ាដ្ញ | អាល់-អ៊្ចស់ការី | 846-874/232-260 |
| 12 | មូហ្ចាំម៉ាដ្ញ ប៊ិន ហ្ចាសាន់ | អាប៊ូ ក៏ស៊ីម | អាល់-ម៉ាស្ញូឌី<br>អាល់-ហ្ម៊ុច្ចយ៉្ចាស្ញ<br>ស៊្ញហ្វ៊ីប អាល់-ស្ញាម៉ាន<br>អាល់-ក៏អ៊ីម | 869/255 |